**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ពា លីម៉ូ**

សាស្ត្រាចារ្យណែនាំ

លោក **ម៉ៅ មុណ្ណា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៨ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-២០១៨។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកឪពុក **ខ្វាន់ ពឺន** និងអ្នកម្តាយ **តុល តូរ៉ាវី** ជាទីគោរពស្រឡាញ់នៃកូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តា ករុណា តាំងពីតូចរហូតដល់ធំពេញវ័យ ដែលរូបលោកទាំងពីរបានលះបង់គ្រប់យ៉ាងទាំងកម្លាំងកាយចិត្ត ថវិកា អប់រំទូន្មានប្រៀនប្រដៅកូន ជំរុញលើកទឹកចិត្តដល់កូនក្នុងការសិក្សារៀនសូត្រ ឲ្យកូនធ្វើខ្លួនជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គម។ ទឹកចិត្តដែលរឹតតែមិនអាចកាត់ថ្លៃបាន ដោយការយកចិត្តទុកដាក់ និងខិតខំរបស់លោកទាំងពីរ ដើម្បីឲ្យរូបកូនបានបន្តការសិក្សាចាប់តាំងពីគ្រូចាប់ដៃឲ្យសរសេរអក្សរ រហូតដល់កូនបានរៀនបន្តដល់មហាវិទ្យាល័យ ទើបកូនមានថ្ងៃនេះគឺជាថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ។

ទន្ទឹមនឹងនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ថា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានគ្រប់គ្រងឲ្យដំណើរការទូទៅក្នុងសាកលវិទ្យាល័យប្រកបដោយភាពរីកចម្រើន ជាពិសេសផ្តល់ឱកាស និងភាពងាយស្រួលជូនដល់និស្សិតបានទទួលការសិក្សាគ្រប់ៗគ្នា ដើម្បីជាធនធានសម្រាប់យកទៅបម្រើសង្គមជាតិ តាមជំនាញនីមួយៗក្នុងទិសដៅតែមួយ គឺការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំបង្រៀនអស់កម្លាំងកាយចិត្ត និងផ្តល់ចំណេះដឹង ចែករំលែកយ៉ាងច្រើនដល់រូបខ្ញុំបាទឲ្យឈានដល់ការបង្កើតស្នាដៃនេះ។

ជាងនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **លោកសាស្ត្រាចារ្យ ម៉ៅ បុណ្ណា** ដែលជាសាស្ត្រាចារ្យណែនាំរូបខ្ញុំបាទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយបង្ហាត់បង្ហាញណែនាំ កែតម្រូវ ផ្តល់អនុសាសន៍ និងជំរុញខ្ញុំបាទ ដើម្បីឲ្យកិច្ចការស្រាវជ្រាវនេះទទួលបានជោគជ័យ។

ចុងបញ្ចប់នេះ ខ្ញុំបាទសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងលោកទាំងអស់ តាមជួយថែរក្សាការពារ ប្រសិទ្ធពរជ័យ សេចក្តីសុខចម្រើនជូនដល់អស់លោកទាំងអស់គ្នា ឲ្យមានសុខភាពល្អកម្លាំងមាំមួន អាយុយឺនយូរ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងរាល់សេចក្តីប៉ងប្រាថ្នា ជាពិសេសសូមឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំ លើមុខវិជ្ជាជាច្រើនរួមមក ខ្ញុំបាទទទួលបានចំណេះដឹងយ៉ាងទូលំទូលាយពីមុខវិជ្ជាទាំងនោះ ក្រោមការជួយខិតខំប្រឹងប្រែងរបស់លោក លោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំយកចិត្តទុកដាក់បង្រៀនរូបខ្ញុំបាទ។ ដោយមានការជួយណែនាំជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ដល់ការបង្ហាត់បង្ហាញក្នុងការបង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើឲ្យខ្ញុំបាទអាចឈានមកដល់ការចងក្រងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង ដើម្បីជាប្រយោជន៍ទូទៅក្នុងសង្គម និងសម្រាប់ការសិក្សាស្រាវជ្រាវ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ខ្ញុំបាទជ្រើសរើសយកប្រធានបទមួយទាក់ទងនឹងប្រព័ន្ធសន្តិសុខសង្គមក្នុងវិស័យសាធារណៈនៅកម្ពុជាដែលមានចំណងជើងថា "របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន"។ ការជ្រើសរើសយកប្រធានបទនេះ គឺដើម្បីឲ្យសិស្ស និស្សិត មន្ត្រីរាជការ អតីតមន្ត្រីរាជការ ជាពិសេសមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវទូទៅ ដែលមានបំណងចង់សិក្សាស្វែងយល់ពីរបបសន្តិសុខសង្គមក្នុងវិស័យសាធារណៈនៅកម្ពុជាមួយនេះ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា សារណានេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវទូទៅ និងក៏ដូចជាមន្ត្រីរាជការ អតីតមន្ត្រីរាជការ ដែលមានបំណងចង់ស្វែងយល់បន្ថែម "របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន" ដែលទទួលបានតាវកាលិកដូចជា តាវកាលិកថែទាំសុខភាព តាវកាលិកហានិភ័យការងារ ការទទួលបានប្រាក់សោធន និងរបបឧបត្ថម្ភផ្សេងៗទៀត ពីស្ថាប័នប្រតិបត្តិករនៃរបបសន្តិសុខសង្គមរួមមាន៖ បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស.) បេឡាជាតិអតីតយុទ្ធជន(ប.ជ.អ.) ជាដើម។ សារណានេះទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមឲ្យកាន់តែច្បាស់អំពីប្រព័ន្ធធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែរ។

ជាការពិតណាស់ ការសរសេរចៀសមិនផុតពីកំហុសអចេតនា និងចំណុចខ្វះខាតមួយចំនួនកើតឡើងជាក់ជាមិនខាន ដូចជាពាក្យពេជន៍ ខ្លឹមសារ អត្ថន័យ និងអក្ខរាវិរុទ្ធជាដើម។ ខ្ញុំបាទសូមទទួលស្វាគមន៍ជានិច្ច រាល់មតិរិះគន់កែលម្អក្នុងន័យស្ថាបនាជាមួយគំនិតល្អៗ របស់មិត្តអ្នកអានទាំងអស់ ក្នុងគោលបំណង និងគោលដៅឲ្យកាន់តែមានភាពល្អប្រសើរជាងមុន។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ................................................ ១

## ជំពូកទី១ ៖ របបសន្តិសុខសង្គមនៅកម្ពុជា

**ផ្នែកទី១ ៖ ប្រព័ន្ធសន្តិសុខសង្គមក្នុងវិស័យសាធារណៈ** ................................................ ៥

**កថាខណ្ឌទី១ ៖ ប្រវត្តិនៃរបបសន្តិសុខសង្គម** ................................................ ៥

**កថាខណ្ឌទី២ ៖ កិច្ចដំណើរការប្រព័ន្ធសន្តិសុខសង្គមក្នុងវិស័យសាធារណៈ** ................................................ ៧

**ផ្នែកទី២ ៖ ស្ថាប័នប្រតិបត្តិករនៃប្រព័ន្ធសន្តិសុខសង្គម** ................................................ ៨

**កថាខណ្ឌទី១ ៖ បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) ................................................ ៨

ក.ស្ថានភាពទូទៅ ................................................ ៩

ខ.រដ្ឋបាល ប.ស.ស ................................................ ១០

**កថាខណ្ឌទី២ ៖ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** (ប.ជ.ស.) ................................................ ១៤

ក.ស្ថានភាពទូទៅ ................................................ ១៥

ខ.ក្រុមប្រឹក្សាភិបាល ................................................ ១៧

គ.អង្គការប្រតិបត្តិនៃ ប.ជ.ស. ................................................ ១៨

**កថាខណ្ឌទី៣ ៖ បេឡាជាតិអតីតយុទ្ធជន** (ប.ជ.អ.) ................................................ ២០

ក.ស្ថានភាពទូទៅ ................................................ ២១

ខ.ក្រុមប្រឹក្សាភិបាល ................................................ ២២

គ.អង្គការប្រតិបត្តិរបស់ ប.ជ.អ. ................................................ ២៤

## ជំពូកទី២ ៖ របបសន្តិសុខសង្គមចំពោះមន្ត្រីសាធារណៈ

**ផ្នែកទី១ ៖ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** ................................................ ២៦

**កថាខណ្ឌទី១ ៖ ការអនុវត្តចំពោះហានិភ័យការងារ** ................................................ ២៦

**កថាខណ្ឌទី២ ៖ ការទទួលបានតាវកាលិក** ................................................ ២៧

ក.តាវកាលិកសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ................................................ ២៧

ខ.តាវកាលិកតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ................................................ ២៧

គ.តាវកាលិកមរណភាពនៃមន្ត្រីសាធារណៈដែលរងហានិភ័យការងារ ................................................ ២៨

**ផ្នែកទី២ ៖ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** ................................................ ៣០

**កថាខណ្ឌទី១ ៖ សេវាថែទាំសុខភាព** ................................................ ៣១

ក.តាវកាលិកផ្នែកសេវា ................................................ ៣១

ខ.សេវា ឬការព្យាបាលដែលមិនរាប់បញ្ចូល ..........................................................................៣៤
គ.ការកំណត់ជំងឺរ៉ាំរ៉ៃ..............................................................................................................៣៤
**កថាខណ្ឌទី២ ៖ បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**...........................................................................................................................៣៤
ក.ការកំណត់អត្រាភាគទានផ្នែកថែទាំសុខភាព ................................................................៣៤
ខ.ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព...................................................៣៥

## ជំពូកទី៣ ៖ របបសន្តិសុខសង្គមចំពោះអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**ផ្នែកទី១ ៖ របបសន្តិសុខសង្គមផ្នែកសោធន** ..........................................................................៣៨
**កថាខណ្ឌទី១ ៖ សិទ្ធិទទួលបានរបបសោធនចំពោះមន្ត្រីរាជការ** ..........................................៣៨
ក.លក្ខខណ្ឌនៃការចូលនិវត្តន៍...........................................................................................៣៩
ខ.ការទទួលរបបសោធន ....................................................................................................៤២
**កថាខណ្ឌទី២ ៖ សិទ្ធិទទួលបានរបបសោធន និងរបបឧបត្ថម្ភផ្សេងៗ ចំពោះអតីតយុទ្ធជន** ...............................................................................................................................................៤៥
ក.លក្ខខណ្ឌនៃការចូលនិវត្តន៍ និងរបបសោធនចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ...៤៥
ខ.លក្ខខណ្ឌនៃការចូលនិវត្តន៍ និងរបបសោធនចំពោះមន្ត្រីនគរបាលជាតិ.............................៤៩
គ.របបឧបត្ថម្ភយោធិន មន្ត្រីនគរបាលជាតិ ដែលពលី មរណៈបង្កឲ្យស្លាប់ បាត់ខ្លួន..............៥២
**ផ្នែកទី២ ៖ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**...................................................................៥៦
**កថាខណ្ឌទី១ ៖ សេវាថែទាំសុខភាព**........................................................................................៥៦
ក.តារកាលិកផ្នែកសេវា .......................................................................................................៥៧
ខ.សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល..............................................................................៥៨
គ.ការកំណត់ជំងឺរ៉ាំរ៉ៃ..............................................................................................................៥៩
**កថាខណ្ឌទី២ ៖ បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**...........................................................................................................................៥៩
ក.ការកំណត់អត្រាភាគទានផ្នែកថែទាំសុខភាព ................................................................៥៩
ខ.ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព...................................................៥៩
**សេចក្តីសន្និដ្ឋាន** ..........................................................................................................................៦២
**អនុសាសន៍** ..................................................................................................................................៦៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

របបសន្តិសុខសង្គមក្នុងវិស័យសាធារណៈ បានដំណើរការចាប់តាំងពីសម័យសង្គមរាស្ត្រនិយមចន្លោះឆ្នាំ១៩៥៣-១៩៧០ មកម្ល៉េះ គួយ៉ាងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានបង្កើតឡើងតាំងពីពាក់កណ្តាលទសវ្សរត្សឆ្នាំ១៩៥០ ដោយឡែករបបសន្តិសង្គមសម្រាប់អតីតយុទ្ធជន ត្រូវបានបង្កើតឡើងនៅក្នុងទសវ្សរត្សទី៦០ ដែលមានឈ្មោះថា បេឡាសោធនទាហាន ដែលបេឡាសោធនទាហាននេះ មានប្រភពធនធានសម្រាប់ទ្រទ្រង់ដំណើរការបានមកពី៖ ប្រាក់កាត់ទុកចំនួន៦%លើចំនួនបៀវត្សទាហាន វិភាគទានថវិការបស់រាជរដ្ឋាភិបាលចំនួន១៥%លើបៀវត្សប្រចាំបណ្តាស័ក្តិ ការប្រាក់ដែលបេឡាចងការ ព្រមទាំងអំណោយ និងអច្ច័យទាន។ទាំងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ត្រូវបានបាត់បង់ទៅវិញក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត ចន្លោះឆ្នាំ១៩៧៥-១៩៧៩។

នៅក្នុងឆ្នាំ១៩៨៣ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចលេខ០១ សសរ. ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៨៣ ស្តីពីគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលសេចក្តីសម្រេចនេះ ចែងអំពីរបបសន្តិសុខសង្គមឧបត្ថម្ភ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ក្នុងករណីមានជំងឺ គ្រោះថ្នាក់ការងារ ការសម្រាលកូន មរណភាព និងជួបការលំបាកខ្លាំង ។ លុះមកដល់ឆ្នាំ១៩៨៥ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចលេខ១៥០ សសរ. ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម(បាត់បង់សម្បទាវិជ្ជាជីវៈ) សម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ។

នៅឆ្នាំ១៩៨៨ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានធ្វើការកែសម្រួលខ្លឹមសារគោលនយោបាយធានារ៉ាប់រងសង្គមមួយចំនួន និងបានចេញសេចក្តីសម្រេចលេខ២៩៥ សសរ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៨៨ ស្តីពីគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តន៍ជន និងជនបាត់បង់សមត្ថភាពពលកម្ម។ បន្ទាប់មក ក្រុមប្រឹក្សារដ្ឋមន្ត្រីក៏បានធ្វើការកែសម្រួលខ្លឹមសារគោលនយោបាយសោធន ដើម្បីឲ្យស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម ដោយចេញសេចក្តីសម្រេចលេខ១៨៤ សសរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩០ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ។

នៅឆ្នាំ១៩៩៣ ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា បានចេញក្រឹត្យលេខ១០ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះនគរបាលប្រជាជនកម្ពុជា ចែងអំពីរបបសន្តិសុខសង្គមសម្រាប់គាំពារមន្ត្រីនគរបាលនៅពេលចូលនិវត្តន៍ ដោយទទួលបានរបបសោធននិវត្តន៍ ព្រមទាំងរបបសោធនបាត់បង់សមត្ថភាពពលកម្ម ដោយសារជំងឺរ៉ាំរ៉ៃ ភាពជរា និងគ្រោះថ្នាក់ផ្សេងៗ។

ក្រោយការបោះឆ្នោតជាសាកលឆ្នាំ១៩៩៣ រដ្ឋសភាជាតិបានបង្កើតរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទី២ ដែលមន្ត្រីរាជការត្រូវគោរព និងអនុវត្តតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឧបត្ថម្ភប្រាក់សោធនជូនមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍ និងឧបត្ថម្ភប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការដែលបាត់បង់សមត្ថភាពការងារ។ ចំណែកឯយោធិននៃកងយោធពលខេមរភូមិន្ទវិញ រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យលេខអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងការបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដែលមានគោលដៅកំណត់លក្ខខណ្ឌនៃការចូលនិវត្តន៍តាមការកំណត់ ការចូលនិវត្តន៍មុនពេលកំណត់ និងលក្ខខណ្ឌនៃការទទួលរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទ នៃកងយោធពលខេមរភូមិន្ទ អនុវត្តច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងច្បាប់វិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦។

នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភា បានសម្រេចបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឲ្យស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានគោលដៅកំណត់ពីរបបសន្តិសុខសង្គមឲ្យស្ថាប័នអនុវត្ត និងមូលនិធិសម្រាប់ទ្រទ្រង់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ ហើយរបបសន្តិសុខសង្គមនេះ គ្របដណ្តប់លើតាវកាលិកដូចជា៖ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។

នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា បានសម្រេចបង្កើតបេឡាជាតិអតីតយុទ្ធជន ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ដែលមានគោលដៅគ្រប់គ្រងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក៏មានគោលបំណងដូចជា៖ អនុវត្តគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលចំពោះអតីតយុទ្ធជន បង្កើនប្រសិទ្ធភាពក្នុងការបើករបបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងគ្រួសារអតីតយុទ្ធជនឲ្យបានឆាប់រហ័សនិងមានតម្លាភាព ចូលរួមចំណែកក្នុងយុទ្ធសាស្ត្រជាតិ កំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ លើកកម្ពស់ជីវភាពខាងសម្ភារៈស្មារតីរបស់អតីតយុទ្ធជន និងបង្កើតសំណាញ់សុវត្ថិ

ភាពសង្គម ព្រមទាំងបង្កើតភាពជាដៃគូជាមួយបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោកលើវិស័យអតីតយុទ្ធជន។ របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន អាចទទួលបានតាវកាលិករួមមាន ៖ ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈពិការភាព ជំងឺ និងគ្រួសាររបស់ជនទាំងនេះ។

នៅឆ្នាំ២០១៧ កន្លងទៅថ្មីៗនេះ រាជរដ្ឋាភិបាលក៏បានចេញអនុក្រឹត្យស្តីពី បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយអនុលោមតាមព្រះរាជក្រឹត្យស្តីពី ការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដែលមានគោលដៅផ្តល់តាវកាលិកសន្តិសុខសង្គម ផ្នែកហានិភ័យការងារចំពោះមន្ត្រីសាធារណៈនិងផ្នែកថែទាំសុខភាពចំពោះមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ តាមរយៈព្រះរាជក្រឹត្យនេះ បានផ្តល់សមត្ថកិច្ចជូនបេឡាជាតិរបបសន្តិសុខសង្គម ដែលជាស្ថាប័នប្រតិបត្តិករក្នុងការគ្រប់គ្រងនិងចាត់ចែងរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិមន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ មន្ត្រីនគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យាដែលបម្រើនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ព្រមទាំងអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

នៅក្នុងឆ្នាំ២០១៨ នេះ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវបានបង្កើតឡើង ដែលមានគោលបំណងធានាប្រសិទ្ធភាព ស្ថិរភាព និងនិរន្តរភាពនៃការគ្រប់គ្រងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន ព្រមទាំងធានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃការចំណាយ និងចីរភាពនៃចំណូលថវិការដ្ឋ។

ដើម្បីឈានដល់ការបកស្រាយប្រធានបទស្តីពី របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន យើងចាំបាច់ត្រូវសិក្សាលើចំណោទបញ្ហាមួយចំនួនដូចក្រោមជាមុនសិន៖

- តើមានស្ថាប័នណាខ្លះ ដែលទទួលបន្ទុករបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ហើយស្ថាប័នទាំងនោះមានភារកិច្ចអ្វីខ្លះ?
- តើមន្ត្រីសាធារណៈ ទទួលបានការគាំពារពីរាជរដ្ឋាភិបាលយ៉ាងដូចម្តេច នៅពេលមានជំងឺ ឬបញ្ហាសុខភាព ឬហានិភ័យការងារ?
- ដើម្បីទទួលបានតាវកាលិក តើអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ហើយតាវកាលិកទាំងនោះទទួលបានយ៉ាងដូចម្តេច ពីស្ថាប័នប្រតិបត្តិករនៃរបបសន្តិសុខសង្គម?
- តើរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានជួយអ្វីខ្លះ ចំពោះសង្គមជាតិ និងជីវភាពរស់នៅរបស់ពួកគេ?

សារណាដែលមានប្រធានបទ របបសន្តិសុខសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន មិនត្រឹមតែរំលេចឲ្យដឹងពីប្រវត្តិរបបសន្តិសុខសង្គមនៃការកកើតរបបសន្តិសុខសង្គមនៅសម័យសង្គមរាស្ត្រនិយម សម័យរដ្ឋកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែរបបសន្តិសុខសង្គមក៏បានចាប់ដំណើរការឡើងវិញ ក្រោយពីប្រទេសកម្ពុជាប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលស្ថាប័នរដ្ឋសភា រាជរដ្ឋាភិបាល ក៏បានបង្កើតលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងការធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីសាធារណៈ និងអតីតមន្ត្រីរាជការដែលមាន ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ជាបន្តបន្ទាប់។ តាមរយៈលិខិតបទដ្ឋានគតិយុត្តទាំងនោះ បានផ្តល់អត្ថប្រយោជន៍ជាច្រើនសម្រាប់មន្ត្រីសាធារណៈ ដូចជាការទទួលបាននូវការថែទាំសុខភាពដោយឥតគិតថ្លៃពីមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នរដ្ឋ និងការទទួលបានតាវកាលិកគ្រោះថ្នាក់ការងារ នៅពេលដែលមន្ត្រីសាធារណៈទទួលរងហានិភ័យការងារ។ ដោយឡែកសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ក៏ទទួលបានរបបសោធនព្រមទាំងទទួលបាននូវការថែទាំសុខភាព និងព្យាបាលជំងឺដោយឥតគិតថ្លៃដូចមន្ត្រីរាជការដែរ។ ការបង្កើតបទដ្ឋានគតិយុត្តទាំងនោះ បានជំរុញឲ្យមានប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម សម្រាប់គាំពារមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅពេលមានហានិភ័យណាមួយកើតឡើងចំពោះពួកគេដោយចៃដន្យ។

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើ និងឲ្យយល់កាន់តែច្បាស់ប្រធានបទនៃសារណាស្តីពី របបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន យើងបានធ្វើការបែងចែកជាបីជំពូកសំខាន់ៗ ក្នុងនោះរួមមាន៖ (ជំពូកទី១)របបសន្តិសុខសង្គមនៅកម្ពុជា (ជំពូកទី២)របបសន្តិសុខសង្គមចំពោះមន្ត្រីសាធារណៈ (ជំពូកទី៣)របបសន្តិសុខសង្គមចំពោះអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

# ជំពូកទី ១
# របបសន្តិសុខសង្គម
# នៅកម្ពុជា

# ជំពូកទី១ ៖ របបសន្តិសុខសង្គមនៅកម្ពុជា

## ផ្នែកទី១ ៖ ប្រព័ន្ធសន្តិសុខសង្គមក្នុងវិស័យសាធារណៈ

របបសន្តិសុខសង្គម ត្រូវបានឲ្យនិយមន័យ ពីរយ៉ាងគឺ៖ ១.ជាបណ្តុំនៃវិធានទាំងឡាយដែលរៀបចំឡើងសម្រាប់ធានាកម្មករនិយោជិត និងគ្រួសាររបស់ពួកគេ(អាចសម្រាប់មន្ត្រីរាជការស៊ីវិល) ទល់នឹងហានិភ័យសង្គមដូចជា គ្រោះថ្នាក់ការងារ ជំងឺវិជ្ជាជីវៈ ប្រាក់សោធន ភាពគ្មានការងារធ្វើ ជំងឺផ្សេងៗ ជរាភាព និងមរណភាពជាដើម។ ២.ជាអង្គការមួយ ឬស្ថាប័នមួយដែលទទួលបន្ទុកអនុវត្តនូវវិធាននៃរបបសន្តិសុខសង្គម។ ចំណែកអង្គការពលកម្មអន្តរជាតិឆ្នាំ ១៩៨៤ បានផ្តល់និយមន័យរបបសន្តិសុខសង្គមថា ជាការការពារមួយដែលសង្គមត្រូវផ្តល់ឲ្យសមាជិករបស់ខ្លួនតាមរយៈវិធានការសាធារណៈ ដើម្បីប្រឆាំងទៅនឹងវិបត្តិសេដ្ឋកិច្ច និងវិបត្តិសង្គម ដែលបង្កឡើងដោយការធ្លាក់ចុះ ឬបាត់បង់នៃប្រាក់ចំណូលដែលបណ្តាលមកពី ជំងឺ មាតុភាព គ្រោះថ្នាក់ការងារ ទុព្វលភាព និងមរណភាព ព្រមទាំងផ្តល់នូវការថែទាំផ្នែកវេជ្ជសាស្ត្រ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារដែលមានកូន។

### កថាខណ្ឌទី១ ៖ ប្រវត្តិនៃរបបសន្តិសុខសង្គម

របបសន្តិសុខសង្គម បានចាប់កំណើតឡើងនៅពេលដែលសង្គមមនុស្សត្រូវទទួលរងហានិភ័យនានា ដោយសារការគំរាមកំហែងផ្នែកសេដ្ឋកិច្ចនិងព្រឹត្តិការណ៍ទាំងឡាយ ដែលចាំបាច់ឲ្យមនុស្សរិះរកវិធានការដើម្បីដោះស្រាយ និងកាត់បន្ថយនូវហានិភ័យនោះ។ ដំណាក់កាលដំបូងនៃរបបសន្តិសុខសង្គមពាក្យថា សន្តិសុខសង្គម ត្រូវបានបង្កើតជាច្បាប់មុនដំបូងគេលើពិភពលោកនៅសហរដ្ឋអាមេរិក នៅឆ្នាំ១៩៣៥ ដែលមានឈ្មោះថា ច្បាប់របបសន្តិសុខសង្គម។ ប៉ុន្តែវាមិនមែនមានន័យថា ច្បាប់នេះជាចំណុចនៃរបបសន្តិសុខសង្គមអន្តរជាតិនោះទេ។ នៅឆ្នាំ១៦០២ នៅដំណាក់កាលរីកលូតលាស់នៃលទ្ធិសង្គមនិយមនៅអង់គ្លេសបានបង្កើត ច្បាប់ស្តីពីភាពក្រីក្រ ក្រោយមកបានធ្វើវិសោធនកម្មនៅឆ្នាំ ១៨៣៥ មានឈ្មោះថា ច្បាប់ស្តីពីភាពក្រីក្រថ្មី។

បើក្រឡេកមកប្រទេសជប៉ុនវិញ បន្ទាប់ពីឆ្លងកាត់រយៈកាលជាច្រើនឆ្នាំក្រោយមក ចាប់ដើមសតវត្សទី២០ ដល់ក្រោយសង្គ្រាមលោកលើកទី២ ស្របពេលជាមួយនឹងការវិវត្តនៃការយល់ដឹងទូទៅ ចំពោះការទទួលខុសត្រូវលើភាពក្រីក្រ វាមិនគួរស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បុគ្គលឯកជនទេ។ តែវាគឺជាការទទួលខុសត្រូវរបស់សង្គមទាំងមូល ពោលគឺដោយសារតែភាពក្រីក្ររបស់បុគ្គលម្នាក់ៗ ឆ្លុះបញ្ចាំងពីភាពក្រីក្ររបស់សង្គមតែម្តង។ ដូច្នេះហើយ គោលគំនិតនៃការធានាកម្រិតស្តង់ដាជីវភាពទាបរបស់ប្រជាពលរដ្ឋទូទាំងប្រទេសនោះ មានភាពរីកចម្រើនឡើងគួរឲ្យកត់សម្គាល់។ ស្របពេលនោះ ប្រព័ន្ធធានារ៉ាប់រងសង្គមគ្រប់ប្រភេទ ក៏ត្រូវបានរៀបចំឡើងសម្រាប់ធានាដល់ជីវភាពរបស់ប្រជាជនដែរ។ តួយ៉ាងប្រព័ន្ធជួយសង្គ្រោះភាពក្រីក្រជាសាធារណៈ ជាប្រព័ន្ធមួយដែលធ្វើការប្រឆាំងនឹងការទម្លាក់សិទ្ធិប្រជាពលរដ្ឋ ពោលគឺដើម្បីមកទទួលស្គាល់សិទ្ធិជាមូលដ្ឋានរបស់

ប្រជាពលរដ្ឋវិញ ដែលវាបានធ្វើឲ្យមានការប្រែប្រួលលើសារធាតុរបស់ប្រព័ន្ធជួយសង្គ្រោះជាសាធារណៈ ដែលមានលក្ខណៈទំនើប។ ម៉្យាងទៀតការធានារ៉ាប់រងកម្មករនិយោជិត បានពង្រីកដែនអនុវត្តរបស់ខ្លួន ព្រមទាំងបានវិវត្តខ្លួនឯងទៅជារបបធានារ៉ាប់រងសង្គមដែលបានគ្រប់គ្រង ឬជួយដល់ប្រជាពលរដ្ឋទូទៅ វាមានលក្ខណៈដូចគ្នាទៅនឹងការជួយសង្គ្រោះជាសាធារណៈដែរ។ ការវិនិច្ឆ័យទៅលើភាពទាក់ទងគ្នារវាង វិភាគទាន និងតាវកាលិក ក៏ត្រូវបានវិវត្តទៅជាកម្រិតស្ដួចស្ដើងមួយជាក់លាក់ ហើយទ្រឹស្ដីនៃការជួយសង្គ្រោះក៏ត្រូវបានលេចឡើងនៅភាពប្រសើរជាងមុនដែរ។

ហេតុនេះហើយ ចំពោះភាពខុសគ្នានៃជនដែលត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងអត្ថន័យនៃប្រព័ន្ធទាំងនេះ ព្រមទាំងការច្របាច់បញ្ចូលគ្នារវាង ការធានារ៉ាប់រងសង្គម និងការជួយសង្គ្រោះជាសាធារណៈ ដែលចេញពីការវិវត្តភាពខុសគ្នានេះ ពាក្យថា របបសន្តិសុខសង្គម ក៏បានកើតឡើង។ តួយ៉ាង ការបោះពុម្ពផ្សាយសៀវភៅនៅឆ្នាំ ១៩៥២ របស់អង្គការពលកម្មអន្តរជាតិ ដែលមានចំណងជើងថា ដំណើរឆ្ពោះទៅកាន់របបសន្តិសុខសង្គម។ លើសពីនេះទៀត ការប្រែប្រួលចាប់ពីដើមសតវត្សទី២០ ដល់ក្រោយសង្គ្រាមលោកលើកទី២មក ពាក្យថា របបសន្តិសុខសង្គម ក៏មានការជ្រួតជ្រាបបន្តិចម្ដងៗ និងបានដឹងឮដល់មនុស្សទូទៅផងដែរ។

តើមូលហេតុចម្បងអ្វីខ្លះ ដែលបង្កើតឲ្យមាន របបសន្តិសុខសង្គម?

មានហេតុផលមួយចំនួន ដែលបង្កើតឲ្យមានរបបសន្តិសុខសង្គម។ **ទីមួយៈ** មនុស្សត្រូវការការការពារនៅពេលដែលខ្លួនអាចជួបប្រទះនឹងបញ្ហាដែលមិនបានគិតទុកជាមុនដូចជា ការបាត់បង់ ឬចុះថយនូវសមត្ថភាពបង្កើនផល និងការរើសអើងដែលអាចប៉ះពាល់ដល់ជីវភាពគ្រួសាររបស់ពួកគេ។ ដូច្នេះ ពួកគេត្រូវការប្រព័ន្ធមួយដែលអាចការពារខ្លួនពីហានិភ័យ និងអស្ថិរភាពសង្គមនេះ។ ផលប្រយោជន៍នៃរបបសន្តិសុខសង្គមនេះ ជាកម្លាំងចលករមួយប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងភាពមិនស្មើភាពគ្នា និងធ្វើឲ្យមានការអភិវឌ្ឍផ្នែកសង្គម និងសេដ្ឋកិច្ច។ ហើយវាគឺជាកូនសោរក៏សំខាន់ដើម្បីសម្រេចបានដល់គោលដៅអភិវឌ្ឍសហសវត្ស។ **ទីពីរៈ** វាជាសិទ្ធិដែលមនុស្សគ្រប់រូបក្នុងនាមជាសមាជិកសង្គម ត្រូវទទួលបាននូវរបបសន្តិសុខសង្គមនេះ ពោលគឺថា ក្នុងឋានៈជាសមាជិកសង្គមមនុស្សគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិទទួលបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្ដីថ្លៃថ្នូរ និងការរីកចម្រើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួន តាមរយៈការខិតខំរបស់ជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិស្របតាមការរៀបចំ និងធនធានរបស់ប្រទេសនីមួយ។

ចំណែកប្រទេសកម្ពុជា ដោយសារតែកម្ពុជាធ្លាប់ឆ្លងកាត់នូវរបបនយោបាយជាច្រើន ការបង្កើតច្បាប់សម្រាប់អនុវត្តនោះ ក៏មានលក្ខណៈខុសគ្នាដែរ។ តែទោះជាយ៉ាងណា ច្បាប់ដែលត្រូវបានបង្កើតសម្រាប់របបនយោបាយនោះ អាចមានឈ្មោះខុសគ្នា តែមានមុខងារដូចគ្នា ឬក៏ស្រដៀង

គ្នា។ នៅប្រទេសកម្ពុជាកាលពីមុនយើងក៏ធ្លាប់មានជាច្បាប់ ឬបទដ្ឋានគតិយុត្តទាក់ទងនឹងរបបសន្តិសុខសង្គមដែរ នៅឆ្នាំ១៩៥៥។ ប៉ុន្តែកាលនោះគឺជាអំឡុងពេលដែលប្រទេសកម្ពុជា ទើបតែរួចផុតពីអាណានិគមរបស់បារាំង ហើយច្បាប់ក៏ដូចជាបទដ្ឋានគតិយុត្តទាក់ទងនឹងរបបសន្តិសុខសង្គមនេះមានដូចជា ព្រះរាជក្រឹត្យលេខ៥៥ និងលេខ៣០៦។ ក្រោយមកនាអំឡុងឆ្នាំ ១៩៧៥-១៩៧៩ របបសន្តិសុខសង្គម ក៏ត្រូវបានរលាយទៅវិញ ហើយយើងក៏មិនដឹងច្បាស់លាស់ពីអត្ថន័យនៃព្រះរាជក្រឹត្យទាំងនេះដែរ ដោយសារវាបានឆ្លងកាត់នូវរបបនយោបាយជាច្រើន ពិសេសរាល់បទដ្ឋានគតិយុត្តគ្រប់យ៉ាងក្នុងរបបប៉ុល ពត ស្ទើតែរលាយបាត់អស់ទៅហើយ។

## កថាខណ្ឌទី២ ៖ កិច្ចដំណើរការប្រព័ន្ធសន្តិសុខសង្គមក្នុងវិស័យសាធារណៈ

ប្រព័ន្ធសន្តិសុខសង្គម ជាប្រព័ន្ធសម្រាប់គ្រប់គ្រងកម្មវិធីសន្តិសុខសង្គម ដែលរួមបញ្ចូលកម្មវិធីដែលរៀបចំឡើងដើម្បីជួយដល់ប្រជាជន ក្នុងការការពារពួកគាត់ពីការធ្លាក់ចុះភ្លាមៗនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺ លំហែមាតុភាព គ្រោះថ្នាក់ការងារ និកម្មភាព ទុព្វលភាព ជរាភាព (ឬចូលនិវត្តន៍) និងមរណភាពនៃអ្នកដែលរកចំណូលសម្រាប់គ្រួសារ។ របបសន្តិសុខសង្គមតម្រូវឲ្យសមាជិកនិងឬភាគីពាក់ព័ន្ធបង់ភាគទានជាកាតព្វកិច្ចទៅតាមអត្រាជាក់លាក់។ ប្រព័ន្ធសន្តិសុខសង្គមនៅក្នុងប្រទេសកម្ពុជាមានធាតុផ្សំ ៥ គឺ សោធន ថៃទាំសុខភាព ហានិភ័យការងារ និកម្មភាព និងពិការភាព។ ប្រព័ន្ធសន្តិសុខសង្គម នឹងជំរុញឲ្យប្រជាជនគ្រប់រូបចូលរួមសន្សំប្រាក់ (បង់ភាគទាន) នៅក្នុងមូលនិធិរួមមួយ ដើម្បីការពារហានិភ័យពីការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចាស់ជរា និងនៅពេលមានតម្រូវការសេវាថៃទាំសុខភាព ព្រមទាំងហានិភ័យផ្សេងៗទៀត។ បច្ចុប្បន្នមន្ត្រីសាធារណៈទទួលបានការគាំពារនៅពេលចូលនិវត្តន៍ និងពេលបាត់បង់សមត្ថភាពការងារពីបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន។ លើសពីនេះទៀតរាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឲ្យបេឡាជាតិរបបសន្តិសុខសង្គម ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថៃទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយអនុលោមតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថៃទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថៃទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដើម្បីធានាឲ្យមានសង្គតិភាព ក្នុងការគាំពារសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារក្នុងវិស័យឯកជន និងមន្ត្រីរាជការក្នុងវិស័យសាធារណៈ។

## ផ្នែកទី២ ៖ ស្ថាប័នប្រតិបត្តិករនៃប្រព័ន្ធសន្តិសុខសង្គម

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធិផលជាច្រើន និងអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយជោគជ័យជាបន្តបន្ទាប់ លើប្រព័ន្ធសន្តិសុខសង្គម គឺការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមមួយចំនួនរួមមាន៖ បេឡាជាតិរបបសន្តិសុខសង្គម បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងបេឡាជាតិអតីតយុទ្ធជន។ ស្ថាប័នទាំងនេះ មានគោលដៅផ្តល់ការគាំពារសន្តិសុខប្រាក់ចំណូលដែលអាចបណ្តាលមកពីការឈឺថ្កាត់ គ្រោះថ្នាក់ការងារ មាតុភាព និងចាស់ជរា ជាដើម សម្រាប់ក្រុមគោលដៅមួយចំនួនដូចជា មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

### កថាខណ្ឌទី១ ៖ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

សន្តិសុខសង្គមត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ យោងតាមព្រះរាជក្រឹត្យលេខ៥៥ និង៣០៦។ តែគួរឲ្យសោកស្តាយកំឡុងពេលរបបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៩) សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះទទួលខុសត្រូវការរៀបចំទាំងអស់នៃប្រកាសសម្រាប់ ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជន ដែលធ្វើការក្នុងវិស័យឯកជន។ជាលទ្ធផលការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារឆ្នាំ១៩៩២ដែលជាច្បាប់ការងារកម្ពុជា បច្ចុប្បន្នដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ (ថ្មីៗនេះប្តូរទៅជាអគ្គនាយកដ្ឋានការងារ)។ បន្ទាប់ពីនោះមក ច្បាប់សន្តិសុខសង្គម ត្រូវបានអនុម័តដោយសភានៅខែកញ្ញា ឆ្នាំ២០០២ ដែលថ្មីៗត្រូវបានគេស្គាល់ថា ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ អនុក្រឹត្យស្តីពីការបង្កើត ប.ស.ស ត្រូវបានអនុម័ត នៅឆ្នាំ២០០៧ ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ ប.ស.ស ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារ សន្តិសុខសង្គមឲ្យស្របទៅតាមច្បាប់សន្តិសុខសង្គមជាតិ និងបទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាមអនុក្រឹត្យ។ ក្រោយពីការរៀបចំដ៏ធំទូលាយនេះ ប.ស.ស ត្រូវបានដំណើរការនៅចុងឆ្នាំ២០០៨ ។

អនុលោមតាមច្បាប់ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ស្ថានភាពរីកចំរើននៃសេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មក្នុងតំបន់ ប.ស.ស បាននិងកំពុងត្រៀមខ្លួនតាមរយៈការរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដោយបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំនេះឡើង ដែលមានចក្ខុវិស័យនិងបេសកកម្មដ៏ច្បាស់លាស់ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឲ្យទទួលបាននូវសេវាសន្តិសុខសង្គម

នៅពេលដែលពួកគាត់ជួបប្រទះនូវយថាភាពផ្សេងៗ មានជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និងមាតុភាពជាដើម។

ក្នុងស្ថានភាពដែលប្រទេសកម្ពុជាមានការរីកចំរើនលើគ្រប់វិស័យ ការធានាផ្នែកសន្តិសុខសង្គម មានសារៈសំខាន់ខ្លាំងណាស់ ដោយបានផ្តល់នូវការគាំពារចំពោះប្រជាជនកម្ពុជា និយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែក រំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គម ធានាបាននូវសន្តិសុខ ប្រាក់ចំណូល ពោលគឺមានន័យថា តាមរយៈការធានាផ្នែកសន្តិសុខសង្គម គ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រ ដោយមិនអាចងើបរួចបានឡើយ។ ម្យ៉ាងទៀត គោលនយោបាយសន្តិសុខសង្គម ក៏រួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលការណ៍នៃការចែករំលែកប្រាក់ចំណូល តាមខ្សែទទឹង និងខ្សែបណ្តោយ គឺមានន័យថា អ្នកមានប្រាក់ចំណូលខ្ពស់ជួយដល់អ្នកមានប្រាក់ចំណូលទាប អ្នកមានសុខភាពល្អ ជួយដល់អ្នកមានជំងឺ ជនពិការ ឬ អ្នកដែលទទួលរងនូវគ្រោះថ្នាក់ផ្សេងៗ ជនមានវ័យក្មេងជួយដល់ជនចាស់ជរា ដែលការនេះធ្វើឲ្យមនុស្សក្នុងសង្គមទាំងមូល ទទួលបាននូវភាពកក់ក្តៅក្នុងជីវភាពរស់នៅ ធានារក្សាបានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ដោយការធានាឲ្យបាននូវសន្តិសុខប្រាក់ចំណូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម ប.ស.ស បានអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនគ្រោងអនុវត្តនៅពេលឆាប់ៗខាងមុខនេះ។ ឈរលើការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពប្រកបដោយជោគជ័យ និងធានាឲ្យមានភាពសង្គតិភាពក្នុងការគាំពារសង្គមទាំងវិស័យឯកជន និងមន្ត្រីរាជការ ក្នុងវិស័យសាធារណៈ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឲ្យ ប.ស.ស ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនចាប់ពីឆ្នាំ២០១៧តទៅ។

**គ.ស្ថានភាពទូទៅ**

**១.ការបង្កើត ប.ស.ស**

ប.ស.ស គឺជានីតិបុគ្គលសាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ហើយត្រូវស្ថិតនៅក្រោមអនុភាពនៃអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ

នៃច្បាប់ស្តីពីការងារ។ ប.ស.ស គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល[1] ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម ហើយត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.ភារកិច្ចរបស់ ប.ស.ស.**

បេឡាជាតិរបបសន្តិសុខសង្គមមានភារកិច្ច[2]ដូចខាងក្រោម៖

- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ
- ធានាឲ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃប.ស.ស ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេលជរាភាពទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះជាយថាហេតុផ្សេងៗទៀតដូចជាជំងឺ មាតុភាពជាដើម
- ប្រមូលភាគទានពីសមាជិកនៃប.ស.ស និងនិយោជក
- សម្របសម្រួលនិងរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីៈ អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ព្រមទាំងចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខនិងអនាម័យការងារ
- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវនិងអង្កេតហានិភ័យការងារ
- ចាត់ចែងនិងការគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

**ខ.រដ្ឋបាល ប.ស.ស**

**១.ក្រុមប្រឹក្សាភិបាល**

ប.ស.ស ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពី ការបង្កើត ប.ស.ស និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស។ ក្រុមប្រឹក្សាភិបាលរបស់ ប.ស.ស មានសមាសភាពត្រីភាគី មានសមាជិក០៩រូប[3]៖

- តំណាងរាជរដ្ឋាភិបាល ០៥រូប
  - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ០១រូប ប្រធាន

[1] មាត្រា ១ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
[2] មាត្រា ៣ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
[3] មាត្រា ៤ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប សមាជិក
- តំណាងក្រសួងសុខាភិបាល ០១រូប សមាជិក
- នាយកនៃបេឡាជាតិរបបសន្តិសុខសង្គម ០១រូប សមាជិកស្វ័យប្រវត្តិ

• តំណាងនិយោជក ០២រូប សមាជិក
• តំណាងកម្មករនិយោជិត ០២រូប សមាជិក

ក្រុមប្រឹក្សាភិបាលនៃប.ស.ស មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃប.ស.ស ហើយក្រុមប្រឹក្សាភិបាលនេះមានភារកិច្ច[4]ដូចតទៅ៖

- អនុម័តថវិកាប្រចាំឆ្នាំរបស់ ប.ស.ស ជាពិសេសសម្រាប់តារាវកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច
- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ ប.ស.ស
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃប.ស.ស
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ ប.ស.ស
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ ប.ស.ស
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ ប.ស.ស
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ ប.ស.ស
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ ប.ស.ស
- វាយតម្លៃនូវលទ្ធផលការងារនៃ ប.ស.ស និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាភិបាលបច្ចេកទេសនៃ ប.ស.ស សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឲ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិន

[4] មាត្រា ៥ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

ដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។ តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬសេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។ ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលសមាជិកនោះតំណាងឲ្យ។

សមាជិកក្រុមប្រឹក្សាភិបាលនៃ ប.ស.ស ត្រូវបាត់បង់សមាជិកភាព[5]របស់ខ្លួន ក្នុងករណីដូចខាងក្រោម៖

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬមានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ ប.ស.ស ឬ បម្រើសេវាកម្មណាមួយឲ្យ ប.ស.ស ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល។

**២.អង្គការប្រតិបត្តិនៃ ប.ស.ស**

នាយកនៃប.ស.ស ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកនៃ ប.ស.ស មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ ប.ស.ស។ នាយកនៃ ប.ស.ស ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានតាមច្បាប់ និងជាតំណាងនៃប.ស.ស ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឲ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស។ ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃ ប.ស.ស មានភារកិច្ច[6]សំខាន់ៗដូចតទៅ៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច

---

[5] មាត្រា ១០ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[6] មាត្រា ១២ អនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ ប.ស.ស
- ទទួលបន្ទុកដឹកនាំ ប.ស.ស ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ស.ស ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបរបស់ ប.ស.ស ដោយគោរពតាមលក្ខន្តិកៈ ឬច្បាប់ជាធរមាន និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើសតែងតាំងដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិករបស់ ប.ស.ស ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់មន្ត្រីរាជការនៃប.ស.ស ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ ប.ស.ស ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ ប.ស.ស និងទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ ប.ស.ស។

នាយកនៃ ប.ស.ស មានសិទ្ធិផ្ទេរអំណាចខ្លះ ឬទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលក្នុងបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល។

**៣.បុគ្គលិករបស់ ប.ស.ស**

បុគ្គលិកអចិន្ត្រៃយ៍របស់ ប.ស.ស រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃប.ស.ស។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវបៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។ ប.ស.ស អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ ប.ស.ស និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។ បុគ្គលិកនៃ ប.ស.ស ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

គណៈនេយ្យករនៃ ប.ស.ស ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណៈនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃ ប.ស.ស។

**កថាខណ្ឌទី២ ៖ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល** (ប.ជ.ស.)

របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានបង្កើតឡើងតាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៥០ មកម្លេះ។ របបសន្តិសុខសង្គមនេះ ត្រូវបានបាត់បង់ទៅវិញក្នុងសម័យប៉ុលពត ។ បន្ទាប់ពីថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ ក្រោយពេលដែលរដ្ឋាភិបាលបានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធក្រសួង ស្ថាប័ន និងជ្រើសរើសកម្មាភិបាល បុគ្គលិក កម្មកររដ្ឋឲ្យចូលបម្រើការងារ របបសន្តិសុខសង្គមក៏ត្រូវបានរៀបចំបង្កើតឡើងវិញជាជំហានៗផងដែរ ផ្អែកទៅតាមស្ថានភាពសេដ្ឋកិច្ច និងសង្គម ។

នៅក្នុងឆ្នាំ១៩៨៣ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចលេខ០១ សសរ. ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៨៣ ស្តីពីគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលសេចក្តីសម្រេចនេះ ចែងអំពីរបបសន្តិសុខសង្គមឧបត្ថម្ភចំពោះ កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ក្នុងករណីមានជំងឺ គ្រោះថ្នាក់ការងារ សម្រាលកូន មរណភាព និងជួបការលំបាកខ្លាំង ។ លុះមកដល់ឆ្នាំ១៩៨៥ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានចេញសេចក្តីសម្រេចលេខ១៥០ សសរ. ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម(បាត់បង់សម្បទាវិជ្ជាជីវៈ) សម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ។

នៅឆ្នាំ១៩៨៨ ក្រុមប្រឹក្សារដ្ឋមន្ត្រីបានធ្វើការកែសម្រួលលើខ្លឹមសារគោលនយោបាយធានារ៉ាប់រងសង្គមមួយចំនួន និងបានចេញសេចក្តីសម្រេចលេខ២៤៥ សសរ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ១៩៨៨ ស្តីពីគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម។ បន្ទាប់មក ក្រុមប្រឹក្សារដ្ឋមន្ត្រីក៏បានធ្វើការកែសម្រួលលើខ្លឹមសារគោលនយោបាយសោធន ដើម្បីឲ្យស្របទៅតាមការវិវត្តន៍នៃស្ថានភាពសេដ្ឋកិច្ច និងសង្គម ដោយចេញសេចក្តីសម្រេចលេខ១៨៤ សសរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩០ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ។

ដើម្បីពង្រឹងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ឲ្យស្របតាមព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាមូលដ្ឋានក្នុងការអនុវត្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។

អនុវត្តតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ត្រង់ចតុកោណទី៣ មុំទី៤ ស្តីពីការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានផ្តួចផ្តើមបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្នុងគោលដៅដើម្បីដាក់ឲ្យដំណើរការគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ឲ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការលំបាករបស់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ស្របតាមស្មារតី និងខ្លឹមសារដែលមានចែងក្នុងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ តាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព មានប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។

ប.ជ.ស. ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៤ អនក្រ.បក ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ។

ប.ជ.ស. គឺជាស្ថាប័នមួយដែលមានតួនាទីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍និងកែទម្រង់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាពិសេសគឺសិក្សាលើលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកបន្ថែមទៀត ដើម្បីឲ្យស្របទៅតាមបរិបទនៃវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម ។ ប.ជ.ស. ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកាតព្វកិច្ចគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គម ដែលមានតាវកាលិកចំនួន០៦ គឺការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក ។

**ក.ស្ថានភាពទូទៅ**

**១.ការបង្កើត ប.ជ.ស.**

ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ រាជរដ្ឋាភិបាលបានបង្កើត បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលតាមរយៈអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្របតាម ខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

ប.ជ.ស. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល[7] ដើម្បីដាក់ឲ្យដំណើរការ គ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ឲ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការលំបាករបស់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។ ប.ជ.ស. គឺជានីតិបុគ្គលនៃច្បាប់សាធារណៈ ដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប.ជ.ស. មានវិសាលភាពគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលមានស្ថានភាពចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និងមរណភាព និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ។ ប.ជ.ស. មានកាតព្វកិច្ចគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គម ជូនមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ក្នុងករណីចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ និងមរណភាព និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ។

**២.ចក្ខុវិស័យ**

ធានាចំពោះមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ ឲ្យទទួលបាននូវអត្ថប្រយោជន៍នានា ដែលជាតម្រូវការមូលដ្ឋាន និងលើកកម្ពស់សុខុមាលភាពសង្គមរបស់អ្នកទាំងនេះ តាមរយៈការផ្តល់របបសន្តិសុខសង្គមប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

**៣.បេសកកម្ម**

- ចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- គ្រប់គ្រងមូលនិធិ ប.ជ.ស. តាមគោលការណ៍អភិបាលកិច្ចល្អ
- សិក្សាស្រាវជ្រាវ និងធ្វើផែនការដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឲ្យស្រប តាមស្ថានភាពសេដ្ឋកិច្ច និងសង្គម
- ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិសម្រាប់ ប.ជ.ស.
- ទទួលខុសត្រូវ និងធានាការបើកផ្តល់នូវតាវកាលិកទាំងឡាយសម្រាប់សមាជិក ប.ជ.ស.
- ត្រួតពិនិត្យ និងវាយតម្លៃការចំណាយតាវកាលិក
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិ នៃ ប.ជ.ស.
- សម្របសម្រួល និងរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន ។

[7] មាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

## ខ.ក្រុមប្រឹក្សាភិបាល

### ១.ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលគឺជាអង្គនីតិប្បញ្ញត្តិនៃ ប.ជ.ស. ដែលមានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅរបស់ ប.ជ.ស.។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ច[8]ដូចតទៅ៖

- ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ជ.ស.
- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ ប.ជ.ស.
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ ប.ជ.ស.
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះ ប.ជ.ស.
- ពិនិត្យ និងកំណត់លើបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការតែងតាំង ការតម្លើងឋានៈ ការដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិក ប.ជ.ស. ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាពិនិត្យ និងសម្រេច
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាត សម្រាប់ ប.ជ.ស.
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ ប.ជ.ស.
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ ប.ជ.ស.
- វាយតម្លៃលទ្ធផលការងារនៃ ប.ជ.ស. និងលើកវិធានការកែលម្អអនុវត្ត
- ពិនិត្យ និងលើកសំណើក្នុងការកំណត់អត្រាភាគទាន តាវកាលិក និងប្រភេទនៃរបបសន្តិសុខសង្គម តាមរយៈរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- សិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឲ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

### ២.សមាភាពក្រុមប្រឹក្សាភិបាល

ប.ជ.ស. ដឹកនាំ និងគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាព[9]ដូចខាងក្រោម៖

- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១ រូប ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប សមាជិក

[8] មាត្រា ៦ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
[9] មាត្រា ៥ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- តំណាងក្រសួងសុខាភិបាល ១ រូប សមាជិក
- តំណាងក្រសួងយុត្តិធម៌ ១ រូប សមាជិក
- តំណាងក្រសួងមហាផ្ទៃ ១ រូប សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា ១ រូប សមាជិក
- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ១ រូប សមាជិក
- តំណាងមន្ត្រីរាជការស៊ីវិល ១ រូប សមាជិក
- តំណាងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ១ រូប សមាជិក
- នាយក ប.ជ.ស. ១ រូប សមាជិកស្វ័យប្រវត្តិ

**គ.អង្គការប្រតិបត្តិនៃ ប.ជ.ស.**

**១.ភារកិច្ចរបស់ ប.ជ.ស.**

ប.ជ.ស. មានតួនាទីជាអ្នកបម្រើសេវារបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ស្របតាមស្មារតី និងខ្លឹមសារ ដែលមានចែងក្នុងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ។ ប.ជ.ស. មានភារកិច្ចដាក់ឲ្យដំណើរការ គ្រប់គ្រង និងធានាការបើកផ្តល់តាវកាលិកជូន មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក តាមគោលការណ៍អភិបាលកិច្ចល្អមានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ ប.ជ.ស. មានភារកិច្ចដូចខាងក្រោម[10]៖

- ចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- គ្រប់គ្រងមូលនិធិ ប.ជ.ស. តាមគោលការណ៍អភិបាលកិច្ចល្អ
- ត្រួតពិនិត្យ និងវាយតម្លៃការចំណាយតាវកាលិក
- ស្រាវជ្រាវ និងរៀបចំបទប្បញ្ញត្តិសម្រាប់ ប.ជ.ស.
- សិក្សាស្រាវជ្រាវ និងធ្វើផែនការដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឲ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច
- ប្រមូលភាគទានពីសមាជិក ទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាល និងទទួលជំនួយមនុស្សធម៌ពីប្រភពផ្សេងៗទៀត
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិនៃ ប.ជ.ស.
- ទទួលខុសត្រូវ និងធានាការបើកផ្តល់នូវតាវកាលិកទាំងឡាយ សម្រាប់សមាជិក ប.ជ.ស.

[10] មាត្រា ៩ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- សម្របសម្រួល និងរៀបចំឲ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

**២.នាយក ប.ជ.ស.**

នាយក ប.ជ.ស. ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយក ប.ជ.ស. មានភារកិច្ចចាត់ចែង និងគ្រប់គ្រងការងារជាប្រក្រតីរបស់ ប.ជ.ស.។ នាយក ប.ជ.ស. ត្រូវបានទទួលអំណាចចាំបាច់ សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញ ក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាង ប.ជ.ស. ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឲ្យ តាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ ប.ជ.ស. និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ជ.ស. ។ ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយក ប.ជ.ស. មានភារកិច្ច[11]សំខាន់ៗ ដូចតទៅៈ

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ ប.ជ.ស.
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងរាយការណ៍តាមដំណាក់កាលនីមួយៗ ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាព និងលទ្ធផលការងាររបស់ ប.ជ.ស.
- ទទួលបន្ទុកគ្រប់គ្រង និងដឹកនាំ ប.ជ.ស. ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ជ.ស. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងសម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបរបស់ ប.ជ.ស. ស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬកំណត់ដោយក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំងតម្លើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិកនៃ ប.ជ.ស. ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា ពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង តម្លើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់បុគ្គលិកនៃ ប.ជ.ស. ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមន្ត្រីរាជការស៊ីវិល តាមរយៈក្រុមប្រឹក្សាភិបាល
- ធ្វើជាតំណាងនៃ ប.ជ.ស. ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិរបស់ ប.ជ.ស. និងទទួលខុសត្រូវចំពោះមុខច្បាប់ លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ ប.ជ.ស. ។

[11] មាត្រា ១៣ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

**៣.បុគ្គលិករបស់ ប.ជ.ស.**

បុគ្គលិកអចិន្ត្រៃយ៍របស់ ប.ជ.ស. រួមមានមន្ត្រីរាជការស៊ីវិល ក្នុងក្របខ័ណ្ឌនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងនានា ឬមន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ ប.ជ.ស.។ មន្ត្រីទាំងនេះត្រូវបានទទួលបន្តនូវបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន ដោយអនុលោមតាមបទបញ្ញាទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការ និងអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។ ប.ជ.ស. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះត្រូវស្ថិតនៅក្រោមបទញ្ញត្តិនៃបទបញ្ញាផ្ទៃក្នុងរបស់ ប.ជ.ស. និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ។ បុគ្គលិកនៃ ប.ជ.ស. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ញាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ ដូចមានចែងនៅក្នុងបទបញ្ញាផ្ទៃក្នុង។

គណនេយ្យករនៃ ប.ជ.ស. ត្រូវតែងតាំងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការឯកភាពគ្នា ជាមួយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់ របស់នាយកនៃ ប.ជ.ស.។

**កថាខណ្ឌទី៣ ៖ បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.)**

របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ត្រូវបានបង្កើតឡើងនៅក្នុងទសវត្សទី៦០ ដែលមានឈ្មោះថា បេឡាសោធនទាហាន ដោយព្រះរាជក្រមលេខ៣៧៩ នស ចុះថ្ងៃទី១៦ខែកុម្ភៈ ឆ្នាំ១៩៦០ ហើយច្បាប់នេះ ត្រូវបានធ្វើវិសោធនកម្មលើមាត្រាមួយចំនួននៅក្នុងឆ្នាំ១៩៦៥ ដោយព្រះរាជក្រមលេខ២៥៣ បរ.ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦៥។ នៅក្នុងសម័យកាលនោះ ប្រភពធនធានសម្រាប់ទ្រទ្រង់ដំណើរការបេឡាសោធនទាហានបានមកពី ៖

- ប្រាក់កាត់ទុកចំនួន៦% លើចំនួនបៀវត្សទាហាន
- វិភាគទានថវិការបស់រាជរដ្ឋាភិបាលចំនួន១៤% លើបៀវត្សប្រចាំបណ្តាស័ក្តិ
- ការប្រាក់ដែលបេឡាចងការ
- អំណោយ និងអច្ច័យទាន។

ចំពោះបេឡាសោធនទាហាននាពេលនោះមិនបានគ្របដណ្តប់លើតារាកាលិករបបសន្តិសុខសង្គមទូលំទូលាយ ដូចបច្ចុប្បន្ននេះទេការផ្តល់នៅពេលនោះគឺផ្តោតតែលើសោធននិវត្តន៍តែមួយមុខ ប៉ុណ្ណោះ។ បេឡាសោធនទាហាន ត្រូវបានបាត់បង់នៅសម័យ ប៉ុល ពត។ លុះមកដល់ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលនាពេលនោះ បានរៀបចំជាបណ្តើរៗឲ្យមាន របបសន្តិសុខ

សង្គមសម្រាប់អតីតយុទ្ធជន ដែលគ្របដណ្តប់លើតារកាលិកច្រើនប្រភេទដូចជា ៖ ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈ ពិការភាព ជំងឺ និង អ្នកនៅក្នុងបន្ទុក។ ចំពោះប្រភពធនធានសម្រាប់ទ្រទ្រង់ដំណើរការរបបសន្តិសុខសង្គមគឺទទួលបាន ការផ្តត់ផ្គង់ទាំងស្រុងដោយថវិកាជាតិចំពោះរបបឧបត្ថម្ភជូនមុខសញ្ញានេះទៀតសោត គឺមានការ ប្រែប្រួល ដោយអាស្រ័យទៅលើវឌ្ឍនភាពនៃសេដ្ឋកិច្ច និងសង្គម។ ខាងក្រោមនេះគឺជាប្រវត្តិ សង្ខេបនៃក្រសួងដែលគ្រប់គ្រង របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៖

- ក្រសួងយុទ្ធជនពិការ សង្គមកិច្ច ចាប់ពីខែតុលា ឆ្នាំ១៩៨៥ ដល់ឆ្នាំ១៩៩២
- ក្រសួងការងារ សង្គមកិច្ច ពីឆ្នាំ១៩៩២ ដល់ខែកក្កដា ឆ្នាំ១៩៩៣
- ក្រសួងអតីតយុទ្ធជន ពីខែសីហា ឆ្នាំ១៩៩៣ ដល់ខែតុលា ឆ្នាំ១៩៩៣
- ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ពីខែវិច្ឆិកា ឆ្នាំ១៩៩៣ ដល់ខែវិច្ឆិកា ឆ្នាំ១៩៩៨
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ពីខែធ្នូ ឆ្នាំ១៩៩៨ ដល់ខែកក្កដា ឆ្នាំ២០០៤
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពីខែសីហា ឆ្នាំ២០០៤ ដល់ឆ្នាំ២០១០
- បេឡាជាតិអតីតយុទ្ធជនពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ន

ចំពោះក្រសួងដែលគ្រប់គ្រងរបបសន្តិសុខសង្គមដូចបានរៀបរាប់ខាងលើនេះ គឺគ្របដណ្តប់ តែលើអតីតយុទ្ធជន ដែលជាយោធិននៃកងយោធពលខេមរភូមិន្ទនិងគ្រួសារអតីតយុទ្ធជនតែ ប៉ុណ្ណោះ។ ដោយឡែករបបសន្តិសុខសង្គមមន្ត្រីនគរបាលជាតិ ទើបតែធ្វើសមាហរណកម្មទាំងស្រុង មកនៅក្រោមការគ្រប់គ្រងរបស់បេឡាជាតិអតីតយុទ្ធជននៅឆ្នាំ២០១០ ដែលពីមុនមករបបសោធន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ។

**ក.ស្ថានភាពទូទៅ**

**១.ការបង្កើតបេឡាជាតិអតីតយុទ្ធជន**

ដោយអនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ រាជរដ្ឋាភិបាល បានបង្កើតបេឡាជាតិអតីតយុទ្ធជនតាមរយៈអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្របតាម ខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។ បេឡាជាតិអតីតយុទ្ធជន សរសេរកាត់ ថា **ប.ជ.អ.** គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល[12] សម្រាប់ដាក់ឲ្យដំណើរការគ្រប់គ្រង និងធានាការ បើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជននៃកងយោធពលខេមរភូមិន្ទ អតីតយុទ្ធជននៃ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ អតីតយុទ្ធជននៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល បុគ្គលិក ជាប់កិច្ចសន្យា

[12] មាត្រា ១ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន

កងជីវពល កងសេនាជន និងប្រជាពលរដ្ឋដែលបានចូលរួមប្រយុទ្ធ ឬបម្រើការងារប្រយុទ្ធ ដើម្បីប្រទេសជាតិ និងគ្រួសារអតីតយុទ្ធជន។ ប.ជ.អ. ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២.ទស្សនៈវិស័យ**

ប.ជ.អ. មានទស្សនវិស័យ ផ្តោតជាសំខាន់លើការលើកកម្ពស់ជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសាររបស់ពួកគាត់ទាំងស្មារតី និងសម្ភារៈ ឲ្យល្អប្រសើរ និងមានស្ថេរភាពស្របតាមវឌ្ឍនភាពនៃសេដ្ឋកិច្ច-សង្គម ។

**៣.បេសកកម្ម**

- អនុវត្តគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលសម្រាប់អតីតយុទ្ធជន
- អនុវត្តយុទ្ធសាស្ត្រជាតិកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុ
- ពង្រឹងនូវសំណាញ់សុវត្ថិភាពសង្គមសម្រាប់អតីតយុទ្ធជន
- គ្រប់គ្រង និងបង្កើនប្រសិទ្ធភាពក្នុងការបើករបបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន តាមគោលការណ៍អភិបាលកិច្ចល្អ តម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវ
- បង្កើនភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ-អន្តរជាតិ បណ្តាប្រទេសនានាក្នុងតំបន់ និងលើពិភពលោក លើវិស័យរបបសន្តិសុខសង្គម
- រៀបចំបទដ្ឋានគតិយុត្តដើម្បីពង្រីក និងពង្រឹងគុណភាពនៃតាវកាលិករបបសន្តិសុខសង្គមជូនអតីតយុទ្ធជន ឲ្យកាន់តែទូលំទូលាយ
- រៀបចំបទដ្ឋានគតិយុត្តកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់ ប.ជ.អ.

**ខ.ក្រុមប្រឹក្សាភិបាល**

**១.ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាលគឺជាអង្គនីតិប្បញ្ញត្តិរបស់ ប.ជ.អ. ដែលមានបេសកកម្មក្នុងការតម្រង់ទិសដៅ និងត្រួតពិនិត្យ ដំណើរប្រព្រឹត្តទៅរបស់ ប.ជ.អ.។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តភារកិច្ច[13] ដូចខាងក្រោម៖

- ពិនិត្យ និងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ ប.ជ.អ. ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល

[13] មាត្រា ៩ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន

- ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់ ប.ជ.អ.
- ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យនិងសម្រេចលើចំណូលចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ ប.ជ.អ.
- ពិនិត្យ និងសម្រេចរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះ ប.ជ.អ.
- ពិនិត្យ និងកំណត់លើបែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរស័ក្តិ ឬផ្តល់លាភការដោយមិនប៉ះពាល់ ដល់បទប្បញ្ញត្តិនៃច្បាប់ ឬបទបញ្ជាពាក់ព័ន្ធដល់ប្រយោជន៍បុគ្គលិករបស់គ្រឹះស្ថាន
- ពិនិត្យ និងលើសេចក្តីស្នើក្នុងការកំណត់អត្រាភាគទាន ការបន្ថែមរបបតាវកាលិក នៃរបបសន្តិសុខសង្គម និងតាវកាលិកផ្សេងៗទៀតសម្រាប់អតីតយុទ្ធជន និងគ្រួសារ អតីតយុទ្ធជនតាមរយៈរដ្ឋមន្ត្រីក្រសួង អាណាព្យាបាល ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- កែសម្រួលបទបញ្ជាផ្ទៃក្នុង ប.ជ.អ. ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬក្រសួងអាណាព្យាបាលទាំងពីរ
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ ប.ជ.អ.
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ ប.ជ.អ.
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ ប.ជ.អ.
- វាយតម្លៃលើលទ្ធផលការងារនៃ ប.ជ.អ. និងលើកវិធានការកែលម្អផែនការអនុវត្ត
- សិក្សាស្រាវជ្រាវ ដើម្បីអភិវឌ្ឍបច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ឲ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

**២.សមាសភាពក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល នៃ ប.ជ.អ. មានសមាជិក ៩រូប ដែលមានសមាសភាព[14]ដូចតទៅៈ

- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងការពារជាតិ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក

[14] មាត្រា ៥ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន

- នាយក ប.ជ.អ. សមាជិក
- តំណាងបុគ្គលិក ប.ជ.អ. សមាជិក

**គ.អង្គភាពប្រតិបត្តិរបស់ ប.ជ.អ.**

**១.ភារកិច្ចរបស់ ប.ជ.អ.**

ប.ជ.អ. ជានីតិបុគ្គល មានស្វ័យភាពហិរញ្ញវត្ថុ និងមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។ ប.ជ.អ. មានភារកិច្ច[15]៖

- ចាត់ចែង និងគ្រប់គ្រងរបបសន្តិសុខសង្គម ជូនអតីតយុទ្ធជន
- គ្រប់គ្រងមូលនិធិ ប.ជ.អ. តាមគោលការណ៍អភិបាលកិច្ចល្អ
- ត្រួតពិនិត្យ និងវាយតម្លៃលើការចំណាយតាវកាលិក
- ស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ ប.ជ.អ.
- សិក្សាស្រាវជ្រាវ និងធ្វើផែនការ ដើម្បីអភិវឌ្ឍបច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឲ្យស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច
- គ្រប់គ្រង និងចាត់ចែងថវិកាដែលទទួលពីរាជរដ្ឋាភិបាល សប្បុរសជន ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិនានា ផលចំណេញពីការវិនិយោគ អាជីវកម្មស្របច្បាប់ និងពីប្រភពផ្សេងៗទៀត
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិនៃ ប.ជ.អ.
- សម្របសម្រួល និងរៀបចំឲ្យមានសេវាផ្នែកសុខាភិបាលនិងសង្គមកិច្ច សម្រាប់ជាប្រយោជន៍ដល់ ប.ជ.អ.។

**២.នាយក ប.ជ.អ.**

ប.ជ.អ. គ្រប់គ្រងដោយនាយកមួយរូប ដែលត្រូវតែងតាំងដោយអនុក្រឹត្យតាមសេចក្តីស្នើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយក ប.ជ.អ. មានតួនាទីជានាយកប្រតិបត្តិ។ នាយក ប.ជ.អ. មានភារកិច្ច[16]ដូចខាងក្រោម៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំថវិកាប្រចាំឆ្នាំសម្រាប់ ប.ជ.អ. ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច

[15] មាត្រា ២ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន
[16] មាត្រា ១២ នៃអនុក្រឹត្យស្តីពី ការបង្កើតបេឡាជាតិអតីតយុទ្ធជន

- ធ្វើរបាយការណ៍ការងារគ្រប់គ្រង ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្ដាការិយាល័យ និងអង្គភាពក្រោមឱវាទ
- បំពេញមុខតំណែងរបស់ ប.ជ.អ. ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពវិធានស្ដីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ ប.ជ.អ. ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ស្ដីពីការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត

នាយក ប.ជ.អ. ជាតំណាងរបស់ ប.ជ.អ. ក្នុងទំនាក់ទំនងជាមួយតតិយជន ហើយនាយក ប.ជ.អ. ត្រូវស្នើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តែងតាំងនាយករងមួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

**៣.បុគ្គលិករបស់ ប.ជ.អ.**

បុគ្គលិកអចិន្ត្រៃយ៍របស់ ប.ជ.អ. មានមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមកពីក្រសួង ស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវក្របខ័ណ្ឌ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

ប.ជ.អ. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា។ បុគ្គលិកទាំងនោះត្រូវស្ថិតក្រោមបទប្បញ្ញត្តិ នៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្ដីពីការងារ។ បុគ្គលិក ប.ជ.អ. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្ដីពីការគ្រប់គ្រងបុគ្គលិក ដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីមុខងារសាធារណៈ បទបញ្ជានេះ មិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។

# ជំពូកទី២
# របបសន្តិសុខសង្គម
# ចំពោះមន្ត្រីសាធារណៈ

# ជំពូកទី២ ៖ របបសន្តិសុខសង្គមចំពោះមន្ត្រីសាធារណៈ

## ផ្នែកទី១ ៖ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សំដៅដល់ការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។ គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈដោយធ្វើការឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន អង្គភាពខ្លួន។ គ្រោះថ្នាក់ពេលធ្វើដំណើរ សំដៅដល់គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយមន្ត្រីសាធារណៈ ក្នុងពេលធ្វើដំណើរពីលំនៅឋានត្រង់ឆ្ពោះទៅកន្លែងធ្វើការឬវិលមកវិញដោយគ្មានឈប់ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ក្រៅពីការងារដែលក្រសួង ស្ថាប័ន ឬអង្គភាពតម្រូវឲ្យទៅ។ ជំងឺវិជ្ជាជីវៈ សំដៅជំងឺនោះកើតឡើងក្នុងកំលុងពេលបំពេញការងារ ឬក្នុងពេលណាមួយក្រោយបំពេញការងារក៏ដោយ។ រាជរដ្ឋាភិបាលបានសម្រេចដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមសម្រាប់មន្ត្រីសាធារណៈតាមរយៈការចេញអនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បន្ថែមលើព្រះរាជក្រឹត្យ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលមានគោលដៅផ្តល់នូវតាវកាលិកសន្តិសុខសង្គម ផ្នែកហានិភ័យការងារចំពោះមន្ត្រីសាធារណៈ។ របបនេះនឹងផ្តល់តាវកាលិកជូនមន្ត្រីសាធារណៈដូចជា ការសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០% ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%ឡើង វិភាជន៍បូជាសព ធនលាភឧត្តរជីវីសម្រាប់សហព័ទ្ធនិងកូន ព្រមទាំងជនចាស់ជរាពុំមានប្រាក់ចំណូល ដែលនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះដោយហានិភ័យការងាររហូតបាត់បង់ជីវិត។

### កថាខណ្ឌទី១ ៖ ការអនុវត្តចំពោះហានិភ័យការងារ

មន្ត្រីសាធារណៈ មានដូចជា មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ មន្ត្រីនគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យាដែលបម្រើនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារនៅពេលទទួលរងហានិភ័យការងារ។

ជនរងគ្រោះដោយហានិភ័យការងារឬសិទ្ធិវន្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅ ប.ស.ស និងក្រសួង ស្ថាប័ន ឬអង្គភាពសាមី អំពីគ្រោះថ្នាក់ដែលបានកើតឡើងចំពោះខ្លួន លើកលែងតែករណីប្រធានស័ក្តិ ឬការមិនមានលទ្ធភាព ឬមានមូលហេតុសមស្រប។

**កថាខណ្ឌទី២ ៖ ការទទួលបានតាវកាលិក**

**ក.តាវកាលិកសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារ រួមមាន៖ ការព្យាបាលនិងថែទាំមុខរបួសឬជំងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ ទោះដោយសម្រាកឬមិនសម្រាកនៅក្នុងមន្ទីរពេទ្យក្តី រហូតដល់ជាសះស្បើយ ការផ្តល់សេវាសង្គ្រោះបន្ទាន់ ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាលនិងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល ការផ្តល់សេវាស្តារនីតិសម្បទា មានជាអាទិ៍ ការផ្គត់ផ្គង់ ការថែទាំ ឬការជួសជុលឧបករណ៍អវយវៈ ឬសរីរាង្គសិប្បនិម្មិត ឬការកែទម្រង់រាងកាយដែលតម្រូវដោយគ្រូពេទ្យផ្លូវការ ការសម្របសម្រួលមុខងារ ឬការអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈឡើងវិញ ការផ្តល់សេវាដឹកសពឬបញ្ជូនជនរងគ្រោះពេលសង្គ្រោះបន្ទាន់។

**ខ.តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

**១.វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

មន្ត្រីសាធារណៈដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យមានការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០% មានសិទ្ធិទទួលបានវិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារដែលត្រូវបើកផ្តល់ជូនតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម[17]៖

| វ.ប.ក. = ប.ថ. x ក.ប.ក. x ២០% ម.ត.ប. |
|---|

-វ.ប.ក. គឺជាវិភាជន៍បាត់បង់សមត្ថភាពការងារ

-ប.ថ. គឺជាប្រាក់បៀវត្សប្រចាំថ្ងៃរបស់ជនរងគ្រោះ ដែលស្មើនឹងបៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះចែកនឹង២២ថ្ងៃ

-ក.ប.ក. គឺជាកម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍របស់ជនរងគ្រោះ

-ម.ត.ប. គឺជាមេគុណតម្លៃបច្ចុប្បន្នគិតតាមអាយុរបស់ជនរងគ្រោះ

អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍តិចជាង២០% មានរយៈពេល ៥ឆ្នាំ។

[17] ចំណុច ក មាត្រា ៥ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**២.ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

មន្ត្រីសាធារណៈ ដែលរងគ្រោះដោយហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី២០%ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដែលត្រូវគិតតាមរូបមន្តដូចខាងក្រោម[18]៖

| ធ.ល. = ប.ខ. x ៤/៥ ក.ប.ក. |
|---|

-ធ.ល. គឺជាធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

-ប.ខ. គឺជាប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់ជនរងគ្រោះ

ការផ្តល់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ ប.ស.ស ត្រូវរៀបចំឲ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារឡើងវិញក្នុងរយៈពេល១២ខែយ៉ាងយូរ។ សាមីជនដែលទទួលបានធនលាភនេះ ត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពនិងសមត្ថភាពការងារតាមការកំណត់របស់ ប.ស.ស។

ក្នុងករណីដែលមានតាវកាលិកត្រួតគ្នារវាងធនលាភនិងប្រាក់សោធន សាមីជនមានសិទ្ធិទទួលបានតែតាវកាលិកណាមួយដែលមានចំនួនទឹកប្រាក់ខ្ពស់ជាងប៉ុណ្ណោះ។ អាជ្ញាយុកាលនៃសិទ្ធិទាមទារធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានរយៈពេល ៥ឆ្នាំ។

**គ.តាវកាលិកមរណភាពនៃមន្ត្រីសាធារណៈដែលរងហានិភ័យការងារ**

**១.វិភាជន៍បូជាសព**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត អ្នកដែលមានករណីយកិច្ចចាត់ចែងបូជាសពជនរងគ្រោះ ត្រូវទទួលបានវិភាជន៍បូជាសពចំនួន ១០លានរៀល។ វិភាជន៍នេះត្រូវតែផ្តល់ជូនទៅជនដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ។ អាជ្ញាយុកាលនៃសិទ្ធិទាមទារវិភាជន៍បូជាសពមានរយៈពេល ១ឆ្នាំ។[19]

**២.ធនលាភឧត្តរជីវី**

ក្នុងករណីដែលមានហានិភ័យការងាររហូតដល់បាត់បង់ជីវិត សិទ្ធិវន្តនៃជនរងគ្រោះមានសិទ្ធិទទួលបានធនលាភឧត្តរជីវី។ សិទ្ធិវន្តនៃជនរងគ្រោះ ដោយហានិភ័យការងាររហូតបាត់បង់ជីវិតរួមមាន៖

[18] ចំណុច ខ មាត្រា ៥ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[19] មាត្រា ៦ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

- ប្តីឬប្រពន្ធរបស់សាមីជនរងគ្រោះ ដែលមានសំបុត្រអាពាហ៍ពិពាហ៍មុនពេលមានហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារនៃប្តី ឬប្រពន្ធ
- កូនដែលមានអាយុត្រឹម១៨ឆ្នាំចុះ ដែលមិនទាន់មានគូស្រករនិងមានស្ថានភាពដូចខាងក្រោម៖
  - ជាកូនបង្កើត
  - ក្នុងករណីមានការលែងលះ ឬករណីមរណភាពនៃប្តី ឬប្រពន្ធ កូននៃគូស្រករក្រោយដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍ទីមួយដែរ។
  - កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ[20]។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់២១ឆ្នាំចុះ ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬកូនដែលកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ព្រមទាំងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ។ ចំពោះកូនពិការឬមានជំងឺរ៉ាំរ៉ៃ ដែលមិនមានលទ្ធភាពធ្វើការងារមានប្រាក់ឈ្នួល មិនមានការកំណត់អាយុទេ។

- ឪពុកម្តាយឬមនុស្សចាស់ដែលមានអាយុយ៉ាងតិច៥៥ឆ្នាំ មិនមានប្រកបមុខរបរមានប្រាក់ចំណូល និងត្រូវនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ។

ធនលាភឧត្តរជីវី ត្រូវបានផ្តល់ជូនប្រចាំខែតាមរូបមន្តដូចខាងក្រោម[21]៖

- ចំពោះសិទ្ធិវន្ត ជារួមមានប្តីឬប្រពន្ធ កូន និងឪពុកម្តាយ ឬមនុស្សចាស់នៅក្នុងបន្ទុក៖
  -ប្តីឬប្រពន្ធស្មើនឹង ៣/៥ x៦៣%**ប.ខ.** ដែល**ប.ខ.** ជាបៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន
  -ធនលាភសរុបសម្រាប់កូនក្នុងបន្ទុកស្មើនឹង ២/៥ x៦៣%ប.ខ.
  -ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុកស្មើនឹង ៧%ប.ខ.
- ចំពោះសិទ្ធិវន្តជារួមមាន ប្តីឬប្រពន្ធ និងកូន៖
  -ប្តីឬប្រពន្ធ ស្មើនឹង ៣/៥ x ៧០%ប.ខ.
  -ធនលាភសរុបសម្រាប់កូនក្នុងបន្ទុកស្មើនឹង ២/៥ x៧០%ប.ខ.
- ចំពោះសិទ្ធិវន្ត ជារួមមានប្តីឬប្រពន្ធ និងឪពុកម្តាយ ឬមនុស្សចាស់៖
  -ប្តីឬប្រពន្ធស្មើនឹង ២៨%ប.ខ.

[20] មាត្រា ៧ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[21] មាត្រា ៨ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

-ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុកស្មើនឹង ២៨%ប.ខ.

- ចំពោះសិទ្ធិវន្តជាប្តីឬប្រពន្ធឬកូននៅក្នុងបន្ទុក ធនលាភសម្រាប់ប្តីឬប្រពន្ធឬធនលាភសរុបសម្រាប់កូនក្នុងបន្ទុកស្មើនឹង ៥៦%ប.ខ.
- ចំពោះសិទ្ធិវន្តជាឪពុកម្តាយឬមនុស្សចាស់ ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុកស្មើនឹង ៣៥%ប.ខ.
- ចំពោះសិទ្ធិវន្តជារួមមាន កូននិងឪពុកម្តាយឬមនុស្សចាស់៖

-ធនលាភសរុបសម្រាប់កូន២៨%ប.ខ.

-ធនលាភសរុបសម្រាប់ឪពុកម្តាយឬមនុស្សចាស់ដែលនៅក្នុងបន្ទុកស្មើនឹង ២៨% ប.ខ.

សិទ្ធិទទួលបានធនលាភឧត្តរជីវី ត្រូវផុតរលត់ក្នុងករណីនៅពេលដែលសាមីជនទទួលមរណភាព និងប្តីឬប្រពន្ធដែលមានគូស្រករថ្មី ទោះបីជាមានឬគ្មានសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក ប.ស.ស យ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីមានគូស្រករថ្មី។[22]

## ផ្នែកទី២ ៖ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ឬបញ្ហាសុខភាពដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ។ រាជរដ្ឋាភិបាលបានសម្រេចដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ តាមរយៈការចេញអនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បន្ថែមលើព្រះរាជក្រឹត្យស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលមានគោលដៅផ្តល់នូវតាវកាលិកសន្តិសុខសង្គម ផ្នែកថែទាំសុខភាពចំពោះមន្ត្រីសាធារណៈ។ របបនេះ នឹងផ្តល់ជូនមន្ត្រីសាធារណៈនូវសេវាថែទាំសុខភាពទូទៅរួមមាន ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព ការផ្តល់សេវាបង្ការសុខភាព សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ការកំណត់ជំងឺរ៉ាំរ៉ៃ។

[22] មាត្រា ៩ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**កថាខណ្ឌទី១ ៖ សេវាថែទាំសុខភាព**

មន្ត្រីសាធារណ:មានដូចជា មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ មន្ត្រីនគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យាដែលបម្រើនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ អាចទទួលបានសេវាថែទាំសុខភាព ហើយដែលបានបង់ភាគទាន ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដល់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។ ដោយឡែក ចំពោះមន្ត្រីសាធារណៈដែលត្រូវបញ្ចូលក្នុងក្របខ័ណ្ឌថ្មី ក្រសួង ស្ថាប័ន ឬអង្គភាពសាមី ត្រូវបញ្ជូនឈ្មោះមន្ត្រីសាធារណៈនោះមក ប.ស.ស។ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពមានសមត្ថកិច្ច ត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈដែលបានធ្វើបច្ចុប្បន្នកម្មរួច មក ប.ស.ស រៀងរាល់៦ខែ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារ និងថែទាំសុខភាព។ គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវផ្តល់កិច្ចសហការជាមួយ ប.ស.ស ក្នុងការគ្រប់គ្រង និងផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិករបស់ក្រសួងសុខាភិបាល។[23]

**ក.តាវកាលិកផ្នែកសេវា**

**១.សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ រួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល សេវាព្យាបាលដោយស្តុំឬការព្យាបាលដោយចលនា និងសេវាស្តារនីតិសម្បទា និងសេវាសង្គ្រោះបន្ទាន់។[24]

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនដូចខាងក្រោម[25]៖

-ចំពោះការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ រួមមាន៖ សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យ

[23] មាត្រា ១១ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[24] មាត្រា ១២ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[25] មាត្រា ១៣ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

វេជ្ជសាស្រ្តផ្សេងៗទៀត ឧបករណ៍ផ្នែកសល្យសាស្រ្តនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្រ្តផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល ឱសថតាមវេជ្ជបញ្ជា បន្ទប់សម្រាកព្យាបាល(តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល)។

-ចំពោះការផ្តល់សេវាពិគ្រោះជំងឺក្រៅ រួមមាន៖ សេវាព្យាបាលនិងថែទាំតាមបច្ចេកវិជ្ជាជីវៈវេជ្ជសាស្រ្ត សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្រ្តផ្សេងៗទៀត ឧបករណ៍ផ្នែកសល្យសាស្រ្ត និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្រ្តផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល ឱសថតាមវេជ្ជបញ្ជា។

-ចំពោះការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល។

-ចំពោះការផ្តល់សេវាព្យាបាលដោយស្ពំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាដទៃទៀត។

-ចំពោះសេវាសង្គ្រោះបន្ទាន់ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាល ដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះ មិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជនរងគ្រោះឬអ្នកតំណាង ត្រូវជូនដំណឹងជាបន្ទាន់មកប.ស.ស។

សេវាព្យាបាលនិងថែទាំ ដែលមានការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ ការផ្តល់សេវាពិគ្រោះជំងឺក្រៅ ការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល ការផ្តល់សេវាព្យាបាលដោយស្ពំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាសេវាសង្គ្រោះបន្ទាន់ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀត មិនត្រូវបានផ្តល់ជូនឡើយ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ចំពោះស្ត្រីដែលជាមន្ត្រីរាជការដោយផ្តល់ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់ការសម្រាលកូននូវទឹកប្រាក់ចំនួន ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀល សម្រាប់ការសម្រាលបានកូនមួយ។ ប្រាក់ឧបត្ថម្ភនេះ នឹងត្រូវបង្កើនទ្វេគុណ ឬត្រីគុណ ឬច្រើនជាងនេះ ជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា ជាស្ត្រីតាមចំនួនកូនដែលបានសម្រាល។[26] ប្រាក់ឧបត្ថម្ភមាតុភាពសម្រាប់ការសម្រាលកូន ត្រូវបានផ្តល់ជូនមន្ត្រីរាជការ និងមន្ត្រីកម្មសិក្សា ដែលកំពុងបម្រើការងារស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះ

[26] មាត្រា ៤ នៃអនុក្រឹត្យស្តីពី ការកែប្រែនិងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព

រាជអាជ្ញា ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ ព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយក្រសួង ស្ថាប័ន សាមី ទទួលបន្ទុកដោះស្រាយនូវប្រាក់ឧបត្ថម្ភនោះ។

**២.សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព**

ការផ្ដល់សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ត្រូវផ្ដល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។ ការផ្ដល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជា ឬសេវាបញ្ជូនសព ត្រូវផ្ដល់ជូនតាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។[27]

**៣.សេវាបង្ការសុខភាព**

ការផ្ដល់សេវាបង្ការសុខភាពអាចត្រូវបានផ្ដល់ដោយ ប.ស.ស កម្មវិធីបង្ការសុខភាពឬកម្មវិធីបង្ការសុខភាពដទៃផ្សេងទៀត។ សេវាបង្ការសុខភាពដែលផ្ដល់ដោយ ប.ស.ស ត្រូវអនុវត្តដូចគ្នានឹងកម្មវិធីបង្ការសុខភាពផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។[28] សេវាបង្ការសុខភាពដែលត្រូវដាក់បញ្ចូល រួមមាន៖ សេវាចាក់វ៉ាក់សាំងការពារជំងឺផ្ដាសាយធំ សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ សេវាពិនិត្យឈាមរកជំងឺពក ក សេវាពិនិត្យឈាមកំណត់អបោធាតុមហារីកក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និងឬក្រោយការព្យាបាលជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិច មាន៖ CA15-3(Canner Antigen15-3), CA19-9(Canner Antigen19-9), CA125(Canner Antigen125), PSA(Prostate-Specific-Antigen), -HCG(Beta-Human Chorionic Gonadotropin)។ សេវាបង្ការដែលបានកំណត់ខាងលើ ត្រូវផ្ដល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬវិទ្យាស្ថានសាធារណៈ។ សេវានេះមិនត្រូវបានទូទាត់វិញចំពោះការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនក្នុង ឬក្រៅប្រទេសឡើយ លើកលែងតែមានការអនុញ្ញាតជាមុនពី ប.ស.ស។[29]

---

[27] មាត្រា ១៥ នៃអនុក្រឹត្យស្ដីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ដល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[28] មាត្រា ១៦ នៃអនុក្រឹត្យស្ដីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្ដល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[29] ប្រការ ២ នៃប្រកាសស្ដីពី ការដាក់បញ្ចូលសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

**ខ.សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល**

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររួមមាន ការព្យាបាលដោយឥតបង់ថ្លៃដែលកំណត់នៅក្នុងគោលនយោបាយសុខាភិបាលជាតិ ការពិនិត្យសុខភាពទូទៅ ការថែទាំធ្មេញ(ការសម្អាត ការប៉ះ និងការដាក់ធ្មេញ) សេវាប្តូរភេទ ការព្យាបាល ឬវះកាត់កែសម្ផស្ស ឬកែលម្អផ្នែកណាមួយនៃរាងកាយ សេវាបង្កកំណើតសិប្បនិម្មិត ការព្យាបាលអសមត្ថភាពផ្តល់កំណើត ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ ការព្យាបាលដោយខ្លួនឯង ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត ការព្យាបាលញៀនសុរាឬការព្យាបាលផ្តាច់គ្រឿងញៀន ការវះកាត់ដាក់គ្រាប់ភ្នែកសិប្បនិម្មិត ការវះកាត់បេះដូងឬសរសៃបេះដូង និងការលាងឈាម។ សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលដូចបានរៀបរាប់ចំណុចខាងលើ ត្រូវបានផ្តល់ជូន ក្នុងករណីត្រូវសង្គ្រោះបន្ទាន់។[30]

**គ.ការកំណត់ជំងឺរ៉ាំរ៉ៃ**

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់តែឱសថសារវន្តដែលកំណត់ដោយក្រសួងសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុករបស់សាមីជន។ បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវអនុវត្តដូចគ្នានឹងបញ្ជីជំងឺរ៉ាំរ៉ៃនៃផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។[31] ប្រភេទជំងឺរ៉ាំរ៉ៃ ដែលត្រូវកំណត់រួមមាន៖ ជំងឺខ្សោយបេះដូង ជំងឺសាច់ដុំបេះដូង ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ ជំងឺតំរងនោមរ៉ាំរ៉ៃ ជំងឺក្រិនថ្លើម ជំងឺសរសៃឈាមក្រហាមបេះដូង ជំងឺទឹកនោមផ្អែមប្រភេទទី១និងទី២ ជំងឺវិបត្តិចង្វាក់បេះដូង ជំងឺក្រិនសរីរាង្គ ជំងឺវិកលចរិក ជំងឺលុយពុស ជំងឺលើសឈាម ជំងឺតាឡាសសឺមី។[32]

**កថាខណ្ឌទី២ ៖ បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**

**ក.ការកំណត់អត្រាភាគទានផ្នែកថែទាំសុខភាព**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ជាបន្ទុករួមគ្នារវាងរដ្ឋ និងសាមីជន។ អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង ១% នៃប្រាក់បៀវត្សមូលដ្ឋាន ឬប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីសាធារណៈដែលក្នុងនោះ៖ ០,៥០% (សូន្យក្បៀសហាសិបភាគរយ) ជា

---

[30] មាត្រា ១៧ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[31] មាត្រា ១៨ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[32] ប្រការ២ នៃប្រកាសស្តីពី ការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

បន្ទុករបស់រដ្ឋ និង០,៥០% (សូន្យក្បៀសហាសិបភាគរយ) ជាបន្ទុករបស់សាមីជន។[33] ទោះបីជារាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយកំណត់នូវអត្រាបង់ភាគទានសម្រាប់មន្ត្រីសាធារណៈ ប៉ុន្តែរាជរដ្ឋាភិបាលក៏នូវតែជាអ្នករ៉ាប់រងបង់ជំនួសអត្រាភាគទាន ០,៥០% (សូន្យក្បៀសហាសិបភាគរយ) ដែលជាបន្ទុករបស់សាមីជន រហូតដល់មានការសម្រេចជាថ្មីរបស់រាជរដ្ឋាភិបាល។[34]

### ខ.ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

#### ១.ការចុះបញ្ជី និងការចេញអត្តសញ្ញាណសមាជិក

មន្ត្រីសាធារណៈរួមមាន៖ មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិហើយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ មន្ត្រីនគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យាដែលបម្រើនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានការទទួលស្គាល់ពីក្រសួងមុខងារសាធារណៈ ត្រូវបានចុះបញ្ជីជាសមាជិកនៃ ប.ស.ស ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស ។[35]

ប.ស.ស ត្រូវចេញលេខអត្តសញ្ញាណសមាជិក ប.ស.ស សម្រាប់មន្ត្រីសាធារណៈ ដោយអនុលោមតាមលេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ដើម្បីអនុវត្តការចេញលេខអត្តសញ្ញាណសមាជិកនេះ ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានភារកិច្ចដូចតទៅ ក្រសួងមុខងារសាធារណៈត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ និងទំហំថវិកាភាគទាន តាមក្រសួង ស្ថាប័នមក ប.ស.ស ជារៀងរាល់ខែ ដោយឡែកក្រសួង ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីសាធារណៈ ត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ និងទំហំថវិកាភាគទានដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ មក ប.ស.ស ជារៀងរាល់ខែ។[36]

---

[33] មាត្រា៤ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[34] មាត្រា១៦ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[35] មាត្រា៦ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[36] មាត្រា៧ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

### ២. ការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព សំដៅដល់វិធីសាស្ត្រនៃការទូទាត់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ សេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ដែល ប.ស.ស ត្រូវផ្តល់នូវមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ឬមូលដ្ឋានសុខាភិបាល ដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

ប.ស.ស ត្រូវទូទាត់តាវកាលិកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ស្របតាមលក្ខខណ្ឌ បែបបទ និងនីតិវិធី ដែលចែងក្នុងច្បាប់ជាធរមាន។ ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹងយន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ក្រៅពីឱសថក្នុងបញ្ជីឱសថសារវន្ត ដែលត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។[37]

យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាងគឺ វិធីសាស្ត្រទូទាត់ថ្លៃតាមករណី និងវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា។ វិធីសាស្ត្រទូទាត់ថ្លៃតាមករណី[38] ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជំងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា[39] ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេសដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ វិធីសាស្ត្រដែលកំណត់នៅក្នុងយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។[40] ប.ស.ស ត្រូវទូទាត់សងទៅមូលដ្ឋានសុខាភិ

[37] មាត្រា ២១ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[38] មើលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

[39] មើលឧបសម្ព័ន្ធទី២ ប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

[40] ប្រការ៣ នៃប្រកាសអន្តរក្រសួងស្តីពី យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

បាល ឬសាមីជន តាមវិធីសាស្ត្រទូទាត់ថ្លៃដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួង ស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ក្នុងករណីសង្គ្រោះបន្ទាន់។ ក្នុងករណីនេះ ជនរងគ្រោះ ឬអ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ប្រសិនបើ ការសង្គ្រោះបន្ទាន់ធ្វើនៅក្នុងមូលដ្ឋានសុខាភិបាល ដែលមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជន ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស ។ ការទូទាត់ថ្លៃសេវាបញ្ជូនជនរងគ្រោះ ឬអ្នកជំងឺ សម្រាប់ផ្នែកថែទាំសុខភាពត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ប្រភេទមធ្យោបាយបញ្ជូនដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់។ ការទូទាត់ថ្លៃសេវាបញ្ជូន ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ ការបញ្ជូនសព ឬបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។ ការទូទាត់ថ្លៃសេវាបញ្ជូន និងការទូទាត់ថ្លៃសេវាស្តារនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ របៀបទូទាត់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ចំពោះមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវារវាង ប.ស.ស ជាមួយមូលដ្ឋានសុខាភិបាលដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។[41]

សិទ្ធិនៃការទាមទារថ្លៃតារកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល១២ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។[42]

[41] ប្រកាសអន្តរក្រសួងស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

[42] មាត្រា២០ នៃអនុក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តារកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

# ជំពូកទី៣
# របបសន្តិសុខសង្គម
# ចំពោះអតីតមន្ត្រីរាជការ
# និងអតីតយុទ្ធជន

# ជំពូកទី៣ ៖ របបសន្តិសុខសង្គមចំពោះអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

## ផ្នែកទី១ ៖ របបសន្តិសុខសង្គមផ្នែកសោធន

ជាទូទៅ ប្រជាជនកម្ពុជាមិនមានទម្លាប់រៀបចំផែនការហិរញ្ញវត្ថុសម្រាប់ខ្លួនឯងនៅពេលដែលពួកគាត់ឈានចូលវ័យចាស់ជរានោះឡើយ ដោយភាគច្រើនត្រូវពឹងផ្អែកលើការឧបត្ថម្ភរបស់កូនចៅ។ ទម្លាប់នេះ ជាកត្តាជំរុញឲ្យប្រជាជនកម្ពុជាប្រឈមនឹងហានិភ័យខ្ពស់ ក្នុងការធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចូលវ័យចាស់ជរា ជាពិសេស ក្នុងករណីកូនចៅដែលជាជំហរសេដ្ឋកិច្ចគ្រួសារស្ថិតនៅក្នុង ឬធ្លាក់ទៅក្នុងក្រុមប្រជាជនក្រីក្រ។ រហូតមកដល់ពេលនេះ មានតែមន្ត្រីរាជការ យោធិន និងនគរបាលបម្រើការងារក្នុងវិស័យសាធារណៈចំនួនប្រមាណ៧% នៃប្រជាជនសរុបប៉ុណ្ណោះ ទទួលបានប្រាក់សោធននៅពេលចូលនិវត្តន៍ ដែលជាផ្នែកមួយនៃរបបសន្តិសុខសង្គម។ គួរកត់សម្គាល់ឃើញថា ស្ថាប័នមួយចំនួនក៏បានរៀបចំឲ្យមានរបបសោធនសម្រាប់មន្ត្រី បុគ្គលិករបស់ខ្លួនផងដែររួមមាន៖ ធនាគារជាតិនៃកម្ពុជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងកំពង់ផែស្វយ័តក្រុងភ្នំពេញដែលរបបសោធនទាំងនោះស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងដោយស្ថាប័នផ្ទាល់ ហើយក៏មិនមានច្បាប់ និងបទប្បញ្ញត្តិសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យនៅឡើយ។

ប្រព័ន្ធសោធននៅកម្ពុជា បានចាប់ផ្តើមឡើងដោយមានលក្ខណៈដាច់ដោយឡែកពីគ្នាទៅតាមប្រភេទនៃសមាជិកគោលដៅ។ តាមរយៈព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង្កើតគ្រឹះស្ថានសាធារណៈចំនួនពីរគឺ ប.ជ.ស. និង ប.ជ.អ. ដើម្បីគ្រប់គ្រង និងបើកផ្តល់ប្រាក់សោធនសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនដែលជាមន្ត្រីនគរបាល និងយោធិន។ យោងតាមបទប្បញ្ញត្តិនេះ ប.ជ.ស. និង ប.ជ.អ. ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធជន ដែលស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ ប.ជ.ស. និង ប.ជ.អ. ទទួលហិរញ្ញប្បទានទាំងស្រុងពីថវិការដ្ឋ។

### កថាខណ្ឌទី១ ៖ សិទ្ធិទទួលបានរបបសោធនចំពោះមន្ត្រីរាជការ

មន្ត្រីរាជការទាំងពីរភេទ អាចទទួលបានរបបសោធនបានលុះត្រាតែបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដូចមានចែងក្នុងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពី ការអនុវត្តរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល ដែលច្បាប់ទាំងនេះ បានបញ្ញត្តិអំពីលក្ខខណ្ឌសម្រាប់ការចូលនិវត្តន៍របស់មន្ត្រីរាជការ និងការកំណត់អំពីអត្រាការទទួលបានប្រាក់សោធនសម្រាប់មន្ត្រីរាជការ នៅពេលដល់ចូលនិវត្តន៍។

**ក.លក្ខខណ្ឌនៃការចូលនិវត្តន៍**

ការចូលនិវត្តន៍ គឺជាការផ្លាស់ប្តូរស្ថានភាពពីមន្ត្រីរាជការទៅជានិវត្តជន ជាពិសេសការផ្លាស់ប្តូរពីការទទួលប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្សទៅជាការទទួលប្រាក់សោធននិវត្តន៍ជំនួសវិញ ហើយក៏ជាដំណាក់កាលចុងក្រោយនៃជីវិតការងាររបស់មន្ត្រីរាជការ នៅក្នុងអាជីពរបស់ខ្លួន។ ការចូលនិវត្តន៍ អាចធ្វើឡើងក្រោមទម្រង់៤ គឺ៖ ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឲ្យចូលនិវត្តន៍ ការចូលនិវត្តន៍មុនអាយុតាមការស្ម័គ្រចិត្ត ការដាក់ឲ្យចូលនិវត្តន៍ដោយបញ្ញត្តិ និងការដាក់ឲ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ។

**១.ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឲ្យចូលនិវត្តន៍**

ជាទូទៅមន្ត្រីរាជការត្រូវបានដាក់ឲ្យចូលនិវត្តន៍ នៅអាយុ ៥៥ឆ្នាំ ៥៨ឆ្នាំ និង៦០ឆ្នាំ ដោយយោងតាមច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ និងអាស្រ័យលើប្រភេទក្របខ័ណ្ឌ និងឋានន្តរស័ក្តិ ឬមុខតំណែងរបស់ខ្លួនម្នាក់ៗ។

**មន្ត្រីក្របខ័ណ្ឌប្រភេទ ក**

មន្ត្រីក្របខ័ណ្ឌប្រភេទ ក ទាំងអស់ចូលនិវត្តន៍ នៅអាយុ៦០ឆ្នាំ។ ហើយនៅក្នុងនោះផងដែរ គេបែងចែកជាឋានន្តរស័ក្តិដូចជា៖

- មន្ត្រីក្នុងឋានន្តរស័ក្តិទី១ នៃក្របខ័ណ្ឌប្រភេទ ក (ឧត្តមមន្ត្រី) ទាំងអស់ត្រូវសម្រេចឲ្យចូលនិវត្តន៍ដោយព្រះរាជក្រឹត្យ
- មន្ត្រីក្នុងឋានន្តរស័ក្តិទី២ នៃក្របខ័ណ្ឌប្រភេទ ក (វរៈមន្ត្រី) ទាំងអស់ត្រូវសម្រេចឲ្យចូលនិវត្តន៍ដោយអនុក្រឹត្យ
- មន្ត្រីក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌប្រភេទ ក (អនុមន្ត្រី) ទាំងអស់ត្រូវសម្រេចឲ្យចូលនិវត្តន៍ដោយប្រកាស៖
  - ប្រកាសរបស់ក្រសួងមុខងារសាធារណៈ សម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
  - ប្រកាសរបស់ក្រសួងមហាផ្ទៃ សម្រាប់ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់មហាផ្ទៃ
  - ប្រកាសរបស់ក្រសួង ស្ថាប័នសាមី សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
  - ប្រកាសរបស់ក្រសួងការបរទេស សម្រាប់ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
  - ប្រកាសរបស់ក្រសួងសុខាភិបាល សម្រាប់ក្របខ័ណ្ឌសុខាភិបាលជាន់ខ្ពស់
  - ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម

**មន្ត្រីក្របខ័ណ្ឌប្រភេទ ខ**

ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌនេះ អាយុចូលនិវត្តន៍ត្រូវបានកំណត់ខុសៗគ្នា ដូចខាងក្រោម៖

- មន្ត្រីក្របខ័ណ្ឌក្រមការ ចូលនិវត្តន៍នៅអាយុ៥៨ឆ្នាំ លើកលែងតែមន្ត្រីបម្រើការងារ ក្នុងក្រសួងអប់រំ យុវជន និងកីឡា ចូលនិវត្តន៍នៅអាយុ៦០ឆ្នាំ។ ការចូលនិវត្តន៍ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមុខងារសាធារណៈ។
- មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ចូលនិវត្តន៍នៅអាយុ ៥៨ឆ្នាំ ដោយប្រកាសក្រសួងមហាផ្ទៃ
- មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចូលនិវត្តន៍នៅអាយុ ៥៨ឆ្នាំ ដោយប្រកាសក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- មន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ចូលនិវត្តន៍នៅអាយុ ៦០ឆ្នាំ ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ចូលនិវត្តន៍អាយុ៥៨ឆ្នាំ ដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។
- មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ចូលនិវត្តន៍អាយុ៦០ឆ្នាំ ដោយប្រកាសរបស់ក្រសួងសុខាភិបាល។

**មន្ត្រីក្របខ័ណ្ឌប្រភេទ គ**

- មន្ត្រីក្របខ័ណ្ឌលេខាធិការរដ្ឋបាល ចូលនិវត្តន៍អាយុ៥៥ឆ្នាំ ដោយប្រកាសរបស់ក្រសួងមុខងារសាធារណៈ។
- មន្ត្រីក្របខ័ណ្ឌលេខាធិការដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និងមន្ត្រីក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ ចូលនិវត្តន៍អាយុ៥៥ឆ្នាំ ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។
- មន្ត្រីក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម ចូលនិវត្តន៍អាយុ៥៥ឆ្នាំ ដោយប្រកាសរបស់ក្រសួងស្ថាប័នសាមី។
- មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ចូលនិវត្តន៍អាយុ៥៨ឆ្នាំ ដោយប្រកាសរបស់ក្រសួងសុខាភិបាល
- មន្ត្រីក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ចូលនិវត្តន៍អាយុ៦០ឆ្នាំ ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា

បន្ថែមពីលើនេះទៀត ក៏មានការកំណត់យ៉ាងច្បាស់លាស់លើអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រីផងដែរ។ មន្ត្រីរាជការជាស្ត្រី ត្រូវដាក់ឲ្យចូលនិវត្តន៍ដល់អាយុ ៦០ឆ្នាំនៃប្រភេទដូចខាងក្រោម[43]៖

- ក្របខ័ណ្ឌ ខ៖ ក្របខ័ណ្ឌមន្ត្រីក្រមការ ក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- ក្របខ័ណ្ឌ គ៖ ក្របខ័ណ្ឌលេខាធិការរដ្ឋបាល ក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ ក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម។

ទន្ទឹមនឹងនេះដែរ មន្ត្រីរាជការស៊ីវិលជាស្ត្រី ដែលដូចបានបង្ហាញខាងលើ ក៏មានសិទ្ធិចូលនិវត្តន៍មុនអាយុ ៦០ឆ្នាំបាននៅពេលដល់អាយុ ៥៥ឆ្នាំ ឬ៥៨ឆ្នាំ ទៅតាមប្រភេទក្របខ័ណ្ឌរបស់ខ្លួន ដោយអនុលោមតាមព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ។[44]

**២.ការចូលនិវត្តន៍មុនអាយុ តាមការស្ម័គ្រចិត្ត**

មន្ត្រីរាជការទាំងឡាយដែលមានអតីតភាពការងារ ៣០ឆ្នាំឡើងទៅ ហើយមានអាយុ មិនទាន់ដល់អាយុកំណត់ឲ្យចូលនិវត្តន៍ អាចស្នើសុំចូលនិវត្តន៍បាន។ ក៏ប៉ុន្តែ នៅពេលដែលមន្ត្រីនៃក្របខ័ណ្ឌណាមួយ បានបម្រើការងារមានអតីតភាពគ្រប់ ៣០ឆ្នាំហើយ តែមិនទាន់ដល់អាយុចូលនិវត្តន៍នោះ ក្រសួង ស្ថាប័នមិនអាចចាប់បង្ខំឲ្យចូលនិវត្តន៍បានទេ។

**៣.ការដាក់ឲ្យចូលនិវត្តន៍ដោយប្បញ្ញត្តិ**

ការដាក់ឲ្យចូលនិវត្តន៍ដោយប្បញ្ញត្តិ ជាការដាក់មន្ត្រីរាជការណាម្នាក់ ឲ្យចូលនិវត្តន៍ដោយវិធានការវិន័យ ដែលបានកំណត់ក្នុងបទបញ្ញត្តិក្នុងជំពូកទី៥ នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យស្តីពី នីតិវិធីអនុវត្តវិន័យ ចំពោះមន្ត្រីរាជការស៊ីវិល។

**៤.ការដាក់ឲ្យចូលនិវត្តន៍ ដោយបាត់បង់សម្បទាវិជ្ជាជីវៈ**

ការដាក់ឲ្យចូលនិវត្តន៍នេះ អាចធ្វើទៅបាន ចំពោះមន្ត្រីរាជការទាំងពីរភេទ ដែលបានបាត់បង់សម្បទាវិជ្ជាជីវៈ និងមានអតីតភាពការងារចាប់ពី២០ឆ្នាំ ទៅក្រោម៣០ឆ្នាំ ហើយពុំគ្រប់អាយុចូលនិវត្តន៍។ ការបាត់បង់សម្បទាវិជ្ជាជីវៈ អាចបែងចែកជាមូលហេតុដូចជា៖

<u>ការបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារ</u>

---

[43] មាត្រា ២ នៃព្រះរាជក្រឹត្យស្តីពី ការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី

[44] មាត្រា ៣ នៃព្រះរាជក្រឹត្យស្តីពី ការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ សំដៅលើគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន ទោះជាមូលហេតុយ៉ាងណាក៏ដោយ ឬមានកំហុសមកពីមន្ត្រីរាជការ ឬគ្មានក៏ដោយ ហើយបណ្តាលឲ្យបាត់បង់សម្បទាវិជ្ជាជីវៈការងារទាំងស្រុងនិងអចិន្ត្រៃយ៍។

**ឧទាហរណ៍៖**

- គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុងនិងក្រៅក្រសួង ស្ថាប័ន ដែលមន្ត្រីរាជការបានបំពេញភារកិច្ចរបស់ខ្លួន
- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការ និងនៅពេលមុនឬក្រោយពេលធ្វើការ ដែលមន្ត្រីរាជការរៀបចំសម្ភារៈពលកម្ម ឬម៉ាស៊ីន
- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនក្នុងរយៈពេលធ្វើការ ដូចជា ពេលសម្រាកហូបចុក និងពេលបំបៅកូនកណ្តាលវេន ពេលសម្អាតខ្លួននៅពេលក្រោយធ្វើការ។
- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តាដែលមានគ្រោះថ្នាក់មានជាតិពុលដោយមិនដឹងខ្លួនជាមុនក្នុងក្រសួង ស្ថាប័ន និងក្នុងផលិតកម្ម ហើយបណ្តាលឲ្យមានរបួសពុលសន្លប់ដល់មន្ត្រីរាជការ ហើយធ្វើឲ្យបាត់បង់សម្បទាវិជ្ជាជីវៈជាស្ថាពរនូវសមត្ថភាពការងារ
- គ្រោះថ្នាក់ដែលធ្លាក់លើមន្ត្រីរាជការ ក្នុងពេលដែលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានរបស់ខ្លួនឆ្ពោះត្រង់ទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន។

<u>ការបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារក្នុងពេលបេសកកម្ម</u>

-គ្រោះថ្នាក់នៅពេលមន្ត្រីរាជការបញ្ចេញនូវវីរៈភាព ក្នុងការបំពេញបេសកកម្មដែលក្រសួងស្ថាប័នអង្គភាពប្រគល់ជូន ហើយបានលះបង់ជីវិតរបស់ខ្លួន។

-គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលមន្ត្រីរាជការ ការពារទ្រព្យសម្បត្តិរដ្ឋ ឬសាធារណៈដូចជា ភ្លើងឆេះ ទឹកជំនន់ ជាដើម។

<u>ការបាត់បង់សម្បទាវិជ្ជាជីវៈ ដោយសារជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ</u>

ការដាក់ឲ្យចូលនិវត្តន៍ ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈ ដោយសារមន្ត្រីរាជការមានជំងឺ ឬដោយសារគ្រោះថ្នាក់ផ្សេងៗ ក្រៅពីករណីគ្រោះថ្នាក់ការងារខាងលើ។

**ខ.ការទទួលបានរបបសោធន**

ប្រាក់សោធននិវត្តន៍របស់មន្ត្រីរាជការប្រែប្រួលទៅតាមស្ថានភាពចូលនិវត្តន៍របស់មន្ត្រីម្នាក់ៗ ដែលក្នុងនោះមាននិវត្តជនខ្លះទទួលបាន ៨០% នៃបៀវត្សមូលដ្ឋាន ខ្លះទទួលបាន ៦០%នៃបៀវត្សមូលដ្ឋានជាដើម។ ប្រាក់សោធននិវត្តន៍រួមមាន៖ ប្រាក់សោធននិវត្តន៍អតីតភាព ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា ប្រាក់ឧបត្ថម្ភតែមួយលើក ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ

អតិបរមា ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមាឬសមាមាត្រ ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈតែមួយលើក។

ភារកិច្ចនិងសមត្ថកិច្ចនៃការគ្រប់គ្រងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ជាបន្ទុករបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងដំណើរការបើកផ្តល់តាវកាលិកជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកតាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។

**១.ប្រាក់សោធននិវត្តន៍អតីតភាព**

ប្រាក់សោធននិវត្តន៍អតីតភាពផ្តល់ជូនមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍តាមការកំណត់ ព្រមទាំងមានអតីតភាពបម្រើការងារយ៉ាងតិច ៣០ឆ្នាំឬមន្ត្រីរាជការដែលស្នើសុំចូលនិវត្តន៍តាមការកំណត់ ប៉ុន្តែមានអតីតភាពបម្រើការងារយ៉ាងតិច ៣០ឆ្នាំ។

| |
|---|
| **ប្រាក់សោធននិវត្តន៍អតីតភាព ស្មើនឹង ៨០%នៃបៀវត្សមូលដ្ឋានចុងក្រោយ បូកនឹង ប្រាក់វិភាជន៍គ្រួសារ បូកនឹង ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)** |

ប្រាក់សោធននិវត្តន៍អតីតភាព ផ្តល់ជូននិវត្តជនប្រចាំខែរហូតដល់ពេលនិវត្តជននោះទទួលមរណៈភាព ហើយប្រាក់ប្រាក់សោធននិវត្តន៍អតីតភាព ត្រូវបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

**២.ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា**

ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា ផ្តល់ជូនមន្ត្រីរាជការដែលដល់អាយុចូលនិវត្តន៍តាមការកំណត់ ព្រមទាំងមានអតីតភាពបម្រើការងារចាប់ពី២០ឆ្នាំ ដល់ក្រោម៣០ឆ្នាំ។

| |
|---|
| **ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា ស្មើនឹង ៦០%នៃបៀវត្សមូលដ្ឋានចុងក្រោយ បូកនឹង (២% គុណនឹងចំនួនឆ្នាំដែលលើសពី ២០ឆ្នាំ) បូកនឹង ប្រាក់វិភាជន៍គ្រួសារ បូកនឹង ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)** |

ប្រាក់សោធននិវត្តន៍សមាមាត្រឬប្រាក់សោធនអប្បបរមា ផ្តល់ជូននិវត្តជនប្រចាំខែរហូតដល់ពេលនិវត្តជននោះទទួលមរណៈភាព ហើយប្រាក់ប្រាក់សោធននិវត្តន៍អតីតភាព ត្រូវបើកនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។

**៣.ប្រាក់ឧបត្ថម្ភតែមួយលើក**

ប្រាក់ឧបត្ថម្ភតែមួយលើក ផ្តល់ជូនមន្ត្រីរាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពបម្រើការងារតិចជាង២០ឆ្នាំឬផ្តល់ជូនមន្ត្រីរាជការ ដែលស្នើសុំឈប់ពីការងារដោយស្ម័គ្រចិត្ត ដោយមានប្រធានក្រសួង ស្ថាប័នយល់ព្រមតាមសំណើ។ ប្រាក់ឧបត្ថម្ភតែមួយលើកនេះ ទាបបំផុតស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយ គុណនឹង ៤ និងខ្ពស់បំផុតស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយ គុណនឹង ១០។

| |
|---|
| **បៀវត្សមូលដ្ឋានចុងក្រោយ x ៤ ≤ ប្រាក់ឧបត្ថមួយលើក ≤ បៀវត្សមូលដ្ឋានចុងក្រោយ x ១០** |

**៤.ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា**

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ (ដោយគ្រោះថ្នាក់ការងារឬក្នុងពេលបំពេញបេសកកម្ម) ហើយមានអតីតភាពបម្រើការងារចាប់ពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ ព្រមទាំងពុំគ្រប់អាយុចូលនិវត្តន៍។

| |
|---|
| **ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ស្មើនឹង ៦៥%នៃបៀវត្សមូលដ្ឋានចុងក្រោយ បូកនឹង ប្រាក់វិភាជន៍គ្រួសារ បូកនឹងប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។** |

**៥.ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមាឬសមាមាត្រ**

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមាឬសមាមាត្រ ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ (ដោយជំងឺឬគ្រោះថ្នាក់ផ្សេងៗ) ហើយមានអតីតភាពបម្រើការងារចាប់ពី ២០ឆ្នាំ ដល់ក្រោម ៣០ឆ្នាំ ព្រមទាំងពុំគ្រប់អាយុចូលនិវត្តន៍។

| |
|---|
| **ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមាឬសមាមាត្រ ស្មើនឹង ៥០%នៃបៀវត្សមូលដ្ឋានចុងក្រោយ បូកនឹង (១.៥% គុណនឹងចំនួនឆ្នាំដែលលើសពី២០ឆ្នាំ) បូកនឹង ប្រាក់វិភាជន៍គ្រួសារ បូកនឹង ប្រាក់ឧបត្ថម្ភផ្សេងទៀត(បើមាន)។** |

**៦.ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈតែមួយលើក**

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈតែមួយលើក ផ្តល់ជូនមន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ មានអតីតភាពបម្រើការងារតិចជាង២០ឆ្នាំ ក្រសួង ស្ថាប័ន តម្រូវឲ្យបាត់បង់សម្បទាវិជ្ជាជីវៈ។ យោងលិខិតលេខ ១៤៣ ស.ជ.ណា ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ប្រាក់សោធនបាត់បង់សម្បទា

វិជ្ជាជីវៈតែមួយលើក ស្មើនឹងបៀវត្សមូលដ្ឋានចុងក្រោយ គុណនឹង ៧ ។ មន្ត្រីរាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណៈភាពគ្រួសារនៃសពទទួលបានប្រាក់ឧបត្ថម្ភដូចនិវត្តជនដែរ គឺស្មើនឹងប្រាក់សោធនប្រចាំខែ គុណនឹង ១២ខែ ។

**កថាខណ្ឌទី២៖ សិទ្ធិទទួលបានរបបសោធន និងរបបឧបត្ថម្ភផ្សេងៗ ចំពោះអតីតយុទ្ធជន**

កងកម្លាំងប្រដាប់អាវុធសំដៅយោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ។ ការចូលនិវត្តន៍របស់កងកម្លាំងប្រដាប់អាវុធត្រូវបានបែងចែកជាពីរប្រភេទគឺ ការចូលនិវត្តន៍របស់យោធិននៃកងយោធពលខេមរភូមិន្ទ និងការចូលនិវត្តន៍នៃមន្ត្រីនគរបាលជាតិ។

**ក.លក្ខខណ្ឌនៃការចូលនិវត្តន៍ និងរបបសោធនចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ**

ស្ថានភាពចូលនិវត្តន៍ ជាស្ថានភាពបញ្ចប់ជាស្ថាពរនៃក្របខ័ណ្ឌយោធិនអាជីព ហើយត្រូវវិលត្រឡប់ទៅកាន់ជីវភាពស៊ីវិលវិញ ដោយទទួលផលប្រយោជន៍តាមច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ។[45]

របបសោធននិវត្តន៍ គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់ឲ្យយោធិនម្នាក់ៗ ដែលបានបំពេញតាមលក្ខខណ្ឌចូលនិវត្តន៍ និងរយៈពេលបម្រើការងារ។ របបបាត់បង់សមត្ថភាព គឺជាគោលរបបគិតជាទឹកប្រាក់ ដែលរដ្ឋត្រូវផ្តល់ឲ្យយោធិនម្នាក់ៗ ផ្អែកតាមសកម្មភាពបំពេញការងាររបស់ខ្លួនកន្លងមក មានផលប៉ះពាល់សុខភាព ដោយមិនអាចបន្តការងារទៀតបាន ហើយត្រូវបានចាត់ចូលក្នុងប្រភេទបាត់បង់សមត្ថភាព។

**១.លក្ខខណ្ឌនៃការចូលនិវត្តន៍**

យោធិនអាជីពទាំងពីរភេទនៃយោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវដាក់ឲ្យចូលនិវត្តន៍អាស្រ័យតាមលក្ខខណ្ឌដូចខាងក្រោម[46]៖

<u>នាយទាហាន</u>

-ឋានន្តរស័ក្តិវរសេនីយ៍ឯក ឬវរនាវីឯកឡើងទៅ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៦០ឆ្នាំ។

[45] មាត្រា២៣ នៃអនុក្រឹត្យស្តីពី បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

[46] មាត្រា ៣ នៃអនុក្រឹត្យស្តីពី ការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន ទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ

-ឋានន្តរស័ក្តិវរសេនីយ៍ទោ ឬវរនាវីទោ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៨ឆ្នាំ។

-ឋានន្តរស័ក្តិវរសេនីយ៍ត្រី ឬវរនាវីត្រី ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៥ឆ្នាំ។

-ឋានន្តរស័ក្តិអនុសេនីយ៍ឯក ឬអនុនាវីឯក ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៣ឆ្នាំ។

-ឋានន្តរស័ក្តិអនុសេនីយ៍ទោ ឬអនុនាវីទោ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៨ឆ្នាំ។

-ឋានន្តរស័ក្តិអនុសេនីយ៍ត្រី ឬអនុនាវីត្រី ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៦ឆ្នាំ។

-ឋានន្តរស័ក្តិនាយចំណាង់ ឬនាយនាវីចំណាង់ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥៣ឆ្នាំ។

<u>នាយទាហានរង</u>

-ឋានន្តរស័ក្តិព្រិន្ទបាលឯក ឬនាយចក្របាលឯក ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥២ឆ្នាំ។

-ឋានន្តរស័ក្តិព្រិន្ទបាលទោ ឬនាយចក្របាលទោ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥១ឆ្នាំ។

-ឋានន្តរស័ក្តិពលបាលឯក ឬចក្របាលឯក ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៥០ឆ្នាំ។

-ឋានន្តរស័ក្តិពលបាលទោ ឬចក្របាលទោ ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៣៩ឆ្នាំ។

-ឋានន្តរស័ក្តិពលបាលត្រី ឬចក្របាលត្រី ត្រូវចូលនិវត្តន៍នៅពេលដល់អាយុ ៣៨ឆ្នាំ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវី វីរជន និងវរសេនីយ៍ឯក កងទ័ពជើងអាកាស វរសេនីយ៍ឯកកងទ័ពជើងទឹក ដែលមានគុណសម្បត្តិនិងសមត្ថភាព ឬជាអ្នកជំនាញឯកទេសទោះបីដល់អាយុចូលនិវត្តន៍ក៏ដោយ តាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ។ យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ អាចស្នើសុំចូលនិវត្តន៍មុនពេលកំណត់បាន។

លក្ខខណ្ឌជាក់ស្តែងនៃការកំណត់ប្រភេទកម្រិតបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីព ត្រូវបានកំណត់កម្រិតជាបីថ្នាក់៖

- កម្រិតថ្នាក់ទី១៖ គឺជាយោធិនអាជីព ដែលបានបម្រើការងារ នាំឲ្យទ្រុឌទ្រោមទាំងស្រុងនៃសរីរាងការយសំខាន់ៗ។ ជនបាត់បង់សមត្ថភាពការងារ ពុំអាចធ្វើការងារបម្រើខ្លួនឯងបាន និងតម្រូវឲ្យអ្នកដទៃជួយជាអចិន្ត្រៃយ៍។ យោធិននេះ ទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៨០% ។
- កម្រិតថ្នាក់ទី២៖ គឺជាយោធិនអាជីព ដែលបានបម្រើការងារ នាំឲ្យមានការទ្រុឌទ្រោមធ្ងន់ ឬស្រាលនៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ។ ជនបាត់បង់សមត្ថភាពការងារ អាចប្រកបការងារបាននៅក្នុងករណីពិសេស សាមីជនអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់មួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃ ដោយមិនចាំបាច់ពឹងផ្អែកជំនួយអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ។ យោធិននេះ ទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៦០%។

- កម្រិតថ្នាក់ទី៣៖ គឺជាយោធិនអាជីព ដែលអាចបម្រើការងារបាននៅក្នុងករណីដែលបាន កំណត់ ដោយមិនចាំបាច់មានអ្នកដទៃជួយនៅក្នុងជីវភាពប្រចាំថ្ងៃឡើយ។ យោធិននេះ ទទួលបានកម្រិតថ្នាក់បាត់បង់សមត្ថភាពការងារលើសពី ៤០%។

**២.ការទទួលបានរបបសោធន**

ប្រាក់សោធននិវត្តន៍រួមមាន បៀវត្សរ៍ហានន្តរស័ក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើ បៀវត្សរ៍ហានន្តរស័ក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ(បើមាន) បូកប្រាក់បំណាច់តំបន់(បើមាន)។

- របបសោធននិវត្តន៍

យោធិនអាជីពទាំងពីរភេទនៃយោធិននៃកងយោពលខេមរភូមិន្ទ អាចទទួលបានរបប សោធននិវត្តន៍អប្បបរមា ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ចំពោះយោធិនអាជីពដែលបានបម្រើការងារនៅតំបន់លំបាកការងារគ្រោះថ្នាក់ ឬការងារ ប៉ះពាល់សុខភាពយ៉ាងតិច ១០ឆ្នាំ ចំពោះបុរសនិង ៨ឆ្នាំ ចំពោះនារី។
- ចំពោះយោធិនអាជីពដែលបានបម្រើការងារមិនប៉ះពាល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ ចំនួន ២០ឆ្នាំ ចំពោះបុរស និងចំនួន ១៥ឆ្នាំ ចំពោះនារី ។

ប្រាក់សោធននិវត្តន៍អប្បបរមាប្រចាំខែស្មើ៥០% នៃបៀវត្សរ៍ហានន្តរស័ក្តិប្រចាំខែចុងក្រោយ។ ប្រាក់នេះ ត្រូវបានអត្រាបន្ថែម១ឆ្នាំ ២%ទៀត រាប់ចាប់ពីឆ្នាំទី ៤ នៃរយៈពេលបម្រើការងារយោធា ឬ ចាប់ពីឆ្នាំទី ៦ នៃរយៈពេលបម្រើការងាររដ្ឋ។ តែសរុបមិនត្រូវលើស ៨០% នៃប្រាក់សោធននិវត្តន៍ អតិបរមាឡើយ។

យោធិនអាជីពទាំងពីរភេទនៃយោធិននៃកងយោពលខេមរភូមិន្ទ អាចទទួលបានរបប សោធននិវត្តន៍អតិបរមា ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ចំពោះយោធិនអាជីពដែលបានបម្រើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារ ប៉ះពាល់សុខភាពយ៉ាងតិច ១៥ឆ្នាំ ចំពោះបុរសនិង ១២ឆ្នាំ ចំពោះនារី។
- ចំពោះយោធិនអាជីពដែលបានបម្រើការងារមិនប៉ះពាល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗ លើសពី ២០ឆ្នាំ ចំពោះបុរស និងលើសពី ១៥ឆ្នាំ ចំពោះនារី ។
- ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវរជនក្នុងកងយោធពលខេមរភូមិន្ទ ដែលបានបំពេញ លក្ខខណ្ឌដូចចំណុចរបបសោធននិវត្តន៍អប្បបរមាខាងលើ ត្រូវទទួលបានរបបសោធន អតិបរមា។
- យោធិនពិការដែលនៅបម្រើការងារជាប់រហូតដល់អាយុចូលនិវត្តន៍។

ប្រាក់សោធននិវត្តន៍អតិបរមាស្មើនឹង ៨០% នៃបៀវត្សរ៍ហានន្តរស័ក្តិប្រចាំខែចុងក្រោយ។

- របបសោធនបាត់បង់សមត្ថភាពការងារ

ប្រាក់សោធនបាត់បង់សមត្ថភាពការងារ រួមមាន បៀវត្សរ៍ឋានន្តរស័ក្តិ ត្រូវបានបូកបន្ថែមជាមួយប្រាក់ឧបត្ថម្ភលើបៀវត្សរ៍ឋានន្តរស័ក្តិ បូកប្រាក់ហូបប្រចាំខែ បូកប្រាក់បំណាច់មុខងារ(បើមាន) បូកប្រាក់បំណាច់តំបន់(បើមាន)។

របបសោធនបាត់បង់សមត្ថភាពការងារ យោធិនអាជីពដែលអាចទទួល របបសោធនបាត់បង់សមត្ថភាពការងារបានជាប្រចាំខែ លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ៖

- ដោយសារជំងឺរ៉ាំរ៉ៃ ចាស់ជរា គ្រោះថ្នាក់ផ្សេងៗតែមិនបាត់បង់សរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិនពិការអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារបាន លុះត្រាតែបានបម្រើការងាររដ្ឋរួមយ៉ាងតិច ១៥ឆ្នាំ ចំពោះបុរស និង ១០ឆ្នាំ ចំពោះនារី
- ដោយសារបំពេញភារកិច្ចឬធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាព ដោយពុំគិតពីអាយុ និងរយៈពេលបម្រើការងាររដ្ឋរួមឡើយ ហើយត្រូវបានកម្រិតការបាត់បង់សមត្ថភាពការងារជា ៣ ថ្នាក់៖ ថ្នាក់ទី១ បាត់បង់សមត្ថភាពការងារលើសពី ៨០% ថ្នាក់ទី២ បាត់បង់សមត្ថភាពការងារលើសពី ៦០% និងថ្នាក់ទី៣ បាត់បង់សមត្ថភាពការងារលើសពី ៤០%។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែ ចែកចេញជាពីរផ្នែកដូចខាងក្រោម[47]៖

- ប្រាក់សោធនបាត់បង់សមត្ថភាពការងារប្រចាំខែស្មើនឹង ៥០% នៃបៀវត្សរ៍ឋានន្តរស័ក្តិចុងក្រោយត្រូវបានផ្តល់ចំពោះ៖ យោធិនដែលបំពេញលក្ខខណ្ឌដោយសារជំងឺរ៉ាំរ៉ៃ ចាស់ជរា គ្រោះថ្នាក់ផ្សេងៗតែមិនបាត់បង់សរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជាយោធិនពិការអាចទទួលរបបសោធនបាត់បង់សមត្ថភាពការងារបាន លុះត្រាតែបានបម្រើការងាររដ្ឋរួមយ៉ាងតិច ១៥ឆ្នាំ ចំពោះបុរស និង ១០ឆ្នាំ ចំពោះនារី និងយោធិនដែលបានបម្រើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពចំនួន ១០ឆ្នាំ ចំពោះបុរស និង ៨ឆ្នាំ ចំពោះនារី។ ប្រាក់សោធនបាត់បង់សមត្ថភាពការងារអប្បបរមាប្រចាំខែស្មើ ៥០%នៃបៀវត្សរ៍ឋានន្តរស័ក្តិប្រចាំខែចុងក្រោយ ត្រូវបានអត្រាបន្ថែម ១ឆ្នាំ ១,៥% ទៀត រាប់ចាប់ពីឆ្នាំទី៤ នៃរយៈពេលបម្រើការងារយោធា ឬចាប់ពីឆ្នាំទី៦ នៃរយៈពេលបម្រើការងាររដ្ឋ។ តែប្រាក់សរុបមិនត្រូវលើស ៦០% នៃប្រាក់សោធនបាត់បង់សមត្ថភាពការងារឡើយ។
- ប្រាក់សោធនបាត់បង់សមត្ថភាពការងារ៖

[47] មាត្រា ១២ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ ទទួលបាន១០០%នៃបៀវត្សហានន្តរស័ក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន
- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី២ ទទួលបាន៨០%នៃបៀវត្សហានន្តរស័ក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន
- យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី៣ ទទួលបាន៦០%នៃបៀវត្សហានន្តរស័ក្តិប្រចាំខែចុងក្រោយរបស់សាមីខ្លួន។

ប្រាក់សោធនបាត់បង់សមត្ថភាពការងារទាបបំផុតមិនត្រូវតិចជាង៩០% នៃបៀវត្សហានន្តរស័ក្តិអប្បបរមារបស់នាយទាហានឡើយ។ យោធិនដែលធ្វើការនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពត្រូវបានអត្រាបន្ថែម ១៥% នៃបៀវត្សហានន្តរស័ក្តិថែមទៀត។ យោធិនបាត់បង់សមត្ថភាពការងារថ្នាក់ទី១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែបន្ថែមសម្រាប់អ្នកជំនួយកិច្ចការក្នុងផ្ទះស្មើនឹងប្រាក់បៀវត្សអប្បបរមា និងប្រាក់បំណាច់របស់យុទ្ធជនម្នាក់។ ចំពោះវីរជននៃកងយោធពលខេមរភូមិន្ទត្រូវទទួលបានអត្រាបន្ថែម ១០% នៃបៀវត្សហានន្តរស័ក្តិថែមទៀត។

របបបន្ថែមផ្សេងទៀត ចំពោះយោធិនបាត់បង់សមត្ថភាពការងាររួមមាន[48]៖ ត្រូវបានទទួលប្រាក់បន្ថែម ១លើកស្មើនឹង ៦ខែ នៃបៀវត្សប្រចាំខែចុងក្រោយរបស់សាមីខ្លួន ហើយបើគ្មានទីបង្អែករដ្ឋទទួលបន្ទុកយកទៅស្នាក់នៅមជ្ឈមណ្ឌលរបស់រដ្ឋ ប៉ុន្តែសាមីខ្លួនទទួលប្រាក់បន្ថែមតែ ៥០% ប៉ុណ្ណោះ ហើយពេលមានជំងឺ គ្រោះថ្នាក់ ឬស្លាប់ត្រូវបានទទួលរបបធានារ៉ាប់រងសង្គមដូចយោធិនចូលនិវត្តន៍ដែរ។

### ខ.លក្ខខណ្ឌនៃការចូលនិវត្តន៍ និងរបបសោធនចំពោះមន្ត្រីនគរបាលជាតិ

#### ១.លក្ខខណ្ឌនៃការចូលនិវត្តន៍

មន្ត្រីនគរបាលជាតិកម្ពុជាទាំងពីរភេទ ដែលបានបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ហើយត្រូវបានដាក់ឲ្យចូលនិវត្តន៍[49]៖

- ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលមានហានន្តរស័ក្តិថ្នាក់វរសេនីយ៍ទោចុះ ត្រូវចូលនិវត្តន៍នៅអាយុ ៥៥ ឆ្នាំ
- ចំពោះមន្ត្រីនគរបាលជាតិកម្ពុជាដែលមានហានន្តរស័ក្តិថ្នាក់វរសេនីយ៍ឯកឡើង ត្រូវចូលនិវត្តន៍នៅអាយុ ៦០ ឆ្នាំ។

ការដាក់ឲ្យចូលនិវត្តន៍ត្រូវសម្រេចដោយ៖

- ព្រះរាជក្រឹត្យ ចំពោះថ្នាក់ឧត្តមសេនីយ៍

[48] មាត្រា ១៣ នៃច្បាប់ស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
[49] មាត្រា ៣៤ នៃព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

- អនុក្រឹត្យ ចំពោះថ្នាក់វរសេនីយ៍ឯក
- ប្រកាសរបស់ក្រសួងមហាផ្ទៃ ចំពោះថ្នាក់វរសេនីយ៍ទោ ចុះ

**២.ការទទួលបានរបបសោធន**

- **របបសោធននិវត្តន៍**

មន្ត្រីនគរបាលទាំងពីរភេទ អាចទទួលរបបសោធននិវត្តន៍អប្បបរមាបានតាមលក្ខខណ្ឌដូចខាងក្រោម៖

- នគរបាលទាំងពីរភេទ ដែលបម្រើក្នុងក្របខ័ណ្ឌកងកម្លាំងនគរបាលកម្ពុជា អាចទទួលរបបសោធននិវត្តន៍បានលុះត្រាតែ បុរសត្រូវមានអាយុ ៥៥ឆ្នាំ និងមានរយៈពេលបម្រើការងាររួម ២០ឆ្នាំ ចំណែក នារីត្រូវមានអាយុ ៥០ឆ្នាំ និងមានរយៈពេលបម្រើការងាររួម ១៥ឆ្នាំ។
- នគរបាលដែលបានបម្រើការងារនៅតំបន់លំបាក និងគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពចំនួន ១០ឆ្នាំ ចំពោះបុរស និង ៨ឆ្នាំចំពោះនារី នោះចំពោះអាយុ និងមានរយៈពេលបម្រើការងាររួម ២០ឆ្នាំចំពោះបុរស មានរយៈពេលបម្រើការងាររួម១៥ឆ្នាំចំពោះនារី ត្រូវបានបន្ថយចំនួន ៤ ឆ្នាំ។
- នគរបាលដែលបម្រើការងារនៅតំបន់ដែលលំបាក និងគ្រោះថ្នាក់ ឬប៉ះពាល់សុខភាព១២ឆ្នាំ ចំពោះបុរស និង ៩ឆ្នាំ ចំពោះនារី នោះអាយុ៥៥ឆ្នាំចំពោះបុរស អាយុ៥០ឆ្នាំចំពោះនារី ត្រូវបានបន្ថយចំនួន ៥ឆ្នាំ ដោយមិនគិតអំពីរយៈពេលបម្រើការងាររួមឡើយ។
- មិនគិតពីអាយុ និងរយៈពេលបម្រើការងាររួមចំពោះនគរបាលដែលបានបម្រើការងារនៅតំបន់ដែលលំបាក និងគ្រោះថ្នាក់ ឬប៉ះពាល់សុខភាពចំនួន ១៥ឆ្នាំ ចំពោះបុរស និង ១០ឆ្នាំ ចំពោះនារី ឬបម្រើការងារក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជាចំនួន២០ឆ្នាំ ចំពោះបុរស និង១៥ឆ្នាំ ចំពោះនារី។

មន្ត្រីនគរបាលទាំងពីរភេទ អាចទទួលរបបសោធននិវត្តន៍អប្បបរមាបានតាមលក្ខខណ្ឌដូចខាងក្រោម៖

- បុរសត្រូវមានអាយុ៥៥ឆ្នាំនិងរយៈពេលបម្រើការងារក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជាចំនួន២០ឆ្នាំ។ នារីត្រូវមានអាយុ ៥០ឆ្នាំ និងរយៈពេលបម្រើការងារក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជា ចំនួន ១៥ឆ្នាំ។
- បុរសត្រូវមានអាយុ ៥០ឆ្នាំ និងរយៈពេលបម្រើការងារនៅកន្លែងគ្រោះថ្នាក់ ឬប៉ះពាល់សុខភាព ចំនួន១៥ឆ្នាំ ក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជា។ នារីត្រូវមានអាយុ ៤៥ឆ្នាំ រយៈពេលបម្រើការងារនៅកន្លែងលំបាក និងគ្រោះថ្នាក់ឬប៉ះពាល់សុខភាព ចំនួន១០ឆ្នាំ ក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជា។

- កម្មាភិបាលបម្រើការងារ មុនថ្ងៃ៧ មករា ឆ្នាំ១៩៧៩ និងនគរបាលពិការដែលនៅបម្រើការងារក្នុងកងកម្លាំងនគរបាលប្រជាជនកម្ពុជា ជាប់រហូតដល់ថ្ងៃចូលនិវត្តន៍។

- **របបសោធនបាត់បង់សមត្ថភាពពលកម្ម**

មន្ត្រីនគរបាលទាំងពីរភេទ ដែលបាត់បង់សមត្ថភាពដោយសារជំងឺ រ៉ាំរ៉ៃ ជរា គ្រោះថ្នាក់ផ្សេងៗ តែមិនបណ្តាលឲ្យបាត់បង់នូវសរីរាង្គណាមួយ ហើយមិនគ្រប់លក្ខណៈជានគរបាលពិការអាចទទួលរបបសោធនបាត់បង់សមត្ថភាពពលកម្មតាមលក្ខខណ្ឌដូចខាងក្រោម៖

- នគរបាលទាំងពីរភេទដែលបាត់បង់សមត្ថភាពពលកម្ម ដោយសារជំងឺ ជរា គ្រោះថ្នាក់ផ្សេងៗ តែមិនបណ្តាលឲ្យបាត់បង់ នូវសរីរាង្គណាមួយហើយមិនគ្រប់លក្ខណៈជាជនពិការ អាចទទួលរបបបាត់បង់សមត្ថភាពពលកម្មបាន លុះត្រាតែបានបម្រើការងាររួមយ៉ាងតិច ១៥ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំ ចំពោះនារី។
- នគរបាលដែលបាត់បង់សមត្ថភាពពលកម្មដោយសារការងារ ឬបេសកកម្ម ឬបម្រើការងារនៅតំបន់ដែលលំបាក និងគ្រោះថ្នាក់ ឬប៉ះពាល់សុខភាព

កម្រិតនៃការបាត់បង់សមត្ថភាពពលកម្មកំណត់ជាបីថ្នាក់ រួមមាន៖ ថ្នាក់ទី១ កម្រិតបាត់បង់សមត្ថភាពពលកម្មពី៨១%ទៅ១០០% ថ្នាក់ទី២ កម្រិតបាត់បង់សមត្ថភាពពលកម្មពី៦១% ទៅ៨០% និងថ្នាក់ទី៣ កម្រិតបាត់បង់សមត្ថភាពពលកម្មពី៤១%ទៅ៦០% ។ ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្ម ប្រចាំខែកំណត់ដូចខាងក្រោម៖

- ថ្នាក់ទី១ ស្មើនឹង ៧០% នៃបៀវត្សឋានន្តរស័ក្តិ
- ថ្នាក់ទី២ ស្មើនឹង ៦០% នៃបៀវត្សឋានន្តរស័ក្តិ
- ថ្នាក់ទី៣ ស្មើនឹង ៥០% នៃបៀវត្សឋានន្តរស័ក្តិ

ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មទាបបំផុតមិនត្រូវតិចជាងបៀវត្សឋានន្តរស័ក្តិអប្បបរមាឡើយចំពោះនគរបាលបាត់បង់សមត្ថភាពពលកម្មថ្នាក់ទី១ បានទទួលរបបបន្ថែមប្រចាំខែ ៥០% នៃប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មរបស់សាមីខ្លួនថែមទៀត។ ចំពោះវីរជនត្រូវបានអត្រាបន្ថែម ១០% នៃបៀវត្សឋានន្តរស័ក្តិថែមទៀត។ ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មប្រចាំខែត្រូវគិតទាំងប្រាក់បំណាច់តំបន់ដែលសាមីខ្លួនរស់នៅ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមការកំណត់របស់រដ្ឋ។

របបបន្ថែមផ្សេងៗ ចំពោះមន្ត្រីនគរបាលបាត់បង់សមត្ថភាពពលកម្មរួមមាន៖ ឧបត្ថម្ភមួយលើកនូវទឹកប្រាក់ស្មើនឹង ៤ទៅ៥ខែនៃបៀវត្សសរុបប្រចាំខែ ប្រសិនបើគ្មានបង្អែក រដ្ឋត្រូវទទួលយកចិញ្ចឹមក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ឯប្រាក់បន្ថែម ៥០% នៃប្រាក់សោធនរបស់សាមីខ្លួន ហើយពេល

មានជំងឺសើរើគ្រោះថ្នាក់ ឬស្លាប់ត្រូវបានទទួលរបបធានារ៉ាប់រងសង្គមដូចមន្ត្រីនគរបាលចូលនិវត្តន៍ដែរ។

**គ.របបឧបត្ថម្ភយោធិន មន្ត្រីនគរបាលជាតិ ដែលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន**

**១.របបឧបត្ថម្ភយោធិនដែលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន**

យោធិនពលី សំដៅដល់យោធិន ដែលបានបាត់បង់ជីវិត នៅពេលដែលបានទទួលបញ្ជាទៅប្រយុទ្ធបម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធន៍មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ។

យោធិនពលី ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ[50]៖

- ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ២៦ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនពលីជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ខែនៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនពលី
- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែ ជូនដល់ប្រពន្ធ ឬប្ដី កូនបង្កើត ឪពុក ម្ដាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនពលី ។

យោធិនមរណៈ សំដៅដល់យោធិន ដែលបានទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិត ដោយសារការងារទាំងនោះ ឬដោយសារជំងឺ។

យោធិនមរណៈ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ[51]៖

- ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៧ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនមរណៈជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១២ខែនៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនមរណៈ
- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែ ជូនដល់ប្រពន្ធ ឬប្ដី កូនបង្កើត ឪពុក ម្ដាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនមរណៈ ។

យោធិនបង្កស្លាប់ សំដៅដល់យោធិនដែលបាត់បង់ជីវិតដោយធ្វើអត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់ ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬប្រយោល មកពីល្មើសច្បាប់វិន័យ និងបទបញ្ជា។

---

[50] មាត្រា ៧ នៃអនុក្រឹត្យស្ដីពី របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

[51] មាត្រា ៨ នៃអនុក្រឹត្យស្ដីពី របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

យោធិនបង្កស្លាប់ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ[52]៖

- ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៥ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនបង្កស្លាប់ជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជាឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកផ្តាច់ជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១២ខែនៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់យោធិនបង្កស្លាប់។

យោធិនបាត់ខ្លួន សំដៅដល់យោធិន ដែលបានទទួលបញ្ជាឲ្យទៅប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញឯកទេស និងធ្វើការពិសោធន៍ប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬរស់ រត់ចោលជួរ រត់ចូលខ្មាំងឬត្រូវខ្មាំងចាប់។

យោធិនបាត់ខ្លួន ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ[53]៖

- ប្រាក់ឧបត្ថម្ភជូនគ្រួសារស្មើនឹងទឹកប្រាក់បៀវត្សមូលដ្ឋានចុងក្រោយ របស់យោធិនបាត់ខ្លួនដោយគិតទាំងរបបអង្គរប្រចាំខែ ចាប់ពីខែ ឆ្នាំ បាត់ខ្លួនរហូតដល់គម្រប់ ១២ ខែ
- ក្រោយ១២ខែ គិតពីខែ ឆ្នាំបាត់ខ្លួនមក គ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជាយោធិនពលី លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់បូជាសព ឬបញ្ចុះសពចេញ

ក្នុងអំឡុងពេលកំពុងទទួលរបបឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើប្រសិនបើយោធិនបាត់ខ្លួនបានវិលត្រឡប់មកកងឯកភាពដើម ឬវិលទៅមូលដ្ឋានវិញ ការផ្តល់របបឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែ ឆ្នាំ ដែលយោធិនបាត់ខ្លួន នោះមានមុខ។

ជនដែលមានគ្រប់លក្ខណៈសម្បត្តិ ដែលអាចទទួលរបបឧបត្ថម្ភពីយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន មានដូចតទៅ៖

- ឪពុក និងម្តាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមារ របស់យោធិន បើសិនជាយោធិននោះនៅលីវ
- ប្រពន្ធ ឬប្តី របស់យោធិនមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត
- កូនបង្កើត របស់យោធិនមានសំបុត្រកំណើតអាយុ ១៨ឆ្នាំចុះ និងមានអាយុ ១៨ឆ្នាំឡើង ត្រូវមានលិខិតបញ្ជាក់កំពុងបន្តការសិក្សា ហើយពុំទាន់ទទួលនូវអាហារូបករណ៍ ឬមានលិខិតបញ្ជាក់ពិការភាព
- ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈ១នាក់ ឬ ២នាក់ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ។

[52] មាត្រា ៩ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

[53] មាត្រា ១០ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

**២.របបឧបត្ថម្ភមន្ត្រីនគរបាលដែលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន**

មន្ត្រីនគរបាលពលី សំដៅដល់មន្ត្រីនគរបាលជាតិដែលបាត់បង់ជីវិតនៅពេលដែលបានទទួលបានបញ្ជាបំពេញបេសកកម្ម ហ៊ីកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់។ មន្ត្រីនគរបាលពលីត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម[54]៖

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៩ខែ នៃបៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលពលី ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលពលី
- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលពលី

មន្ត្រីនគរបាលមរណៈ សំដៅដល់មន្ត្រីនគរបាលជាតិដែលបំពេញភារកិច្ចក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំងនោះ ឬដោយសារជំងឺ។ មន្ត្រីនគរបាលមរណៈត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម[55]៖

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៧ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលមរណៈជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១២ខែនៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលមរណៈ
- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែ ជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលមរណៈ

មន្ត្រីនគរបាលបង្កស្លាប់ សំដៅដល់មន្ត្រីនគរបាលជាតិដែលបានបាត់បង់ជីវិតដោយធ្វើអត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់បាត់បង់ជីវិតដោយផ្ទាល់ ឬដោយប្រយោលដែលល្មើសច្បាប់វិន័យ និងបទបញ្ជា។ មន្ត្រីនគរបាលបង្កស្លាប់ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម[56]៖

---

[54] មាត្រា ៧ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈបង្កស្លាប់ បាត់ខ្លួន និងពិការ

[55] មាត្រា ៨ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈបង្កស្លាប់ បាត់ខ្លួន និងពិការ

[56] មាត្រា ៩ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈបង្កស្លាប់ បាត់ខ្លួន និងពិការ

- ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៥ខែ នៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភមួយលើកផ្តាច់ជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១២ខែនៃប្រាក់បៀវត្សមូលដ្ឋានចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់។

មន្ត្រីនគរបាលបាត់ខ្លួន សំដៅដល់មន្ត្រីនគរបាល ដែលបានទទួលបញ្ជាបំពេញបេសកកម្ម ហ្វឹកហាត់មុខជំនាញឯកទេស និងធ្វើការពិសោធប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬរស់ រត់ចោលជួរ ឬត្រូវជនល្មើសចាប់។ មន្ត្រីនគរបាលបាត់ខ្លួនត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម[57]៖

- បន្តបើកប្រាក់បៀវត្សរបស់មន្ត្រីនគរបាលបាត់ខ្លួនព្រមទាំងរបបអង្ករប្រចាំខែជូនគ្រួសារចាប់ពីខែ ឆ្នាំ បាត់ខ្លួនរហូតដល់គម្រប់ ១២ ខែ
- ក្រោយ១២ខែ គិតចាប់ពីខែ ឆ្នាំបាត់ខ្លួនមក នៅតែពុំឃើញវិលត្រឡប់មកវិញត្រូវបានកំណត់ទទួលស្គាល់ជាមន្ត្រីនគរបាលពលី ហើយគ្រួសារគ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជាមន្ត្រីនគរបាលពលីដែរ លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់បូជា ឬបញ្ចុះសព
- ក្នុងអំឡុងពេលកំពុងទទួលរបបឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើ ប្រសិនបើមន្ត្រីនគរបាលបាត់ខ្លួនបានវិលត្រឡប់មកអង្គភាពដើម ឬវិលទៅលំនៅដ្ឋានវិញ ការផ្តល់ប្រាក់ឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែ ឆ្នាំ ដែលមន្ត្រីនគរបាលបាត់ខ្លួន នោះមានមុខ។ ក្នុងករណីបានទទួលស្គាល់ជាមន្ត្រីនគរបាលពលីដោយបានកាត់ផ្តាច់ក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃរួចហើយ ស្រាប់តែមន្ត្រីនគរបាលបាត់ខ្លួននោះបានវិលត្រឡប់មកវិញ ហើយចង់ចូលបម្រើការងារបន្តទៀត ត្រូវបានបញ្ចូលក្របខ័ណ្ឌជាថ្មីដោយទទួលឋានន្តរស័ក្តិ និងប្រាក់បៀវត្សដូចមុនពេលបាត់ខ្លួន។

ជនដែលមានគ្រប់លក្ខណ:សម្បត្តិ ដែលអាចទទួលរបបឧបត្ថម្ភពីមន្ត្រីនគរបាលពលី មរណៈបង្កស្លាប់ បាត់ខ្លួន មានដូចតទៅ៖

- ឪពុក និងម្តាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមាររបស់មន្ត្រីនគរបាលជាតិ បើសិនជាយោធិននោះនៅលីវ
- ប្រពន្ធ ឬប្តី របស់មន្ត្រីនគរបាលជាតិដែលមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត

[57] មាត្រា ១០ នៃអនុក្រឹត្យស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈបង្កស្លាប់ បាត់ខ្លួននិងពិការ

- កូនបង្កើត របស់មន្ត្រីនគរបាលជាតិដែលមានសំបុត្រកំណើតអាយុក្រោម ១៨ឆ្នាំចុះ និងមានអាយុ ១៨ឆ្នាំឡើង ដែលមានលិខិតបញ្ជាក់កំពុងបន្តការសិក្សា ហើយពុំទាន់ទទួលអាហារូបករណ៍ ឬកូនដែលពិការភាពមានលិខិតបញ្ជាក់ត្រឹមត្រូវ
- ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈ ២នាក់ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ។

## ផ្នែកទី២ ៖ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់ការគាំពារចំពោះគ្រោះថ្នាក់ ឬជំងឺ ឬបញ្ហាសុខភាពដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ។ រាជរដ្ឋាភិបាលបានសម្រេចដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន តាមរយៈការចេញអនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បន្ថែមលើព្រះរាជក្រឹត្យស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈនិងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលមានគោលដៅផ្តល់នូវតាវកាលិកសន្តិសុខសង្គម ផ្នែកថែទាំសុខភាពចំពោះអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ របបនេះ នឹងផ្តល់ជូនអតីតមន្ត្រីរាជការ និងអតីតយុទ្ធជននូវសេវាថែទាំសុខភាពទូទៅរួមមាន ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសពការផ្តល់សេវាបង្ការសុខភាព សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ការកំណត់ជំងឺរ៉ាំរ៉ៃ ជាដើម។

### កថាខណ្ឌទី១ ៖ សេវាថែទាំសុខភាព

ដើម្បីទទួលបានសេវាថែទាំសុខភាព អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ហើយដែលបានបង់ភាគទាន ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន ឬអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ដល់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។ ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬអង្គភាពមានសមត្ថកិច្ច ត្រូវផ្តល់ទិន្នន័យអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដែលបានធ្វើបច្ចុប្បន្នកម្មរួច មក ប.ស.ស រៀងរាល់៦ខែ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្នែកហានិភ័យការងារ និងថែទាំសុខភាព។ គ្រប់មូលដ្ឋានសុខាភិបាលទាំងអស់ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវផ្តល់កិច្ចសហការជាមួយ ប.ស.ស ក្នុងការគ្រប់គ្រង និងផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិករបស់ក្រសួងសុខាភិបាល។

**ក.គោលការណ៍ផ្នែកសេវា**

**១.សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ រួមមាន ការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជំងឺក្រៅ សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល សេវាព្យាបាលដោយស្តុំឬការព្យាបាលដោយចលនា និងសេវាស្តារនីតិសម្បទា និងសេវាសង្គ្រោះបន្ទាន់។ សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានផ្តល់ជូនដូចខាងក្រោមៈ

-ចំពោះការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ រួមមានៈ សេវាព្យាបាលនិងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត ឧបករណ៍ផ្នែកសល្យសាស្ត្រនិងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល ឱសថតាមវេជ្ជបញ្ជា បន្ទប់សម្រាកព្យាបាល(តាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល)។

-ចំពោះការផ្តល់សេវាពិគ្រោះជំងឺក្រៅ រួមមានៈ សេវាព្យាបាលនិងថែទាំតាមបច្ចេកវិជ្ជាជីវៈវេជ្ជសាស្ត្រ សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាលឱសថតាមវេជ្ជបញ្ជា។

-ចំពោះការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល។

-ចំពោះការផ្តល់សេវាព្យាបាលដោយស្តុំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទាដទៃទៀត។

-ចំពោះសេវាសង្គ្រោះបន្ទាន់ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាល ដែលស្ថិតនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះ មិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជនរងគ្រោះឬអ្នកតំណាង ត្រូវជូនដំណឹងជាបន្ទាន់មកប.ស.ស។

សេវាព្យាបាលនិងថែទាំ ដែលមានការផ្តល់សេវាព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ ការផ្តល់សេវាពិគ្រោះជំងឺក្រៅ ការផ្តល់សេវាសម្រាលកូន និងការព្យាបាលថែទាំមុន និងក្រោយពេលសម្រាល ការផ្តល់សេវាព្យាបាលដោយស្តុំ ឬការព្យាបាលដោយចលនា ឬសេវាស្តារនីតិសម្បទា សេវាសង្គ្រោះបន្ទាន់ ត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀត មិនត្រូវបានផ្តល់ជូនឡើយ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់។

**២.សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព**

ការផ្តល់សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។ ការផ្តល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជា ឬសេវាបញ្ជូនសព ត្រូវផ្តល់ជូនតាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។

**៣.សេវាបង្ការសុខភាព**

ការផ្តល់សេវាបង្ការសុខភាពអាចត្រូវបានផ្តល់ដោយ ប.ស.ស កម្មវិធីបង្ការសុខភាពឬកម្មវិធីបង្ការសុខភាពដទៃផ្សេងទៀត។ សេវាបង្ការសុខភាពដែលផ្តល់ដោយ ប.ស.ស ត្រូវអនុវត្តដូចគ្នានឹងកម្មវិធីបង្ការសុខភាពផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ សេវាបង្ការសុខភាពដែលត្រូវដាក់បញ្ចូល រួមមាន៖ សេវាចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួត សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស សេវាចាក់សេរ៉ូមប្រឆាំងពិសពស់ សេវាពិនិត្យឈាមរកជំងឺពក ក សេវាពិនិត្យឈាម កំណត់អបោធាតុមហារីកក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមីនិងឬក្រោយការព្យាបាលជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិច។

សេវាបង្ការដែលបានកំណត់ខាងលើ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬវិទ្យាស្ថានសាធារណៈ។ សេវានេះមិនត្រូវបានទូទាត់វិញ ចំពោះការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនក្នុងឬក្រៅប្រទេសឡើយ លើកលែងតែមានការអនុញ្ញាតជាមុនពី ប.ស.ស។

**ខ.សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល**

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររួមមាន ការព្យាបាលដោយឥតបង់ថ្លៃដែលកំណត់នៅក្នុងគោលនយោបាយសុខាភិបាលជាតិ ការពិនិត្យសុខភាពទូទៅ ការថែទាំធ្មេញ(ការសម្អាត ការប៉ះ និងការដាក់ធ្មេញ) សេវាប្តូរភេទ ការព្យាបាល ឬវះកាត់កែសម្ផស្ស ឬកែលម្អផ្នែកណាមួយនៃរាងកាយ សេវាបង្កកំណើតសិប្បនិម្មិត ការព្យាបាលអសមត្ថភាពផ្តល់កំណើត ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ ការព្យាបាលដោយខ្លួនឯង ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត ការព្យាបាលញៀនសុរាឬការព្យាបាលផ្តាច់គ្រឿងញៀន ការវះកាត់ដាក់គ្រាប់ភ្នែកសិប្បនិម្មិត ការវះកាត់បេះដូងឬសរសៃបេះដូង និងការលាងឈាម។

សេវាឬការព្យាបាលដែលមិនរាប់បញ្ចូល ដូចបានរៀបរាប់ចំណុចខាងលើ ត្រូវបានផ្តល់ជូនក្នុងករណីត្រូវសង្គ្រោះបន្ទាន់។

**គ.ការកំណត់ជំងឺរ៉ាំរ៉ៃ**

ការផ្ដល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ និងត្រូវប្រើប្រាស់តែឱសថសារវន្តដែលកំណត់ដោយក្រសួងសុខាភិបាលតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុករបស់សាមីជន។ បញ្ជីជំងឺរ៉ាំរ៉ៃ ត្រូវអនុវត្តដូចគ្នានឹងបញ្ជីជំងឺរ៉ាំរ៉ៃនៃផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ។ ប្រភេទជំងឺរ៉ាំរ៉ៃ ដែលត្រូវកំណត់រួមមាន៖ ជំងឺខ្សោយបេះដូង ជំងឺសាច់ដុំបេះដូង ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ ជំងឺតំរងនោមរ៉ាំរ៉ៃ ជំងឺក្រិនថ្លើម ជំងឺសរសៃឈាមក្រហមបេះដូង ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២ ជំងឺវិបត្តិចង្វាក់បេះដូង ជំងឺក្រិនសរីរាង្គ ជំងឺវិកលចរិក ជំងឺលុយពុស ជំងឺលើសឈាម ជំងឺតាឡាសេមី។

**កថាខណ្ឌទី២ ៖ បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព**

**ក.ការកំណត់អត្រាភាគទានផ្នែកថែទាំសុខភាព**

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាបន្ទុករបស់សាមីជន។ អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង ០,៥០% (សូន្យក្បៀសហាសិបភាគរយ) នៃប្រាក់សោធនរបស់សាមីជន ដោយមិនរាប់បញ្ចូលប្រាក់បន្ទាប់បន្សំ ឬប្រាក់ឧបត្ថម្ភផ្សេងៗ។[58] ទោះបីជារាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្ដីពី ការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយកំណត់នូវអត្រាបង់ភាគទានសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ប៉ុន្តែរាជរដ្ឋាភិបាលក៏នូវតែជាអ្នករ៉ាប់រងបង់ជំនួសអត្រាភាគទាន ០,៥០%(សូន្យក្បៀសហាសិបភាគរយ) ដែលជាបន្ទុករបស់សាមីជន រហូតដល់មានការសម្រេចជាថ្មីរបស់រាជរដ្ឋាភិបាល។[59]

**ខ.ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព**

**១.ការចុះបញ្ជី និងការចេញអត្តសញ្ញាណសមាជិក**

ប.ស.ស ត្រូវចុះបញ្ជីអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស ។

[58] មាត្រា៥ អនុក្រឹត្យស្ដីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[59] មាត្រា១៦ អនុក្រឹត្យស្ដីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

ប.ស.ស ត្រូវចេញលេខអត្តសញ្ញាណសមាជិក ប.ស.ស សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយអនុលោមតាមលេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។ ដើម្បីអនុវត្តការចេញលេខអត្តសញ្ញាណសមាជិកនេះ ក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានភារកិច្ចដូចតទៅក្រសួង ស្ថាប័ន ឬអង្គភាពដែលគ្រប់គ្រងផ្ទាល់លើអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវផ្តល់ទិន្នន័យអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងទំហំថវិកាភាគទាន មក ប.ស.ស ជារៀងរាល់ខែ។[60]

**២. ការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព**

យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព បានកំណត់យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ សេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាពដែល ប.ស.សត្រូវផ្តល់នូវមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ឬមូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

ប.ស.ស ត្រូវទូទាត់តាវកាលិកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ស្របតាមលក្ខខណ្ឌ បែបបទ និងនីតិវិធី តាមច្បាប់ជាធរមាន។ ការផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹង យន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ លើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ក្រៅពីឱសថក្នុងបញ្ជីឱសថសារវន្ត ដែលត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។ យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាងគឺ វិធីសាស្ត្រទូទាត់ថ្លៃតាមករណី និងវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា។ វិធីសាស្ត្រទូទាត់ថ្លៃតាមករណី[61] ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជំងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា[62] ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេសដូចមានចែងក្នុងឧបសម្ព័ន្ធទី២នៃប្រកាសអន្តរ

[60] មាត្រា៧ អនុក្រឹត្យស្តីពី ការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

[61] មើលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

[62] មើលឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

ក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ វិធីសាស្ត្រដែលកំណត់នៅក្នុងយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។ ប.ស.ស ត្រូវទូទាត់សងទៅមូលដ្ឋានសុខាភិបាល ឬសាមីជន តាមវិធីសាស្ត្រទូទាត់ថ្លៃដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព និងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ក្នុងករណីសង្គ្រោះបន្ទាន់។ ក្នុងករណីនេះ ជនរងគ្រោះ ឬអ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ប្រសិនបើ ការសង្គ្រោះបន្ទាន់ធ្វើនៅក្នុងមូលដ្ឋានសុខាភិបាល ដែលមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជន ឬអ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស ។ ការទូទាត់ថ្លៃសេវាបញ្ជូនជនរងគ្រោះ ឬអ្នកជំងឺ សម្រាប់ផ្នែកថែទាំសុខភាព ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ប្រភេទមធ្យោបាយបញ្ជូនដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់។ ការទូទាត់ថ្លៃសេវាបញ្ជូន ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ ការបញ្ជូនសព ឬបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។ ការទូទាត់ថ្លៃសេវាបញ្ជូន និងការទូទាត់ថ្លៃសេវាស្ពារនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២នៃប្រកាសអន្តរក្រសួងស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ របៀបទូទាត់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រចំពោះមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវារវាង ប.ស.ស ជាមួយមូលដ្ឋានសុខាភិបាលដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។[63]

សិទ្ធិនៃការទាមទារថ្លៃតារកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវមានអាជ្ញាយុកាលត្រឹមរយៈពេល ១២ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាព។

[63] ប្រកាសអន្តរក្រសួងស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបរួមមក ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវខាងលើ យើងអាចនិយាយបានថា ប្រព័ន្ធរ៉ាប់រងសង្គមសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ពិតជាមានសារៈសំខាន់ក្នុងការផ្តល់តាវកាលិកថែទាំសុខភាព តាវកាលិកហានិភ័យ របបសោធន ព្រមទាំងរបបឧបត្ថម្ភផ្សេងៗ ដើម្បីគាំពារហានិភ័យដែលអាចផ្តល់ផលប៉ះពាល់អវិជ្ជមានដល់សន្តិសុខ ប្រាក់ចំណូលរបស់មន្ត្រីរាជការ និងអតីតមន្ត្រីរាជការ ដោយសារ ការឈឺថ្កាត់ មាតុភាព គ្រោះថ្នាក់ការងារ ជរាភាព និងមរណភាព ជាដើម។ ចំពោះមន្ត្រីរាជការទទួលបានការគាំពារពីរដ្ឋ ដោយពួកគេទទួលបានការថែទាំ និងព្យាបាលជំងឺដោយឥតគិតថ្លៃពីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយរដ្ឋ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាល ក៏ដាក់ចេញគោលនយោបាយសម្រាប់មន្ត្រីរាជការជាស្ត្រីដែលសម្រាលកូនគឺត្រូវទទួលបានប្រាក់ឧបត្ថម្ភមួយចំនួន និងមានពេលសម្រាកលំហែមាតុភាពយ៉ាងសមរម្យដែរ។ ចំពោះអតីតមន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលក៏បានដាក់ចេញគោលនយោបាយជាតិចំពោះអតីតមន្ត្រីរាជការ ដោយដឹងគុណចំពោះគុណបំណាច់របស់អតីតមន្ត្រីរាជការដែលបានរួមចំណែកក្នុងបុព្វហេតុនៃការអភិវឌ្ឍប្រទេសជាតិ ហើយបានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗសម្រាប់ជំនាន់ក្រោយៗទៀត។ បន្ថែមពីនេះ រាជរដ្ឋាភិបាល បានផ្តល់របបសន្តិសុខសង្គមដោយមានការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលត្រូវបានដំឡើងជារៀងរាល់ឆ្នាំស្របតាមការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល ដោយអនុវត្តការផ្តល់របបសន្តិសុខសង្គមឲ្យទាន់ពេលវេលាស្របតាមគោលនយោបាយនៃការផ្តល់សេវាសាធារណៈ និងយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ចំពោះអតីតយុទ្ធជន រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការងារអតីតយុទ្ធជន និងបានអនុវត្តគោលនយោបាយជាតិចំពោះអតីតយុទ្ធជន ដោយការគោរពគុណូបការៈដ៏ថ្លៃថ្លារបស់អតីតយុទ្ធជនចំពោះជាតិមាតុភូមិនិងប្រជាជន និងការយកចិត្តទុកដាក់ដោះស្រាយជីវភាពទាំងសម្ភារៈ និងថវិកាជាបន្តបន្ទាប់ព្រមទាំងផ្តល់កិត្តិយស ការគោរព និងការថែរក្សាសេចក្តីថ្លៃថ្នូរជូនអតីតយុទ្ធជន។ លើសពីនេះទៀត រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់កែសម្រួលបន្ថែមរបបឧបត្ថម្ភ ជូនអតីតយុទ្ធជនជាបន្តបន្ទាប់ស្របតាមសភាពការណ៍ជាក់ស្តែងនៃស្ថានភាពសេដ្ឋកិច្ចជាតិ ហើយផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនតាមប្រព័ន្ធធនាគារ សំដៅបង្កើនប្រសិទ្ធភាពការបើកផ្តល់ប្រាក់របបគោលនយោបាយជូនអតីតយុទ្ធជន និងគ្រួសារ។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានអនុវត្តគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ព្រមទាំងបានបង្កើតគម្រោងជាច្រើនដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។ ការណ៍នេះគឺជាការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដែលផ្តល់ការលើកទឹកចិត្តតាមរយៈការផ្តល់កិត្តិយស សេចក្តីថ្លៃថ្នូរ ជូនពួកគាត់ ដែលមានគុណបំណាច់បម្រើជាតិមាតុភូមិ។

# អនុសាសន៍

# អនុសាសន៍

ថ្វីត្បិតតែ របបសន្តិសុខសង្គមក្នុងវិស័យសាធារណៈ ដំណើរការរលូនប្រកបដោយប្រសិទ្ធភាពក៏ដោយ ក៏មានបញ្ហាប្រឈមមួយចំនួនដូចជា លក្ខណៈរាយប៉ាយនៃស្ថាប័នប្រតិបត្តិករ អសង្គតិភាពនៃតារាកាលិក ប្រព័ន្ធថែទាំសុខភាព និងគុណភាពនៃសេវាសុខាភិបាលនៅមានកំណត់នៅឡើយ។ ស្ថាប័នប្រតិបត្តិកររបបសន្តិសុខសង្គមបច្ចុប្បន្នគឺ ប.ជ.ស. ប.ជ.អ. និងប.ស.ស ដែលមានមុខងារ និងភារកិច្ចស្ទើរតែដូចគ្នាទាំងស្រុង មានភាពខុសគ្នាតែចំនួនសមាជិក និងគោលដៅប៉ុណ្ណោះ ហើយការដាក់ឲ្យដំណើរការគ្រឹះស្ថានសាធារណៈផ្សេងៗគ្នា ក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមទៅតាមសមាជិកគោលដៅរៀងខ្លួនបែបនេះ នាំឲ្យមានការចំណាយខ្ពស់លើដំណើរប្រតិបត្តិការស្ថាប័ន ទាំងការឧបត្ថម្ភបុគ្គលិក និងការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ។ ដូច្នេះ រដ្ឋាភិបាលគួររៀបចំស្ថាប័នប្រតិបត្តិកររបបសន្តិសុខសង្គមឡើងវិញ ដើម្បីកាត់បន្ថយការចំណាយថវិការបស់រដ្ឋ។ ដោយឡែក ការកំណត់តារាកាលិកសោធនសម្រាប់មន្ត្រីរាជការ នគរបាល និងយោធិនមិនមានសង្គតិភាពនឹងគ្នា ដោយសារការកំណត់តារាកាលិកសោធនទាំងនោះត្រូវបានកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិដោយឡែកពីគ្នា។ សោធនសម្រាប់មន្ត្រីរាជការ ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ សោធនសម្រាប់មន្ត្រីនគរបាល ត្រូវបានកំណត់ដោយច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម។ រីឯ ប្រាក់សោធនយោធិនត្រូវបានកំណត់ដោយច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ។ អសង្គតិភាពនៃប្រាក់សោធននាំឲ្យមានអសមធម៌រវាងក្រុមផ្សេងៗនៃមន្ត្រីសាធារណៈ ជាពិសេស មន្ត្រីដែលមានឋានន្តរស័ក្តិប្រហាក់ប្រហែលគ្នា ប៉ុន្តែទទួលបានប្រាក់សោធនខុសគ្នា។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវរៀបចំ សេចក្តីព្រាងច្បាប់ស្តីពីរបបសោធនមួយ ដែលផ្តល់តារាកាលិករបបសោធន ប្រកបដោយសមធម៌ រវាងក្រុមនៃមន្ត្រីសាធារណៈ ជាពិសេសមន្ត្រីដែលមានឋានន្តរស័ក្តិប្រហាក់ប្រហែលគ្នា។ បើក្រឡេកមើលគុណភាពនៃសេវាសុខាភិបាលវិញ នៅមិនទាន់ឆ្លើយតបនឹងសេចក្តីរំពឹងទុករបស់អ្នកជំងឺឬអតិថិជននៅឡើយទេ ជាពិសេសសេវាសម្រាកព្យាបាល និងថែទាំសុខភាព ដូច្នេះក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវពង្រឹងគុណភាពនៃការបណ្តុះបណ្តាលបង្កើនសមត្ថភាពគ្លីនិក ការពង្រឹងយន្តការនិយ័តកម្ម ការត្រួតពិនិត្យនិងតាមដានគុណភាពជាប្រចាំ និងការពង្រាយបុគ្គលិកជំនាញស្របតាមនិយាមបច្ចេកទេស គឺជាសក្តានុពលភាពនៃការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព។

# ឯកសារយោង

# ឯកសារយោង

## ព្រះរាជក្រម

- ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ ០៧ នស/៩៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- ព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

## ក្រឹត្យច្បាប់

- ក្រឹត្យច្បាប់លេខ ១០ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះនគរបាលប្រជាជនកម្ពុជា

## ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ព្រះរាជក្រឹត្យ លេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន
- ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១២/៨៤៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី
- ព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**អនុក្រឹត្យ**

- អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យ លេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីការអនុវត្តន៍របបសោធន និវត្តន៍ និងបាត់បង់សមត្ថភាពការងារចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ
- អនុក្រឹត្យ លេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិន ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- អនុក្រឹត្យ លេខ ២១៨ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពី ការកែសម្រួលមាត្រា៧ ជំពូកទី៣នៃអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភ ចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យ លេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពី របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- អនុក្រឹត្យ លេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន
- អនុក្រឹត្យ លេខ ១០១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ ស្តីពី ការកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- អនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍
- អនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៣០ ជំពូកទី៣នៃអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីពនិងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍

- អនុក្រឹត្យ លេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- អនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែនិងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព
- អនុក្រឹត្យ លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

**ប្រកាស**

- ប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
- ប្រកាសអន្តរក្រសួងលេខ ៣២៧ ក.ប/ប្រ.ក. ប.ស.ស ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
- ប្រកាសលេខ ០៤៩ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់បញ្ចូលសេវាបង្ការសុខភាពនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ប្រកាសលេខ ២៣៨ ក.ប/ប្រ.ក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

**សៀវភៅបោះពុម្ព**

- ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧
- ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កម្រងការផ្តល់សេវាផ្សេងៗ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សៀវភៅព័ត៌មានសម្រាប់មន្ត្រីរាជការស៊ីវិល បោះពុម្ពលើកទី២ ខែកញ្ញា ឆ្នាំ២០១០

**គេហទំព័រ**

- បេឡាជាតិរបបសន្តិសុខសង្គម http://www.nssf.gov.kh
- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល http://www.nssfc.gov.kh
- បេឡាជាតិអតីតយុទ្ធជន http://www.nfv.gov.kh
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា http://www.mosvy.gov.kh
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ http://www.mlvt.gov.kh

# ឧបសម្ព័ន្ធ

# តារាងបញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួង លេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

ឧបសម្ព័ន្ធទី២ ប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

ឧបសម្ព័ន្ធទី៣ ប្រកាសអន្តរក្រសួងស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

ឧបសម្ព័ន្ធទី៤ ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារនិងថែទាំសុខភាព តាមបណ្តា រាជធានី ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ.........៣២៧.........ក.ប/ប្រ.ក.ប.ស.ស

ក្រសួងសុខាភិបាល

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ    រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៩០២/០១៨ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០២ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព
- យោងតាមការចាំបាច់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល

## សម្រេច

**ប្រការ មួយ.-**

ត្រូវបានកែសម្រួលឧបសម្ព័ន្ធទី១ ក្នុងប្រការ៣ ប្រការ៤ និងប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ទៅជាឧបសម្ព័ន្ធទី១ថ្មី វិញ ក្នុងប្រការ៣ ប្រការ៤ និងប្រការ៩ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព ។

**ប្រការ ពីរ.-**

ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ នេះតទៅ។

**ប្រការ ៥._**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទ ក្រសួងសុខាភិបាល និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៧

| | |
|---|---|
| **រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសុខាភិបាល** | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| **ម៉ម ប៊ុនហេង** | **អ៊ិត សំហេង** |

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ.១៤៧.....ក.ប/ប្រ.ក ស្តីពីការកែសម្រួល*
*ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦*
*ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទករណី

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមករណី សំរាប់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។ ទិដ្ឋភាពរួមនៃវិធីសាស្ត្រទូទាត់តាមករណីត្រូវបានចែងនៅក្នុងតារាងភ្ជាប់មកជាមួយ។

**១-ចំនួន និងកំរិតប្រភេទករណី:** (ជួរឈរលេខ១ក្នុងតារាង) វិធីសាស្ត្រទូទាត់តាមករណីបានកំណត់យកប្រភេទករណី សរុបចំនួន ៥២ ដែលត្រូវបានបែងចែកចេញជា៥ កំរិតនៃសេវាព្យាបាលថែទាំវេជ្ជសាស្ត្រគឺ: កំរិត MPA សំរាប់មណ្ឌលសុខភាព កំរិត CPA1 សំរាប់មន្ទីរពេទ្យបង្អែកកំរិត១ កំរិត CPA2 សំរាប់មន្ទីរពេទ្យបង្អែកកំរិត២ កំរិត CPA3 សំរាប់មន្ទីរពេទ្យបង្អែកកំរិត៣ និង កំរិត NH សំរាប់មន្ទីរពេទ្យជាតិ ដូចមានចែងនៅក្នុងគោល-ការណ៍ណែនាំស្តីពីសំណុំសកម្មភាពអប្បបរមា និងសំណុំសកម្មភាពបង្គ្រប់របស់ក្រសួងសុខាភិបាល។

**២-លេខកូដ:** (ជួរឈរលេខ២ក្នុងតារាង) រាល់ប្រភេទករណីនីមួយៗមានលេខកូដមួយ ដែលផ្តុំឡើងដោយតួអក្សរឡាតាំង៣តួនៅខាងមុខ និងលេខមួយតួនៅខាងចុង។ អក្សរឡាតាំងទាំង៣តួ ភាគច្រើនបំផុត យកចេញពីតួអក្សរឡាតាំង៣តួដំបូងនៃឈ្មោះករណីដែលអាចចាត់ទុកថាជាឈ្មោះសង្ខេប រីឯលេខមួយតួខាងចុងតំណាងកំរិតសេវា ពោលគឺ: លេខ0 តំណាងកំរិតMPA, លេខ1 តំណាងកំរិតCPA1, លេខ2 តំណាងកំរិត CPA2, និង លេខ3 តំណាងកំរិត CPA3 និងលេខ4 តំណាងកំរិត NH។ លេខកូដនឹងត្រូវប្រើជាពិសេសសំរាប់បច្ចេកវិទ្យាប្រព័ន្ធទំនាក់ទំនងព័ត៌មានសំរាប់សំរួលដល់ការត្រួតពិនិត្យតាមដានវាយតំលៃធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗ។

**៣-ឈ្មោះករណី:** (ជួរឈរលេខ៣ក្នុងតារាង) ឈ្មោះករណីនឹងត្រូវប្រើរួមគ្នាជាមួយលេខកូដសំរាប់គោលបំណងត្រួតពិនិត្យតាមដាន វាយតំលៃធ្វើរបាយការណ៍ និងដំណើរការទូទាត់ផ្សេងៗដោយឡែក។

**៤-ការបរិយាយ/និយមន័យករណី:** (ជួរឈរលេខ៤ក្នុងតារាង) ការបរិយាយ/និយមន័យ ករណីដែលមានលក្ខណៈស្របទៅនឹងការអនុវត្តន៍ជាក់ស្តែងអនុញ្ញាតឲ្យមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស កំណត់ និងបែងចែកករណីអ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រទៅតាមប្រភេទករណីនីមួយៗ។

**៥-បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ:** (ជួរឈរលេខ៥ក្នុងតារាង) បញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ ដែលពាក់ព័ន្ធនានាប្រើសំរាប់ជាជំនួយបន្ថែមដល់មូលដ្ឋានសុខាភិបាលក្នុងការកំណត់ និងបែងចែកប្រភេទករណីក៏ដូចជាការធ្វើលំហាត់ ដើម្បីឈានឆ្ពោះទៅការអនុវត្តន៍យន្តការទូទាត់តាមប្រភេទរោគវិនិច្ឆ័យ (Diagnostic related group) ទៅថ្ងៃមុខ។

ដោយសារបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យនេះ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយ មូលដ្ឋានសុខាភិបាលអាចប្រើតែការបរិយាយ/និយមន័យករណីសំរាប់កំណត់ប្រភេទករណីណាដែលស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ មិនមាននៅក្នុងបញ្ជីរាយនាមស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យ។ សំរាប់ករណីសម្រាកពេទ្យ ការកំណត់ករណីនីមួយៗ នឹងត្រូវធ្វើឡើងនៅពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ (ចេញដោយមានការអនុញ្ញាត ចេញដោយបញ្ជូន ឬ ចេញដោយស្លាប់)។សំរាប់ករណីដែលក្នុងរយៈពេលសម្រាកពេទ្យបានទទួលសេវាព្យាបាលថែទាំច្រើនផ្នែក នឹងត្រូវកំណត់ជាប្រភេទករណីមួយដែលមានតំលៃទូទាត់ខ្ពស់ជាងគេ។

ឧ. ករណីអ្នកជំងឺម្នាក់សម្រាកនៅផ្នែកសង្គ្រោះបន្ទាន់ រួចបន្តមកផ្នែកសល្យសាស្ត្រ និងចុងក្រោយត្រូវការវះកាត់ត្រូវចាត់ជាករណីវះកាត់ធំ និងទូទាត់តែសំរាប់ករណីវះកាត់ធំនេះទេ។

**៦-តំលៃទូទាត់:** (ជួរឈរលេខ៦ក្នុងតារាង) តំលៃគិតជាប្រាក់រៀលដែល ប.ស.ស ត្រូវទូទាត់ឲ្យមូលដ្ឋានសុខាភិបាលសំរាប់ករណីនីមួយៗដែលបានកំណត់។ [1] តំលៃទូទាត់នេះគឺសម្រាប់គ្រប់សេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រទាំងអស់ដែលមូលដ្ឋានសុខាភិបាលចាំបាច់ ត្រូវផ្តល់ជូនសំរាប់ព្យាបាលថែទាំករណីជំងឺនោះតាមគោលការណ៍វិជ្ជាជីវៈ និងដែលមានចែងក្នុងតារាកាលិកដែលកំណត់ដោយប្រកាសស្តីពីតារាកាលិកថែទាំសុខភាព និងកិច្ចព្រមព្រៀងរវាង ប.ស.ស និង មូលដ្ឋានសុខាភិបាល ហើយរាល់ការបញ្ជាក់ ឬការចេញ

---

*[1] សូមបញ្ជាក់ថា តំលៃត្រូវទូទាត់នេះត្រូវបានគណនាផ្អែកលើតំលៃចំណាយដោយមិនគិតប្រាក់ឧបត្ថម្ភធនពីរាជរដ្ឋាភិបាលរបស់មណ្ឌលសុខភាពនិងមន្ទីរពេទ្យរដ្ឋមួយចំនួនដែលបានមកពីការសិក្សាតំលៃមណ្ឌលសុខភាព និងមន្ទីរពេទ្យដែលបានធ្វើឡើងដោយក្រសួងសុខាភិបាលកន្លងមក ព្រមទាំងការលៃតំរូវទៅតាមកំរិត ដោយផ្ទៀងផ្ទាត់ជាមួយនឹងតំលៃហិរញ្ញប្បទាន និងតំលៃទូទាត់របស់មូលនិធិសមធម៌ ។*

លិខិតនានារបស់មូលដ្ឋានសុខាភិបាលគ្រប់កំរិតក៏ត្រូវបានគិតបញ្ចូលទៅក្នុងការទូទាត់ថ្លៃតាមប្រភេទករណីផងដែរ។ប៉ុន្តែតំលៃទូទាត់នេះមិនរាប់បញ្ចូលថ្លៃសេវាបញ្ជូន និងថ្លៃសេវាអមវេជ្ជសាស្ត្រនានាដែលមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះទេ។ ចំពោះមូលដ្ឋានសុខាភិបាលឯកជន ប.ស.ស អាចទូទាត់រហូតដល់១៥០% នៃតំលៃមូលដ្ឋានសុខាភិបាលសាធារណៈ ដោយផ្អែកតាមកំរិតសេវារបស់មូល- ដ្ឋានសុខាភិបាលឯកជននោះ ក្នុងករណីដែល ប.ស.ស មានការចាំបាច់ត្រូវចុះកិច្ចព្រម-ព្រៀងជាមួយ នៅទីតាំងដែលមិនមានសេវាសុខាភិបាលសាធារណៈសមស្រប។

ក្នុងការអនុវត្តជាក់ស្តែង ដើម្បីជំរុញការលើកកំពស់គុណភាពសេវា ប.ស.ស មានសិទ្ធិ ទូទាត់តិច ឬច្រើនជាងតំលៃត្រូវទូទាត់ដែលបានកំណត់ក្នុងតារាងនេះ (ចន្លោះពី ៨០% ទៅ ១២០%) ទៅតាមកំរិតគុណភាពសេវាដែលនឹងត្រូវវាស់វែង ឬ វាយតំលៃដោយយន្តការសមស្របមួយ។

**៧-ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលៈ** ដើម្បីអនុវត្តវិធីសាស្ត្រទូទាត់តាមករណីនេះ ប.ស.ស ត្រូវធ្វើការវាយតំលៃ និងចាត់ថ្នាក់មូលដ្ឋានសុខាភិបាល ដែលត្រូវចុះកិច្ចព្រម-ព្រៀងជាកំរិត MPA កំរិត CPA1 កំរិត CPA2 កំរិត CPA3 កំរិតចំរុះ ឬកំរិត NH ទៅតាមវិសាលភាព និងគុណភាពសេវារបស់មូលដ្ឋានសុខាភិបាលនោះ។ សូមបញ្ជាក់ថាមូលដ្ឋាន-សុខាភិបាល មួយអាចទទួលកិច្ចព្រមព្រៀងសំរាប់សេវាច្រើនកំរិត (កំរិតចំរុះ)។ ឧ. សំរាប់មណ្ឌលសុខភាព មានគ្រែមួយ សេវាសម្រាកពេទ្យអាចចាត់ថ្នាក់ជាកំរិត CPA1 និងសេវាដទៃទៀតចាត់ថ្នាក់ជាកំរិត MPA។ មន្ទីរពេទ្យកំរិត CPA1 ខ្លះអាចមានសេវាវះកាត់ធំ ក្នុងករណីនេះ សេវាវះកាត់ធំនេះអាចចាត់ថ្នាក់ជាកំរិត CPA2 បើទោះបីជាសេវាដទៃទៀតត្រូវបានចាត់ថ្នាក់ជាកំរិត CPA1 ក៏ដោយ។

សម្រាប់មណ្ឌលសុខភាពដែលមានទីតាំងនៅក្នុង ឬចំណុះការគ្រប់គ្រងរបស់មន្ទីរពេទ្យត្រូវចាត់ថ្នាក់ជាកំរិត MPA បើកំរិតសេវារបស់មណ្ឌលសុខភាពនោះគ្មានអ្វីខុសគ្នាពីមណ្ឌលសុខភាពដទៃទេនោះ។

| ល.រ | កូដ | ឈ្មោះករណី | ការបរិយាយ/និយមន័យករណី | ស្ថានភាពវេជ្ជសាស្ត្រ/រោគវិនិច្ឆ័យដែលពាក់ព័ន្ធ | តំលៃទូទាត់គិតជារៀល |
|---|---|---|---|---|---|
| 1 | CON0 | ករណីពិគ្រោះជំងឺក្រៅកំរិត MPA | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់នៅមណ្ឌលសុខភាព។ សេវាពិគ្រោះជំងឺក្រៅរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំ សុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ (ធ្វើតេស្តឈាមរកមេរោគគ្រុនចាញ់ និងធ្វើភ្នាសកំហាករកមេរោគរបេង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យ ចេញឲ្យប្រើ)<br>- ការពិនិត្យនិងព្យាបាលបន្តជំងឺរបេងដូតឬហង់សិន ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ។ | - ជំងឺផ្តាសសាយទូទៅ (Common cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលមិនមានផលវិបាក(Uncomplicated acute respiratory infection)<br>- ជំងឺរាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without server dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់គ្មានផលវិបាក(Tuberculosis/leprosy or Suspected and uncomplicated Tuberculosis/ leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក (Uncomplicated Typhoid Fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល ( Otitis media )<br>- ជំងឺពុកធ្មេញ ( Dental Caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites) | ៦.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ចង្កោមរោគសញ្ញាជំងឺកាមរោគ (Sexual Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ(Headache, Fatigue, Fever... of unknown origin)<br>- ជំងឺលើសឈាមគ្មានផលវិបាក (Uncomplicated Hypertension) ។ | |
| 2 | REFO | ករណីសង្គ្រោះបន្ទាន់ បញ្ជូនឬមិនបញ្ជូនកំរិត MPA | ជាសេវាសង្គ្រោះបឋម និងការបញ្ជូនឬមិនបញ្ជូនចេញពីមណ្ឌលសុខភាព ដោយគិតរួមបញ្ចូលទាំង៖<br>- លិខិតបញ្ជូន<br>- ការបញ្ចូលសេរ៉ូម<br>- សេវាសង្គ្រោះបឋមក្នុងពេលបញ្ជូន<br>- ការពិនិត្យតាមដានចាំបាច់ដទៃទៀតតែមិនគិតរួមបញ្ចូលថ្លៃដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះឬតាមមធ្យោបាយផ្សេងៗទេ។ | - ជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរដូចជា:ជំងឺរលាកសួតឬជំងឺហឺត ( Pneumonia/Asthma)<br>- ជំងឺរាគរ៉ាំរ៉ៃ ឬ ជំងឺរាគមានការបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (chronic diarrhea or diarrhea with severe dehydration)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ(Complicated malaria)<br>- សង្ស័យជំងឺរបេងសួត ឬ របេងក្រៅសួតធ្ងន់ធ្ងរ (suspected severe pulmonary/ extra pulmonary Tuberculosis )<br>- ជំងឺគ្រុនពោះវៀនមានផលវិបាក (Complicated Typhoid Fever)<br>- សង្ស័យជំងឺគ្រុនឈាម (Suspected | ២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | Dengue Fever)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with complication/stroke)<br>- ការសម្រាលកូនពិបាក (Complicated delivery)<br>- លង់ទឹក (Drown)<br>- ស្លុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- បាក់ឆ្អឹង (Bone fracture)<br>- រលាក ឬ ហូរឈាមធ្ងន់ធ្ងរ (Severe burn or Hemorrhage)<br>- ពស់ចឹក (Snake bite)<br>- ឆ្កែខាំ (Dog bite)<br>- សត្វទិច/ខាំ ដែលអាចបង្កឲ្យមានគ្រោះថ្នាក់<br>- ស្ថានភាពវេជ្ជសាស្ត្រស្មុគ្រស្មាញផ្សេងទៀត ដែលមណ្ឌលសុខភាព មិនមានលទ្ធភាពពិនិត្យព្យាបាល ។ | |
| 3 | MIN0 | ករណីវះកាត់តូច កំរិត MPA | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖ | - បូសធម្មតា ( Cutaneous abscess )<br>- របួសតូច ( Minor wound ) | ១២.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំស្ពឹក ( Local Anesthesia )<br>- ការវះកាត់<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាចាំបាច់ដទៃទៀត សម្រាប់ករណីសល្យសាស្ត្រតូចនៅមណ្ឌលសុខភាព។ | - រលាកស្រាល ( Mild burn )<br>- ព្យាបាលនិងលាងសំអាតមាត់ស្បូនឬទ្វារមាស (Vagina or Cervix) ។ | |
| 4 | PREO | ករណីសេវាបង្ការ និងពន្យាកំណើត រយៈពេលខ្លី កំរិត MPA | - ជាការពន្យារកំណើតករណីថ្មី និងករណីបន្តបន្ទាប់ (រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ដូចជា ស្រោមអនាម័យ ថ្នាំគ្រាប់ឬថ្នាំចាក់)<br>- ការពិនិត្យផ្ទៃពោះមុនសំរាល (រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត)<br>- ការពិគ្រោះក្រោយសំរាល<br>- ការថែទាំព្យាបាលក្រោយរលូត | - ការថែទាំមុនសំរាល ( Antenatal care)<br>- ការពន្យារកំណើត ( Birth spacing)<br>- ការថែទាំក្រោយសំរាល ( Postnatal care )<br>- ការថែទាំព្យាបាលក្រោយរលូត (Post-abortion care)<br>- ការចាក់ថ្នាំបង្ការ ( Vaccination )។ | ១០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការចាក់ថ្នាំបង្ការ នៅមណ្ឌលសុខ-ភាព។ | | |
| 5 | BSLO | សេវាពន្យារកំណើតរយៈពេលវែង កំរិត MPA | ជាការពន្យារកំណើតសម្រាប់ករណីថ្មី និងករណីបន្តបន្ទាប់ ដោយរួមបញ្ចូលៈ<br>- ការដាក់កងក្នុងស្បូន ឬ ដាក់កងក្នុងដៃ<br>- ការប្រឹក្សាពីវិធីសាស្ត្រពន្យារកំណើត នៅមណ្ឌលសុខភាព។ | - ការពន្យារកំណើតរយៈពេលវែង ( Prolonged birth spacing)។ | ៣០.០០០ |
| 6 | DELO | ករណីសំរាលកូន កំរិត MPA | ជាការសំរាល និងសេវាចាំបាច់ដទៃទៀត រួមមានៈ<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រង ការសំរាលសកម្មដំណាក់កាលទី៣(AMTSL)<br>- ការដេរស្នាមកាត់ឬដាច់ទ្វារមាស<br>- ការថែទាំ និងសង្គ្រោះទារកបន្ទាប់ពីសំរាលភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសំរាប់ករណីសំរាលកូនធម្មតា នៅមណ្ឌលសុខភាព។ | - ការសំរាលកូនធម្មតា (Normal delivery)។ | ៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 7 | CON1 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA1 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន (Referral consultations)នៅមន្ទីរពេទ្យបង្អែកកម្រិត១។សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ ( សេវាមន្ទីរពិសោធន៍មូលដ្ឋាន អេកូសាស្ត្រ ការថតកាំរស្មីអ៊ិច ការវាស់អគ្គិសនីបេះដូង)<br>- កាព្យាបាលនិងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវាដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងៗទេ)។ | - ជំងឺផ្តាសសាយទូទៅ (Common cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវ ដែលមិនមានផលវិបាក(Uncomplicated acute respiratory infections )<br>- រាគមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without severe dehydration)<br>- ជំងឺគ្រុនចាញ់គ្មានផលវិបាក (Uncomplicated malaria)<br>- ជំងឺរបេង/ឃ្លង់ ឬសង្ស័យរបេង/ឃ្លង់ គ្មានផលវិបាក(Tuberculosis/Leprosy or Suspect uncomplicated Tuberculosis / leprosy)<br>- ជំងឺគ្រុនពោះវៀនគ្មានផលវិបាក ( Uncomplicated Typhoid Fever )<br>- ជំងឺគ្រុនឈាមគ្មានផលវិបាក ( Uncomplicated Dengue Fever )<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ (Acute Conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis Media)<br>- ជំងឺពុកធ្មេញ (Dental Caries) | ១២.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | - ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ចង្កោមរោគសញ្ញាជំងឺកាមរោគ(Sexually Transmitted Infection Syndrome)<br>- ជំងឺសើស្បែក (Skin disease)<br>- ឈឺក្បាល អស់កំលាំង ក្តៅខ្លួនមិនដឹងមូលហេតុ ( Headache, Fatigue, Fever... of unknown origin)<br>- ស្ថានភាពដទៃទៀតដែលមិនអាចគ្រប់គ្រងបាននៅមណ្ឌលសុខភាព ប៉ុន្តែមិនត្រូវការសម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់រួមមាន :<br>• រលាកស្រោមខួរក្បាល គិតរួមទាំងរលាកស្រោមខួរក្បាល ដោយមេរោគរបេង (Meningitis including Tuberculosis meningitis)<br>• រលាកខួរក្បាល ( Encephalitis )<br>• របេងស្វតទំរង់ធ្ងន់ធ្ងរ (Miliary Tuberculosis)<br>• ជំងឺតេតាណូស (Tetanus )<br>• ស្ថានភាពវេជ្ជសាស្ត្រដូចមានថៃងក្នុង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ប្រភេទករណី EMG1 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 8 | MIN1 | ករណីវះកាត់តូច កំរិត CPA1 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន ៖<br>- ការចាក់ថ្នាំស្ពឹក ( Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និង ការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - បូសធម្មតា (Cutaneous abscess)<br>- អាប់សែរាក់ៗ (Superficial abscess)<br>- របួសតូច (Minor wound)<br>- រលាកកំរិតស្រាល (Mild burn)<br>- រលាកសាច់ដុំកំរិតមធ្យម (Moderate myositis)<br>- គីសស្បែក (Sebaceous cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ ( Tooth extraction )។ | ២០.០០០ |
| 9 | EMG1 | ករណីសង្គ្រោះបន្ទាន់កំរិត CPA1 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬ អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត១ដោយសំរាក | ស្ថានភាពវេជ្ជសាស្ត្រណាក៏ដោយ ដែលត្រូវការសង្គ្រោះជីវិតបន្ទាន់រួមមាន :<br>- លង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory distress )<br>- ស្តុក ( Shock) | ១២០.០០០ |



AR -

| | | | | | |
|---|---|---|---|---|---|
| | | | ពេទ្យ។ | - ប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or hemorrhage)<br>- ពស់ចឹក (Snake bite)<br>- ការពុល/ការលាងក្រពះ(Intoxication with gastric lavage)<br>- គ្រោះថ្នាក់ចរាចរណ៍(ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យឬសម្រាកពេទ្យ)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀត ដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 10 | MED1 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត១ ។ ករណីសម្រាកពេទ្យផ្នែកសល្យសាស្ត្រ ដែលមិនត្រូវការសង្គ្រោះបន្ទាន់ ឬ បញ្ជូនដូចជារលាកភ្លើង ឬរបួស ត្រូវចាត់ចូលក្នុងប្រភេទករណីនេះ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe bronchitis)<br>- ជំងឺហឺត ( Asthma )<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or chronic diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក | ១០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | (Severe/complicated malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន(Typhoid Fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric ulcer)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់(Arthropathy)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 11 | DEL1 | ករណីសំរាលកូនកំរិត CPA1 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣(AMTSL) | - ការសំរាលកូនធម្មតា( Normal delivery)<br>- ការសំរាលពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។ | ១០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការបូមយកកូន<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារកបន្ទាប់ពីសំរាលភ្លាម<br>- ការថែទាំ និងតាមដានក្រោយសំរាល សម្រាប់ការសំរាលធម្មតា ឬមានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | | |
| 12 | GYN1 | ករណីរោគស្ត្រី កំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - ជំងឺមហារីកមាត់ស្បូន (Cervical cancer)<br>- ជំងឺមហារីកដោះ (Breast cancer)<br>- រលាកមាត់ស្បូនធ្ងន់ធ្ងរ (Severe cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina wound or injury)<br>- រលាកដៃស្បូន (Salpingitis)<br>- រលាកស្បូន (Endometriosis)<br>- រលាកអូវែ (Pelvic Inflammatory)<br>- ជំងឺផ្សេងទៀតទាក់ទងនឹងប្រដាប់បន្តពូជ | ១០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ស្ត្រី។ (other disease related to urogenital system) | |
| 13 | ABO1 | ករណីរលូត/រំលូតកូនកំរិត CPA1 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯង នៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬ ការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ។ | ១០០.០០០ |
| 14 | PED1 | ករណីជំងឺទូទៅកុមារកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe bronchitis)<br>- ជំងឺហឺត (Asthma)<br>- ទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត(Pulmonary abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or chronic diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ឬផ្តល់ផលវិបាក ( Severe/complicated malaria )<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid fever) | ៩២.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺគ្រុនឈាម (Dengue fever)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 15 | TUB1 | ករណីជំងឺរបេងកំរិត CPA1 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត១។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-Pulmonary Tuberculosis)<br>- លើកលែងតែរលាកស្រោមខួរក្បាលដោយមេរោគរបេង (Tuberculous Meningitis) របេងសួតទំរង់ធ្ងន់ធ្ងរ (Miliary Tuberculosis) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ១៦០.០០០ |
| 16 | CON2 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA2 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់ រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសកំរិតមូលដ្ឋាន នៅមន្ទីរពេទ្យបង្អែកកម្រិត២។ សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ | - ជំងឺផ្តាសសាយទូទៅ (Common cold)<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលគ្មានផលវិបាក(Uncomplicated acute respiratory infections)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without severe dehydration) | ១៦.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាបញ្ជូនបន្ទាន់សម្រាប់អ្នកជំងឺក្រៅ ត្រូវបានបញ្ចូលទៅក្នុងប្រភេទករណីនេះ (ដោយមិនគិតថ្លៃសេវាដឹកជញ្ជូនតាមរថយន្តគិលានសង្គ្រោះ ឬតាមមធ្យោបាយផ្សេងទេ)។ | - ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក(Suspected and uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ ( Acute conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis media)<br>- ជំងឺពុកធ្មេញ ( Dental caries )<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ (Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយមិនដឹងមូលហេតុ (Headache, Fatigue, fever…of unknown origin)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus ) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺអេដស៍ (អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំង និងមេរោគអេដស៍ OI/ART) ( HIV/AIDS ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental illness )<br>- បញ្ហាសុខភាពមាត់ធ្មេញ (Oral health problem)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងៗទៀត ដែលមិនអាចព្យាបាលនៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកកំរិត១ ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ។<br>- ករណីបញ្ជូនបន្ទាន់គឺសំដៅលើរាល់ស្ថានភាពវេជ្ជសាស្ត្រ ដូចមានចែងក្នុងប្រភេទករណី EMG2 ដែលត្រូវការបញ្ជូនបន្ទាន់។ | |
| 17 | MIN2 | ករណីវះកាត់តូចកំរិត CPA2 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia)<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស | - បូសធម្មតា (Cutaneous abscess)<br>- អាប់សែរាក់ៗ(Superficial abscess )<br>- របួសតូច (Minor wound)<br>- រលាកស្រាល/មធ្យម (Mild/moderate burn )<br>- រលាកសាច់ដុំ (Myositis)<br>- ដុំពកជាទឹក(គីសស្បែក)(Sebaceous cyst)<br>- ដុំពកជាខ្លាញ់ (Lipoma) | ២៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការវះកាត់ស្បែកនៅចុងលិង្គ (phymosis or paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth extraction)។ | |
| 18 | EMG2 | ករណីសង្គ្រោះបន្ទាន់កំរិត CPA2 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត២ដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន:<br>- ករណីលង់ទឹក (Drown)<br>- វិបត្តិដង្ហើម (Respiratory distress )<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាក ឬហូរឈាមធ្ងន់ធ្ងរ (Severe burn or hemorrhage)<br>- ពស់ចឹក (Snake bite)<br>- ការពុល/ការលាងក្រពះ(Intoxication with gastric lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាក | ២៤០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ពេទ្យ )<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់/ស្ទះសរសៃឈាមខួរក្បាល (Hypertension with complication/stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe chest pain)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺហើមសួតស្រួចស្រាវ(Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់ ។ | |
| 19 | SUR2 | ករណីសល្យសាស្ត្រកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ(លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ2) នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការប៉ះទង្គិចក្បាល (Head trauma)<br>- ការប៉ះទង្គិចពោះ (Abdominal trauma)<br>- ការប៉ះទង្គិចទ្រូង (Chest trauma)<br>- របួសហូរឈាមក្នុងពោះ ( Intra-abdominal hemorrhage )<br>- ជំងឺបូសថ្លើម ( Liver abscess)<br>- គ្រួសក្នុងតំរងនោម (Kidney stone)<br>- គ្រួសក្នុងប្លោកនោម (Bladder stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder stone)។ | ១៥០,០០០ |
| 20 | MAJ2 | ករណីវះកាត់ធំ | ជាអន្តរាគមន៍សល្យសាស្ត្រធំ ធ្វើនៅក្នុង | - ជំងឺរលាកខ្នែងពោះវៀន (Appendicitis) | ៥០០,០០០ |

| | | | | | |
|---|---|---|---|---|---|
| | | កំរិត CPA2 | បន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត២។ | - ជំងឺក្លូន (Hernia)<br>- កូនក្រៅស្បូន (Ectopic Pregnancy)<br>- គីស/ដុំអូវែរ (Ovarian cyst/Tumor)<br>- កាត់អវៈយវៈ (Amputation)<br>- វះកាត់ភ្នែក ( ភ្នែកឡើងបាយ ភ្នែករបួស ) (Ophthalmic Surgery including Cataract, Eye Surgery )<br>- វះកាត់យកកូនចេញ(ករណីសំរាលតាមទ្វាមាសមិនបាន) ( Caesarian section)<br>- ភ្លាត់សន្លាក់ (Dislocation of joint)<br>- ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន/ចងបំពង់មេជីវិតបុរស) (Sterilization by tuboligation / vasectomy)។ | |
| 21 | MED2 | ករណីជំងឺទូទៅមនុស្សពេញវ័យកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត ( Pulmonary abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic | ១២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/complicated malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ ( Gastric ulcer)<br>- ជំងឺរលាកស្រោមបេះដូងនិងជំងឺបេះដូងផ្សេងៗ (Pericarditis and other forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus )<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត (Thyroid gland disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការ | |

| | | | | | |
|---|---|---|---|---|---|
| | | | | សម្រាកពេទ្យ។ | |
| 22 | DEL2 | ករណីសំរាលកូនកំរិត CPA2 | ជាការសំរាល និងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣(AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬដាច់ទ្វារមាស<br>- ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំ និងសង្គ្រោះទារកបន្ទាប់ពីសំរាលភ្លាម<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ការសំរាលកូនធម្មតា(Normal delivery)<br>- ការសំរាលពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ។ | ១២០.០០០ |
| 23 | GYN2 | ករណីរោគស្ត្រីកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ | - ជំងឺមហារីកមាត់ស្បូន (Cervical cancer)<br>- ជំងឺមហារីកដោះ (Breast cancer) | ១៥០.០០០ |



AR

| | | | | | |
|---|---|---|---|---|---|
| | | | ដោយផ្នែកសម្ភព/រោគស្ត្រី នៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ (Severe cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina wound or injury)<br>- រលាកដៃស្បូន (Salpingitis)<br>- រលាកស្បូន (Endometriosis)<br>- រលាកអូវែ (Pelvic Inflammatory)<br>- ជំងឺផ្សេងទៀតទាក់ទងនឹងប្រដាប់បន្តពូជស្ត្រី។ (other disease related to urogenital system) | |
| 24 | ABO2 | ករណីរលូត/រំលូតកូនកំរិត CPA2 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - រលូតកូន (Miscarriage )<br>- កូនស្លាប់ក្នុងពោះ (Still birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នាឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ១២០.០០០ |
| 25 | PED2 | ករណីជំងឺទូទៅកុមារកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ដោយផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត២។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion )<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax) | ១០៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺបូសសួត (Pulmonary abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or chronic diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (severe/complicated malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/ leprosy )<br>- ជំងឺគ្រុនពោះវៀន (Typhoid fever)<br>- ជំងឺគ្រុនឈាម (Dengue fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (septicemia)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 26 | TUB2 | ករណីជំងឺរបេងកំរិត CPA2 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រនិងអមវេជ្ជសាស្ត្រ ដែលចាំបាច់ត្រូវផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែក | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary | *១៨០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | កម្រិត២។ | Tuberculosis)<br>- លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ ជំងឺឃ្លង់ដែលត្រូវការសម្រាកពេទ្យ។ | |
| 27 | CON3 | ករណីពិគ្រោះជំងឺក្រៅកំរិត CPA3 | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យបង្អែកកម្រិត៣ សេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ<br>- ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃ | - ជំងឺផ្តាសសាយទូទៅ (Common cold )<br>- ជំងឺផ្លូវដង្ហើមស្រួចស្រាវដែលគ្មានផលវិបាក (Uncomplicated acute respiratory infections)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without severe dehydration)<br>- ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ(Acute conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis media) | ២៤.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ខ្ពស់ ដូចជា CT-Scan, MRI, EEG មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | - ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយមិនដឹងមូលហេតុ (Headache , Fatigue ,fever... of Unknown origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) ( HIV/AIDS ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental Illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្ត្រ ចក្ខុសាស្ត្រ ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 28 | MIN3 | ករណីវះកាត់តូច តំរិត CPA3 | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia )<br>- ការវះកាត់ | - បូសធម្មតា (Cutaneous abscess)<br>- អាប់សែរាក់ៗ (Superficial abscess)<br>- របួសតូចតាច (Minor wound)<br>- រលាកស្រាល/មធ្យម(Mild/moderate burn) | ៥០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូច នៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ (ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth extraction )។ | |
| 29 | EMG3 | ករណីសង្គ្រោះបន្ទាន់កំរិត CPA3 | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ ដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ដោយសម្រាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន:<br>- ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory distress)<br>- ស្តុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe burn or hemorrhage)<br>- ពស់ចឹក (snake bite)<br>- ការពុល/ការលាងក្រពះ( intoxication with | ៣២០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | gastric lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with complication/stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe chest pain)<br>- ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 30 | SUR3 | ករណីសល្យសាស្ត្រកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ3) ឬការទាញបញ្ចូលនិងអបដោយរណបឬម្នាងសីលាក្នុងករណីភ្លាត់សន្លាក់ឬបាក់ឆ្អឹងដែលមិនតម្រូវឲ្យធ្វើការវះកាត់ នៅ | - ការប៉ះទង្គិចក្បាល (Head trauma)<br>- ការប៉ះទង្គិចពោះ (Abdominal trauma)<br>- ការប៉ះទង្គិចទ្រូង (Chest trauma)<br>- រហូសហូរឈាមក្នុងពោះ(Intra-abdominal hemorrhage)<br>- បូសថ្លើម (Liver abscess)<br>- គ្រួសក្នុងតំរងនោម (Kidney stone) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | មន្ទីរពេទ្យបង្អែកកម្រិត៣។ | - គ្រួសក្នុងផ្លោកនោម (Bladder stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់ (Gallbladder stone )។<br>- ភ្លាត់សន្លាក់ឆ្អឹង (Luxation) និងបាក់ឆ្អឹងដែលមិនតម្រូវឲ្យធ្វើការវះកាត់ (Closed Fracture)។ | |
| 31 | PRE3 | ករណីវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ កំរិត CPA3 | ជាអន្តរាគមន៍សល្យសាស្ត្រ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយក្នុងគោលបំណងបញ្ចប់កំណើតដោយចេតនាឬលក្ខខណ្ឌតម្រូវផ្សេងៗ។ | - ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស)<br>( Sterilization: tuboligation, vasectomy)។ | ៨០០.០០០ |
| 32 | MOP3 | ករណីវះកាត់មធ្យមកំរិត CPA3 | ជាអន្តរាគមន៍សល្យសាស្ត្រ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេសការវះកាត់សង្គ្រោះបន្ទាន់ឬគ្រោងទុកដែលមិនមានភាពស្មុគស្មាញ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ | - ជំងឺរលាកខ្នែងពោះវៀនគ្មានផលវិបាក ( Uncomplicated Appendicitis)<br>- ជំងឺក្លូនគ្មានផលវិបាក( Uncomplicated Hernia )<br>- កូនក្រៅស្បូនមិនទាន់ធ្លាយឈាម ( Non Rupture of Ectopic Pregnancy )<br>- គីស/ដុំអូវែគ្មានផលវិបាក | ៦០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត ៣។ | ( UnComplicated Ovarian Cyst/Tumor)<br>- ការវះកាត់ក្រពេញប្រូស្តាត(ដំពកឬមហារីកប្រូស្តាត) (Prostate Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រួសក្នុងប្លោកនោមឬមូលហេតុផ្សេងៗទៀតដែលនាំឲ្យមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or other causes)<br>- ការវះកាត់ភ្នែក (ភ្នែកឡើងបាយ របួសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury )<br>- ការវះកាត់យកកូនចេញ (Caesarian section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T major Surgery ) | |
| 33 | MAJ3 | ករណីវះកាត់ធំកំរិត CPA3 | ជាអន្តរាគមន៍សល្យសាស្ត្រ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/ | - ជំងឺរលាកខ្នែងពោះវៀនមានផលវិបាក (Complicated Appendicitis)<br>- ជំងឺក្លូនមានផលវិបាក(complicated Hernia)<br>- កូនក្រៅស្បូនធ្លាយឈាម (Rupture of | ១.០០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យបង្អែកកម្រិត៣។ | Ectopic Pregnancy)<br>- គីសឬដុំអូវែមានផលវិបាក(Complicated Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រួសក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់មូត្រសាស្ត្រនិងការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់កដោយប្រើអង់ដូស្កុប (Chirurgie Urologique ou ORL par Endoscopique)<br>- ការវះកាត់ដោយ Coelioscopique ជាអាទិ៍៖ គ្រួសក្នុងថង់ទឹកប្រមាត់ គីសឬដុំអូវែ កូនក្រៅស្បូនមិនទាន់ធ្លាយឈាម ។ល។<br>- ការវះកាត់ថង់ទឹកប្រមាត់ (គ្រួសក្នុងថង់ទឹកប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំឲ្យមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder stone or other causes) | |

| | | | | | |
|---|---|---|---|---|---|
| | | | | - ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ីតមានផលវិបាក) (Thyroid Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal occlusion, Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេងទៀត(ការបាក់ឆ្អឹង) (Amputation and other surgical interventions (bone fracture))<br>- ការវះកាត់ជំងឺបាយភ្នែកដោយ Phaco Machine (Phacoemulsification Cataract Surgery )។ | |
| 34 | MED3 | ករណីជំងឺទូទៅ | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជ | - ជំងឺរលាកសួត (Pneumonia) | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | មនុស្សពេញវ័យ កំរិត CPA3 | សាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or chronic diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal hemorrhage)<br>- ជំងឺរលាកស្រោមបេះដូងនិងជំងឺបេះដូងផ្សេងៗ (Pericarditis and other forms of | |

| | | | | | |
|---|---|---|---|---|---|
| | | | | Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid gland disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |
| 35 | DEL3 | ករណីសំរាលកូនកំរិត CPA3 | ជាការសំរាលនិងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣(AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ<br>- ប្រពោធនកម្មទារកបញ្ជូនពីមូលដ្ឋានសុខាភិបាលផ្សេងទៀត។ | ១៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការថែទាំនិងសង្គ្រោះទារកបន្ទាប់ពីសំរាលភ្លាម<br>- ប្រពោធនកម្មទារក (ការចិញ្ចឹមទារកក្នុងកែវ)<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | | |
| 36 | GYN3 | ករណីរោគស្ត្រីកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - ជំងឺមហារីកមាត់ស្បូន (Cervical cancer)<br>- ជំងឺមហារីកដោះ (Breast cancer)<br>- រលាកមាត់ស្បូនធ្ងន់ធ្ងរ (Severe cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina wound or injury)<br>- រលាកដៃស្បូន (Salpingitis)<br>- រលាកស្បូន (Endometriosis)<br>- រលាកអូវែ (Pelvic Inflammatory)<br>- ជំងឺផ្សេងទៀតទាក់ទងនឹងប្រដាប់បន្តពូជស្ត្រី។ (other disease related to urogenital system) | ២០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 37 | ABO3 | ករណីរលូត/រំលូតកូនកំរិត CPA3 | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូន ដោយឯកឯងនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ១៥០.០០០ |
| 38 | PED3 | ករណីជំងឺទូទៅកុមារកំរិត CPA3 | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis) | ១២៨.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង (Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 39 | TUB3 | ករណីជំងឺរបេងកំរិត CPA3 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ ដែលផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យបង្អែកកម្រិត៣។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis)<br>- លើកលែងតែទំរង់ស៊ាំនឹងថ្នាំច្រើនមុខ (except multidrug resistant forms) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | ២០០.០០០ |
| 40 | CON4 | ករណីពិគ្រោះជំងឺក្រៅកំរិត NH | ជាការពិគ្រោះជំងឺក្រៅករណីថ្មី និងករណីបន្តបន្ទាប់រួមទាំងការពិគ្រោះបញ្ជូន និងការពិគ្រោះឯកទេសគ្រប់កំរិតនៅមន្ទីរពេទ្យជាតិសេវាពិគ្រោះរួមមាន៖<br>- ការសាកសួរ<br>- ការពិនិត្យ | - ជំងឺផ្តាសសាយទូទៅ (Common cold )<br>- ជំងឺឆ្លងផ្លូវដង្ហើមស្រួចស្រាវដែលគ្មានផលវិបាក (Uncomplicated acute respiratory infections)<br>- ជំងឺរាគដែលមិនបាត់បង់ជាតិទឹកធ្ងន់ធ្ងរ (Diarrhea without severe dehydration) | ៦០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | - ការអប់រំសុខភាព<br>- ការប្រឹក្សាយោបល់<br>- ការផ្តល់សៀវភៅសុខភាព<br>- ការផ្តល់សេវាអមវេជ្ជសាស្ត្រ(សេវាមន្ទីរពិសោធន៍ អេកូសាស្ត្រ ការថតកាំរស្មីអិច ការវាស់អគ្គិសនីបេះដូង អេកូបេះដូង)<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)។<br>- សេវាអមវេជ្ជសាស្ត្រដែលមានតំលៃខ្ពស់ ដូចជា CT-Scan, MRI, EEG មិនគិតរួមបញ្ចូលក្នុងករណីនេះទេ។ | - ជំងឺគ្រុនចាញ់ដែលគ្មានផលវិបាក (Uncomplicated malaria)<br>- ជំងឺរបេងនិងឃ្លង់ដែលគេសង្ស័យនិងគ្មានផលវិបាក (Suspected and uncomplicated Tuberculosis/leprosy)<br>- ជំងឺគ្រុនពោះវៀនដែលធ្វើរោគវិនិច្ឆ័យបានទាន់ពេលវេលា (Early detection of Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue fever)<br>- ជំងឺភ្នែកក្រហមស្រួចស្រាវ(Acute conjunctivitis)<br>- ជំងឺរលាកត្រចៀកកណ្តាល (Otitis media)<br>- ជំងឺពុកធ្មេញ (Dental Caries)<br>- ជំងឺដង្កូវពោះវៀន (Intestinal Parasites)<br>- ជំងឺកាមរោគ(Sexual Transmitted Disease)<br>- ឈឺក្បាល អស់កម្លាំង ក្តៅខ្លួនដោយមិនដឹងមូលហេតុ (Headache , Fatigue ,fever... of Unknown origin)<br>- ជំងឺទឹកនោមផ្អែម ( Diabetes Mellitus )<br>- ជំងឺអេដស៍(អ្នកជំងឺដែលទទួលនូវថ្នាំប្រឆាំងនិងមេរោគអេដស៍ OI/ART) ( HIV/AIDS | |

| | | | | | |
|---|---|---|---|---|---|
| | | | | ambulatory OI/ART)<br>- ជំងឺផ្លូវចិត្ត ( Mental Illness )<br>- ជំងឺផ្សេងៗទៀតដែលមិនអាចពិគ្រោះព្យាបាលនៅថ្នាក់ក្រោមបាន គិតទាំងការថែទាំជំងឺឯកទេសគ្រប់ប្រភេទផ្នែកទន្តសាស្ត្រ ចក្ខុសាស្ត្រ ត្រចៀក/ច្រមុះ/បំពង់ក និងផ្លូវចិត្ត ប៉ុន្តែមិនចាំបាច់សម្រាកពេទ្យ ។ | |
| 41 | MIN4 | ករណីវះកាត់តូចកំរិត NH | ជាសកម្មភាពវះកាត់តូចមិនសម្រាកពេទ្យ ដែលរួមមាន៖<br>- ការចាក់ថ្នាំស្ពឹក(Local Anesthesia )<br>- ការវះកាត់<br>- ការបង្ហូរខ្ទុះ(Drainage)<br>- ការលាងសំអាត<br>- ការដេររបួស<br>- ការរុំរបួស<br>- ការព្យាបាល និងការផ្តល់ឱសថ (ឱសថដែលគ្រូពេទ្យចេញឲ្យប្រើ)<br>- សេវាចាំបាច់ដទៃទៀតសម្រាប់ករណីសល្យសាស្ត្រតូចនៅមន្ទីរពេទ្យជាតិ។ | - បូសធម្មតា (Cutaneous abscess)<br>- អាប់សែរាក់ៗ (Superficial abscess)<br>- របួសតូចតាច (Minor wound)<br>- រលាកស្រាល/មធ្យម(Mild/moderate burn)<br>- រលាកសាច់ដុំ (Myositis)<br>- គីសស្បែក (Sebaceous cyst)<br>- ដុំខ្លាញ់ (Lipoma)<br>- ការវះកាត់ស្បែកនៅចុងលិង្គ (ស្បែកបាំងចុងប្រដាប់ភេទបុរសទាំងមូលឬមួយផ្នែក) (Phymosis or Paraphymosis Circumcision)<br>- ការដកធ្មេញ (Tooth extraction )។ | ១០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| 42 | EMG4 | ករណីសង្គ្រោះបន្ទាន់កំរិត NH | ជាអន្តរាគមន៍(វេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ) សង្គ្រោះជីវិត ឬអវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះដែលចាំបាច់ផ្តល់ដោយផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យជាតិដោយសំរាកពេទ្យ។ | គ្រប់ស្ថានភាពវេជ្ជសាស្ត្រ/ជំងឺទាំងអស់ដែលត្រូវការសេវាសង្គ្រោះបន្ទាន់រួមមាន:<br>- ករណីលង់ទឹក (Drown )<br>- វិបត្តិដង្ហើម (Respiratory distress)<br>- ស្ហុក (Shock)<br>- ការប្រកាច់ (Convulsion)<br>- សន្លប់ (Coma)<br>- រលាកឬហូរឈាមធ្ងន់ធ្ងរ (Severe burn or hemorrhage)<br>- ពស់ចឹក (snake bite)<br>- ការពុល/ការលាងក្រពះ( intoxication with gastric lavage)<br>- គ្រោះថ្នាក់ចរាចរណ៍ (ករណីធ្ងន់ធ្ងរដែលត្រូវការតាមដាននៅមន្ទីរពេទ្យ និងសម្រាកពេទ្យ)<br>- ជំងឺលើសឈាមមានផលវិបាក ឬ គ្រោះថ្នាក់ដាច់ ឬ ស្ទះសរសៃឈាមខួរក្បាល (Hypertension with complication/stroke)<br>- ចុកទ្រូងធ្ងន់ធ្ងរ (Severe chest pain) | ៨០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺតេតាណូស (Tetanus )<br>- ជំងឺហើមសួតស្រួចស្រាវ ( Acute Pulmonary Edema)<br>- ស្ថានភាពវេជ្ជសាស្ត្រផ្សេងទៀតដែលត្រូវការសេវាសង្គ្រោះបន្ទាន់។ | |
| 43 | SUR4 | ករណីសល្យសាស្ត្រកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ផ្តល់ដោយផ្នែកសល្យសាស្ត្រ (លើកលែងករណីវះកាត់ធំដូចមានចែងក្នុងMAJ4)ឬការទាញបញ្ចូលនិងអបដោយរណបឬម្នាងសីលាក្នុងករណីភ្លាត់សន្លាក់ឬបាក់ឆ្អឹងដែលមិនតម្រូវឲ្យធ្វើការវះកាត់ នៅមន្ទីរពេទ្យជាតិ។ | - ការប៉ះទង្គិចក្បាល (Head trauma)<br>- ការប៉ះទង្គិចពោះ (Abdominal trauma)<br>- ការប៉ះទង្គិចទ្រូង (Chest trauma)<br>- រប្វួសហូរឈាមក្នុងពោះ(Intra-abdominal hemorrhage)<br>- បូសថ្លើម (Liver abscess)<br>- គ្រួសក្នុងតំរងនោម (Kidney stone)<br>- គ្រួសក្នុងថ្លោកនោម (Bladder stone)<br>- គ្រួសក្នុងថង់ទឹកប្រម៉ាត់(Gallbladder stone )។<br>- ភ្លាត់សន្លាក់ឆ្អឹង (Luxation) និងបាក់ឆ្អឹងដែលមិនតម្រូវឲ្យធ្វើការវះកាត់ (Closed Fracture)។ | ៦០០.០០០ |
| 44 | MOP4 | ករណីវះកាត់ | ជាអន្តរាគមន៍សល្យសាស្ត្រ ធ្វើនៅក្នុង | - ជំងឺរលាកខ្នែងពោះវៀនគ្មានផលវិបាក | ១.000.000 |



AR.

| | | | | | |
|---|---|---|---|---|---|
| | | មធ្យមកំរិត NH | បន្ទប់វះកាត់ ដោយប្រើថ្នាំសណ្ដំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ឬគ្រោងទុក ដែលមិនមានភាពស្មុគស្មាញ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | ( Uncomplicated Appendicitis)<br>- ជំងឺក្លូនគ្មានផលវិបាក( Uncomplicated Hernia )<br>- កូនក្រៅស្បូនមិនទាន់ធ្លាយឈាម ( Non Rupture of Ectopic Pregnancy )<br>- គីស/ដុំអូវែគ្មានផលវិបាក ( UnComplicated Ovarian Cyst/Tumor)<br>- ការវះកាត់ក្រពេញប្រូស្តាត(ដំពកឬមហារីកប្រូស្តាត) (Prostate Surgery including Prostate Tumor Or Cancer)<br>- ការវះកាត់ប្លោកនោម (គ្រួសក្នុងប្លោកនោម ឬមូលហេតុផ្សេងៗទៀតដែលនាំឲ្យមានជំងឺប្លោកនោម) (Bladder Surgery including Bladder stone or other causes)<br>- ការវះកាត់ភ្នែក (ភ្នែកឡើងបាយ របួសភ្នែក) (Ophthalmic Surgery including Cataract, Eye Injury )<br>- ការវះកាត់យកកូនចេញ (Caesarian section)<br>- ការវះកាត់ធំផ្នែកត្រចៀក/ច្រមុះ/បំពង់ក ( E-N-T major Surgery ) | |

| | | | | | |
|---|---|---|---|---|---|
| 45 | MAJ4 | ករណីវះកាត់ធំ កំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រធំធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយជាពិសេស ការវះកាត់សង្គ្រោះបន្ទាន់ និងការថែទាំ/សង្គ្រោះមុន និងក្រោយវះកាត់ដោយរួមទាំងការបញ្ចូលឈាមនៅក្នុងមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកខ្នែងពោះវៀនមានផលវិបាក (Complicated Appendicitis)<br>- ជំងឺក្លូនមានផលវិបាក(complicated Hernia)<br>- កូនក្រៅស្បូនធ្លាយឈាម (Rupture of Ectopic Pregnancy)<br>- គីសឬដុំអូវែមានផលវិបាក(Complicated Ovarian Cyst/Tumor )<br>- រលាកស្រោមពោះ (Peritonitis)<br>- ការវះកាត់តំរងនោម (គ្រួសក្នុងតំរងនោម ឬជំងឺតំរងនោមដោយមូលហេតុផ្សេងៗ) (Renal Surgery including Kidney stone or other causes)<br>- ការវះកាត់មូត្រសាស្ត្រ ដោយប្រើអង់ដូស្កុប (Chirurgie Urologique par Endoscopique)។<br>- ការវះកាត់ដោយ Coelioscopique ជាអាទិ៍៖ គ្រួសក្នុងថង់ទឹកប្រមាត់ គីសឬដុំអូវែ កូនក្រៅស្បូនមិនទាន់ធ្លាយឈាម ។ល។<br>- ការវះកាត់ថង់ទឹកប្រមាត់ (គ្រួសក្នុងថង់ទឹក | ១.៥០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | ប្រមាត់ ឬ មូលហេតុផ្សេងៗទៀតដែលនាំឲ្យមានជំងឺថង់ទឹកប្រមាត់) (Gallbladder Surgery including Gallbladder stone or other causes)<br>- ការវះកាត់ស្បូន ( ការធ្លាយស្បូន ជំងឺស្រុតស្បូន ដុំសាច់ស្បូន) (Uterus Surgery including Uterus Rupture, Prolapse, Tumor)<br>- ការវះកាត់ដុំពោះ (Abdominal Tumor Surgery)<br>- ការវះកាត់ក្រពេញទីរ៉ូអ៊ីត(ជំងឺក្រពេញទីរ៉ូអ៊ីតរួមទាំងមានផលវិបាក) (Thyroid Surgery including Complicated Thyroid disease)<br>- ការវះកាត់ពោះវៀន ( ការស្ទះពោះវៀន , របួសពោះវៀន) (Intestinal Surgery including Intestinal occlusion, Injury)<br>- ការវះកាត់អវៈយវៈ ឬការវះកាត់ឆ្អឹងផ្សេងទៀត(ការបាក់ឆ្អឹង) (Amputation and other surgical interventions (bone fracture)) | |



Ha.

| | | | | | |
|---|---|---|---|---|---|
| | | | | - ការវះកាត់ជំងឺបាយភ្នែកដោយ Phaco Machine (Phacoemulsification Cataract Surgery ) | |
| 46 | PRE4 | ករណីវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ កំរិត NH | ជាអន្តរាគមន៍សល្យសាស្ត្រ ធ្វើនៅក្នុងបន្ទប់វះកាត់ ដោយប្រើថ្នាំសណ្តំទូទៅ (ថ្នាំសន្លប់) ឬថ្នាំស្ពឹកតាមឆ្អឹងខ្នង ឬថ្នាំស្ពឹកនៅនឹងកន្លែងទូលាយក្នុងគោលបំណងបញ្ចប់កំណើតដោយចេតនាឬលក្ខខណ្ឌតម្រូវផ្សេងៗ។ | - ការវះកាត់បង្ការកំណើតអចិន្ត្រៃយ៍ (ចងដៃស្បូន ចងបំពង់មេជីវិតបុរស) ( Sterilization: tuboligation, vasectomy)។ | ៦០០.០០០ |
| 47 | MED4 | ករណីជំងឺទូទៅមនុស្សពេញវ័យ កំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់មនុស្សពេញវ័យផ្តល់ដោយផ្នែកជំងឺទូទៅនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ (Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត (Pulmonary Abscess)<br>- ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or chronic diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/complicated Malaria) | ៨០០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរបេង/ឃ្លង់ ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺរលាកក្រពះ (Gastritis)<br>- ជំងឺដំបៅក្រពះ (Gastric Ulcer )<br>- ហូរឈាមខាងក្នុងពោះ (Intra-abdominal hemorrhage)<br>- ជំងឺរលាកស្រោមបេះដូងនិងជំងឺបេះដូងផ្សេងៗ (Pericarditis and Other Forms of Cardiopathy)<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ជំងឺទឹកនោមផ្អែម (Diabetes Mellitus)<br>- ជំងឺលើសឈាម (Hypertension)<br>- ជំងឺសន្លាក់ (Arthropathy)<br>- ជំងឺក្រពេញទីរ៉ូអ៊ីត(Thyroid gland disease)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ។ | |

| | | | | | |
|---|---|---|---|---|---|
| 48 | DEL4 | ករណីសំរាលកូនកំរិត NH | ជាការសំរាលកូននិងសេវាចាំបាច់ដទៃទៀតរួមមាន៖<br>- ការបញ្ចូលសេរ៉ូម<br>- ការចាក់ថ្នាំ Oxytocin ជាចំណែកមួយនៃការគ្រប់គ្រងការសំរាលសកម្មដំណាក់កាលទី៣(AMTSL)<br>- ការបូមយកកូន និងការប្រើសំភារៈជំនួយការសំរាលផ្សេងទៀត<br>- ការដេរស្នាមកាត់ ឬ ដាច់ទ្វារមាស ការជួសជុលមាត់ស្បូនរហែកឡើងវិញ<br>- ការថែទាំនិងសង្គ្រោះទារកបន្ទាប់ពីសំរាលភ្លាម<br>- ប្រពោធនកម្មទារក (ការចិញ្ចឹមទារកក្នុងកែវ)<br>- ការថែទាំនិងតាមដានក្រោយសំរាលសម្រាប់ការសំរាលធម្មតា ឬ មានផលវិបាកនៅមន្ទីរពេទ្យជាតិ។ | - ការសំរាលកូនធម្មតា (Normal delivery)<br>- ការសំរាលកូនពិបាកដែលមិនត្រូវការវះកាត់យកកូនចេញ ។<br>- ប្រពោធនកម្មទារកបញ្ជូនពីមូលដ្ឋានសុខាភិបាលផ្សេងទៀត។ | ៤00.000 |
| 49 | GYN4 | ករណីរោគស្ត្រីកំរិត NH | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ | - ជំងឺមហារីកមាត់ស្បូន (Cervical cancer)<br>- ជំងឺមហារីកដោះ (Breast cancer) | ៤00.000 |

| | | | | | |
|---|---|---|---|---|---|
| | | | ផ្តល់ដោយផ្នែកសម្ភព/រោគស្ត្រីនៅមន្ទីរពេទ្យជាតិ។ | - រលាកមាត់ស្បូនធ្ងន់ធ្ងរ (Severe cervicitis)<br>- គ្រោះថ្នាក់រហែកទ្វារមាស (Vagina wound or injury)<br>- រលាកដៃស្បូន (Salpingitis)<br>- រលាកស្បូន (Endometriosis)<br>- រលាកអាងត្រគាក (Pelvic Inflammatory)<br>ជំងឺផ្សេងទៀតទាក់ទងនឹងប្រដាប់បន្តពូជស្ត្រី។ (other disease related to urogenital system) | |
| 50 | ABO4 | ករណីរលូត/រំលូតកូនកំរិត NH | ការរំលូតកូនស្របច្បាប់ និងសេវាចាំបាច់សំរាប់ការរំលូតដោយសុវត្ថិភាព ព្រមទាំងការថែទាំក្រោយរំលូត/រលូតកូនដោយឯកឯងនៅមន្ទីរពេទ្យជាតិ។ | - រលូតកូន (Miscarriage)<br>- កូនស្លាប់ក្នុងពោះ (Still birth)<br>- ការពពោះដែលមិនតាមបំណងប្រាថ្នា ឬការពពោះដែលមិនសមស្របតាមផ្នែកវេជ្ជសាស្ត្រ ។ | ៤០០.០០០ |
| 51 | PED4 | ករណីជំងឺទូទៅកុមារកំរិត NH | ជាការសម្រាកពេទ្យសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់សម្រាប់កុមារ ផ្តល់ជូននៅផ្នែកជំងឺកុមារនៅមន្ទីរពេទ្យជាតិ។ | - ជំងឺរលាកសួត (Pneumonia)<br>- ជំងឺរលាកទងសួតធ្ងន់ធ្ងរ(Severe Bronchitis)<br>- ជំងឺហឺត (Asthma)<br>- ជំងឺទឹកក្នុងស្រោមសួត (Pleural Effusion)<br>- ជំងឺខ្យល់ក្នុងស្រោមសួត (Pneumothorax)<br>- ជំងឺបូសសួត( Pulmonary Abscess) | ៣៥០.០០០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ជំងឺរាគធ្ងន់ធ្ងរឬរ៉ាំរ៉ៃ (Severe or Chronic Diarrhea)<br>- ជំងឺគ្រុនចាញ់ធ្ងន់ធ្ងរឬផ្តល់ផលវិបាក (Severe/Complicated Malaria)<br>- ជំងឺរបេង/ឃ្លង់ដែលមានផលវិបាក (Complicated Tuberculosis/Leprosy)<br>- ជំងឺគ្រុនពោះវៀន (Typhoid Fever)<br>- ជំងឺគ្រុនឈាម (Dengue Fever)<br>- ជំងឺរលាកស្រោមខួរក្បាល (Meningitis)<br>- ជំងឺរលាកខួរក្បាល (Encephalitis)<br>- ជំងឺអេដស៍ (HIV/AIDS)<br>- ជំងឺបេះដូង ( Cardiopathy )<br>- ជំងឺមេរោគរាតត្បាតក្នុងឈាម (Septicemia)<br>- ជំងឺតេតាណូស (Tetanus)<br>- ស្ថានភាពវេជ្ជសាស្ត្រដទៃដែលត្រូវការសម្រាកពេទ្យ ។ | |
| 52 | TUB4 | ករណីជំងឺរបេងគំរិត NH4 | ជាការសម្រាកពេទ្យរួមទាំងសេវាវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រ ដែលចាំបាច់ដែលផ្តល់ដោយផ្នែកជំងឺរបេងនៅមន្ទីរពេទ្យជាតិ។ | - គ្រប់ទំរង់នៃជំងឺរបេងសួត (All forms of Pulmonary Tuberculosis)<br>- ជំងឺរបេងក្រៅសួត (Extra-pulmonary Tuberculosis) | ៣00.000 |

| | | | | | |
|---|---|---|---|---|---|
| | | | | - លើកលែងតែទំរង់ជំងឺរបេងស៊ាំនឹងថ្នាំច្រើនមុខ(except multidrug resistant forms) ជំងឺឃ្លង់(Leprosy)ដែលត្រូវការសម្រាកពេទ្យ។ | |

# ឧបសម្ព័ន្ធទី២
# ប្រកាសអន្តរក្រសួងលេខ ១៧៣
# ក.ប/ប្រ.ក ចុះថ្ងៃទី0៥ ខែឧសភា
# ឆ្នាំ២0១៦ ស្តីពីយន្តការទូទាត់
# ថ្លៃសេវាផ្នែកថែទាំសុខភាព

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**                    **ក្រសួងសុខាភិបាល**

លេខ............១៧៣......ក.ប/ប្រ.ក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## យន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**          **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់យន្តការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ សេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ដែល ប.ស.ស ត្រូវផ្តល់ជូនមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀង ឬ មូលដ្ឋានសុខាភិបាលដែលបានផ្តល់សេវាសង្គ្រោះបន្ទាន់។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ ៖

- ***យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*** សំដៅដល់វិធីសាស្ត្រនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព សម្រាប់ផ្នែកថែទាំសុខភាព ។
- ***សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ*** សំដៅដល់សេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រ និងសេវាជំនួយវេជ្ជសាស្ត្រ។
- ***សេវាវេជ្ជសាស្ត្រ*** សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- ***សេវាអមវេជ្ជសាស្ត្រ*** សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- ***សេវាជំនួយវេជ្ជសាស្ត្រ*** សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា។
- ***សេវាស្តារនីតិសម្បទា*** គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់ផ្នែកថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬ ធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាព ជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

- ***វិធីសាស្ត្រទូទាត់តាមករណី*** សំដៅដល់ការទូទាត់ក្នុងអត្រាថេរមួយ ដែលគ្រប ដណ្តប់លើគ្រប់តម្លៃសេវាសម្រាប់មួយករណីនៃអ្នកជំងឺម្នាក់ ឬប្រភេទជំងឺជាក់លាក់ណាមួយ។
- ***វិធីសាស្ត្រទូទាត់តាមប្រភេទសេវា*** គឺជាការទូទាត់ថ្លៃសេវាដោយផ្អែកទៅលើប្រភេទសេវាផ្សេងៗគ្នា ហើយមានតម្លៃដាច់ដោយឡែកពីគ្នា។
- ***អន្តរាគមន៍*** សំដៅដល់សកម្មភាពព្យាបាល ឬជួយសង្គ្រោះជនរងគ្រោះ ឬអ្នកជំងឺដែលស្ថិតនៅក្នុងស្ថានភាពវិករ។
- ***មូលដ្ឋានសុខាភិបាល*** សំដៅដល់អង្គភាពព្យាបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

**ប្រការ ៣.-**

យន្តការនៃការទូទាត់ថ្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវបានកំណត់តាមវិធីសាស្ត្រពីរយ៉ាង គឺវិធីសាស្ត្រទូទាត់ថ្លៃតាមករណី និង វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា។

វិធីសាស្ត្រទូទាត់ថ្លៃតាមករណី ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់តាមអត្រាតម្លៃថេរតាមប្រភេទករណីជំងឺ និងតាមកម្រិតមូលដ្ឋានសុខាភិបាលនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា ត្រូវបានអនុវត្តចំពោះប្រភេទសេវាសម្រាប់ករណីពិសេស ដូចមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

វិធីសាស្ត្រដែលកំណត់នៅក្នុងប្រកាសនេះ ត្រូវអនុវត្តសម្រាប់ផ្នែកថែទាំសុខភាព ដែលស្ថិតនៅក្នុងដែនអនុវត្តរបស់ ប.ស.ស និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា។

**ប្រការ ៤.-**

ប.ស.ស ត្រូវទូទាត់សងទៅមូលដ្ឋានសុខាភិបាល ឬសាមីជន តាមវិធីសាស្ត្រទូទាត់ថ្លៃដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ក្នុងករណីសង្គ្រោះបន្ទាន់។ ក្នុងករណីនេះ ជនរងគ្រោះ ឬអ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត ។

ប្រសិនបើ ការសង្គ្រោះបន្ទាន់ធ្វើនៅក្នុងមូលដ្ឋានសុខាភិបាល ដែលមិនមានកិច្ចព្រមព្រៀងជាមួយ ប.ស.ស សាមីជន ឬ អ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស។

**ប្រការ ៥.-**

ការទូទាត់ថ្លៃសេវាបញ្ជូនជនរងគ្រោះ ឬ អ្នកជំងឺ សម្រាប់ផ្នែកថែទាំសុខភាព ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ ដែលប្រើប្រាស់ប្រភេទមធ្យោបាយបញ្ជូនដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់។

ការទូទាត់ថ្លៃសេវាបញ្ជូន ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៦.-**

ការបញ្ជូនសព ឬ បញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬ ប្រភេទមធ្យោបាយដាក់ស្តែងផ្សេងទៀត។ ការទូទាត់ថ្លៃសេវាបញ្ជូននេះ ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៧.-**

ការទូទាត់ថ្លៃសេវាស្តារនីតិសម្បទា ត្រូវអនុវត្តគោលការណ៍ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ។

**ប្រការ ៨.-**

របៀបទូទាត់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ចំពោះមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីកិច្ចព្រមព្រៀងប្រើប្រាស់និងផ្តល់សេវារវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយមូលដ្ឋានសុខាភិបាល ដែលចេញដោយរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ ៩.-**

រៀងរាល់ដំណាច់ឆ្នាំ ប.ស.ស ត្រូវវិភាគវាយតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ដោយផ្អែកលើតម្លៃសេវាហិរញ្ញប្បទាន និងតម្លៃចំណាយផ្សេងៗ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

ការកែប្រែប្រភេទករណី ឬតម្លៃទូទាត់សេវាដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ត្រូវធ្វើឡើងដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

និយមន័យនៃករណីក្នុងយន្តការទូទាត់ថ្លៃសេវាដូចមាន ចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ អាចត្រូវបានកំណត់ឡើងវិញ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស។

**ប្រការ ១០.-**

វិធីសាស្ត្រទូទាត់ដទៃទៀត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃប.ស.ស បន្ទាប់ពីទទួលយោបល់ពីគណៈកម្មការវេជ្ជសាស្ត្រនៃប.ស.ស ដោយយោង

តាមស្ថានភាពជាក់ស្តែង នៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងការវិភាគហិរញ្ញវត្ថុនៃផ្នែកថែទាំសុខភាព។

**ប្រការ ១១.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និយោជកម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព*

## ១. វិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា

ឧបសម្ព័ន្ធនេះមានគោលបំណងរៀបចំវិធីសាស្ត្រទូទាត់ថ្លៃតាមប្រភេទសេវា សម្រាប់ករណីពិសេសតាមតារាងតម្លៃសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ របស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ផ្នែកថែទាំសុខភាព។

**ក. វិធីសាស្ត្រនេះត្រូវអនុវត្តចំពោះប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាលនិងថែទាំបន្ត និងករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.១ ប្រភេទករណីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តដូចខាងក្រោម៖**

**ក.១.១ ការលាងឈាម** គឺជាការលាងឈាមបណ្តាលមកពីឧបទ្ទវហេតុគ្រោះថ្នាក់ផ្សេងៗ ឬសង្គ្រោះបន្ទាន់ ។

***ចំពោះករណីលាងឈាមតាមការគ្រោងទុកដែលបណ្តាលមកពីជំងឺរ៉ាំរ៉ៃ មិនត្រូវបានរាប់បញ្ចូលឡើយ។***

**ក.១.២ MRI (Magnetic Resonance Imaging)** គឺជាបច្ចេកទេសរូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពទៅតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៣ CT SCAN** គឺជាទម្រង់រូបភាពវេជ្ជសាស្ត្រដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមស្ថានភាពចាំបាច់ និងមនសិការវិជ្ជាជីវៈ។

**ក.១.៤ ការព្យាបាលដោយកាំរស្មីអ៊ិច (Radiotherapy)** គឺជាការព្យាបាលជំងឺមហារីកដោយកាំរស្មីអ៊ិចផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ។

**ក.១.៥ ការវិភាគរកកោសិកាមហារីក** គឺជាការវិភាគចំណិតដុំសាច់នៃសរីរាង្គឬផ្នែកណាមួយនៃរាងកាយដើម្បីរកកោសិកាមហារីក ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

**ក.១.៦ MATERIEL OSTEOSYNTHESE** គឺជាលោហៈដែលប្រើប្រាស់សម្រាប់តភ្ជាប់ឆ្អឹងដែលបែកបាក់។

**ក.១.៧ បន្ទប់ម៉ាស៊ីនត្រជាក់** គឺផ្អែកទៅតាមស្ថានភាពជាក់ស្តែង និង ការព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

**ក.១.៨ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះសម្រាប់របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព** គឺជាការបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ក្នុងករណីសង្គ្រោះបន្ទាន់ដោយរថយន្តសាមុយ(SAMU) ឬរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬ មធ្យោបាយផ្សេងៗទៀត ។ ការទូទាត់ថ្លៃសេវាបញ្ជូនត្រូវកំណត់ដោយប.ស.ស ផ្អែកទៅលើប្រភេទមធ្យោបាយបញ្ជូន និងទៅតាមតារាងតម្លៃសេវារបស់មូលដ្ឋានសុខាភិបាលសាធារណៈ ឬបន្ថែម៣០% (សាមសិបភាគរយ)ចំពោះប្រភេទមធ្យោបាយបញ្ជូនដោយរថយន្ត សាមុយ (SAMU) ឬ រថយន្តគិលានសង្គ្រោះ របស់មូលដ្ឋានសុខាភិបាលឯកជនឬតាមមធ្យោបាយជាក់ស្តែង។

**ក.១.៩ ការបញ្ជូនសព** គឺជាការបញ្ជូនសពឬអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជាតាមគ្រប់ប្រភេទមធ្យោបាយបញ្ជូនពីកន្លែងគ្រោះថ្នាក់ ឬពី មូលដ្ឋានសុខាភិបាលទៅកាន់លំនៅស្ថានឬឈាបនដ្ឋានសម្រាប់ផ្នែកថែទាំសុខភាព។ ការទូទាត់ថ្លៃសេវាបញ្ជូនសពនេះផ្អែកតាមតម្លៃសេវាមូលដ្ឋានសុខាភិបាលសាធារណៈដែលបានផ្តល់សេវានោះឬផ្អែកទៅតាមតម្លៃកំណត់ដោយ

ប.ស.ស ដោយឈរលើស្ថានភាពទីតាំងភូមិសាស្ត្រ ចម្ងាយ និងប្រភេទមធ្យោបាយបញ្ជូន ។

**ក.១.១០ សេវាស្តារនីតិសម្បទា** គឺជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រសម្រាប់ផ្នែកថែទាំសុខភាព ក្នុងគោលបំណងជួយដល់ជនរងគ្រោះ រក្សាស្តារ ឬធ្វើឲ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទង ដែលបានបាត់បង់ ឬ ខូចខាតដោយសារជំងឺ រងរបួស ឬពិការភាព។ ការផ្តល់សេវាស្តារនីតិសម្បទា ឬសម្ភារៈបរិក្ខារ និងឧបករណ៍សិប្បនិម្មិត ឬ ត្រូវផ្តល់ទាំងអស់ហើយត្រូវកំណត់ជ្រើសរើស និង វាយតម្លៃដោយ ប.ស.ស ផ្អែកទៅលើស្ថានភាព និងតារាងតម្លៃសេវារបស់អង្គភាព ឬ ស្ថាប័នរដ្ឋ ឬ ឯកជនដែលផ្តល់សេវានោះ។

**ក.២ ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧបសម្ព័ន្ធទី១**

**ក.២.១ ការចោះ ឬដាប់ឆ្អឹងលលាដ៍ក្បាល (Trepanation)** គឺជាអន្តរាគមន៍វះកាត់ដោយចោះ ឬ ដាប់ឆ្អឹងលលាដ៍ក្បាល ដើម្បីពិនិត្យស្រទាប់ក្រៅ នៃស្រោមខួរក្បាល និងព្យាបាល បញ្ហាសុខភាពទាក់ទង និងជំងឺក្នុងស្រទាប់ក្រៅនៃស្រោមខួរ និងក្នុងខួរក្បាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។

**ក.២.២ ការវះកាត់បេះដូងនិងសរសៃឈាម** គឺជាការវះកាត់បេះដូងនិងសរសៃឈាមធំៗដោយគ្រូពេទ្យឯកទេសវះកាត់បេះដូង ក្នុងករណីសង្គ្រោះបន្ទាន់សម្រាប់ផ្នែកថែទាំសុខភាព។ ចំពោះការវះកាត់បេះដូង និងសរសៃឈាមតាមការគ្រោងទុកមិនត្រូវបានរាប់បញ្ចូលឡើយ។

**ក.២.៣ ការព្យាបាលសង្គ្រោះបន្ទាន់ជំងឺបេះដូង** គឺជាអន្តរាគមន៍ព្យាបាល និងថែទាំវេជ្ជសាស្ត្រឯកទេសបេះដូងក្នុងគោលបំណងសង្គ្រោះអាយុជីវិតរបស់អ្នកជំងឺ ឬជនរងគ្រោះ សម្រាប់របបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព។

អន្តរាគមន៍នេះសម្រាប់តែមជ្ឈមណ្ឌលព្យាបាលជំងឺបេះដូងភ្នំពេញ ឬមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងពិសេស ជាមួយបេឡាជាតិរបបសន្តិសុខសង្គមប៉ុណ្ណោះ ។

ខ. ប.ស.ស នឹងធ្វើការទូទាត់តាមប្រភេទសេវាសម្រាប់ករណី ក.១ និង ក.២ ដូចខាងក្រោម៖

ខ.១ សម្រាប់ប្រភេទករណីដូចមានចែងក្នុងចំណុច ក.១ នៃឧបសម្ព័ន្ធនេះ មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់តាមប្រភេទសេវាសម្រាប់ថ្លៃសេវាពិសេសបន្ថែម ឬ សេវាព្យាបាល និងថែទាំបន្តទៅតាមតម្លៃហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬ ទៅតាមការព្រមព្រៀង។ ការទូទាត់នេះមិនរាប់បញ្ចូលការទូទាត់តាមករណី ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១ ទេ។

ខ.២ សម្រាប់ករណីពិសេសដូចមានចែងក្នុងចំណុចក.២ នៃឧបសម្ព័ន្ធនេះមូលដ្ឋានសុខាភិបាល នឹងទទួលបានការទូទាត់ថ្លៃសេវាតាមប្រភេទសេវាហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬទៅតាមការព្រមព្រៀង។

# ឧបសម្ព័ន្ធទី៣

# ប្រកាសអន្តរក្រសួងស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងមូលដ្ឋានសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ.........៧៩១........ក.ប/ប្រ.ក

ក្រសួងសុខាភិបាល

# ប្រកាសអន្តរក្រសួង

## ស្តីពី

## កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាង បេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់បែបបទ និង នីតិវិធីនៃការចុះកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) និងមូលដ្ឋានសុខាភិបាល សម្រាប់ផ្នែកថែទាំសុខភាព។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ៖

- សេវាសុខាភិបាល សំដៅដល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬ ជនរងគ្រោះ និងសេវាបញ្ជូនសព។
- សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សំដៅដល់សេវាវេជ្ជសាស្ត្រ សេវាអមវេជ្ជសាស្ត្រ និងសេវាជំនួយវេជ្ជសាស្ត្រ។
- សេវាវេជ្ជសាស្ត្រ សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- សេវាអមវេជ្ជសាស្ត្រ សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- សេវាជំនួយវេជ្ជសាស្ត្រ សំដៅដល់ការព្យាបាលដោយស្ទុំ និងដោយចលនា។
- មូលដ្ឋានសុខាភិបាល សំដៅដល់អង្គភាពព្យាបាលសាធារណៈ ឬឯកជនដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។

- កិច្ចព្រមព្រៀង សំដៅដល់នីតិវិធីនិងបែបបទនៃការផ្តល់សេវាសុខាភិបាលដោយមូលដ្ឋានសុខាភិបាលនិងការប្រើប្រាស់សេវាសុខាភិបាលរបស់សមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ។

**ប្រការ ៣.-**

**៣.១** មូលដ្ឋានសុខាភិបាលសាធារណៈត្រូវមានកាតព្វកិច្ចចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដោយអនុវត្តតាមទម្រង់កិច្ចព្រមព្រៀងដូចមានចែងក្នុងឧបសម្ព័ន្ធ១ សម្រាប់មណ្ឌលសុខភាព ឧបសម្ព័ន្ធ២ សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ និងឧបសម្ព័ន្ធ៣ សម្រាប់មន្ទីរពេទ្យជាតិ។

**៣.២** មូលដ្ឋានសុខាភិបាលឯកជន អាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស បានលុះត្រាតែមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតផ្តល់សេវា និងគុណភាពសេវាពី ប.ស.ស។

**៣.៣** ប.ស.ស អាចចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ដោយផ្អែកលើសេចក្តីត្រូវការចាំបាច់ ទីតាំងភូមិសាស្ត្រ និងស្ថានភាពមូលដ្ឋានសុខាភិបាលព្រមទាំងមានធនធានហេដ្ឋារចនាសម្ព័ន្ធសមស្រប ឬគ្រប់គ្រាន់ សម្រាប់ការផ្តល់សេវាសុខាភិបាលឲ្យមានគុណភាព ក្នុងនោះរួមមាន៖

- អគារសមរម្យ និងបរិស្ថានអនាម័យល្អ
- ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ និងមធ្យោបាយចាំបាច់នានាសម្រាប់គាំទ្រការធ្វើរោគវិនិច្ឆ័យ និងផ្តល់ការព្យាបាលនិងថែទាំតាមវិធាន បទបញ្ជា និងអាជ្ញាប័ណ្ណផ្សេងៗរបស់ក្រសួងសុខាភិបាល។ បុគ្គលិកសុខាភិបាលមានសមត្ថភាពបច្ចេកទេស និងក្រមសីលធម៌ និងមានចំនួនសមស្របតាមការកំណត់របស់ក្រសួងសុខាភិបាល។

**ប្រការ ៤.-**

**៤.១** ការទូទាត់ថ្លៃសេវា ជូនមូលដ្ឋានសុខាភិបាល អាចធ្វើទៅបានលុះត្រាតែមានការកំណត់ពីលទ្ធភាពផ្តល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ កម្រិតនៃការទូទាត់ថ្លៃតាមប្រភេទករណី និងកម្រិតនៃការទូទាត់ថ្លៃតាមប្រភេទសេវា ដោយ ប.ស.ស។ ទោះជាយ៉ាងណាក៏ដោយ ការកំណត់ពីកម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលនេះ មិនត្រូវទាបជាងកម្រិតកំណត់ដោយក្រសួងសុខាភិបាលឡើយ។

**៤.២** ការទូទាត់ថ្លៃសេវា ជូនមូលដ្ឋានសុខាភិបាល ត្រូវអនុវត្តតាមយន្តការទូទាត់ថ្លៃសេវាដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាថែទាំសុខភាព។

៤.៣ ប.ស.ស ត្រូវទូទាត់ថ្លៃសេវាជូនមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងតាមរយៈប្រព័ន្ធធនាគារ។ ការទូទាត់នេះត្រូវធ្វើឡើងទៅតាមកាលវិភាគ បែបបទ និងនីតិវិធីដូចមានចែងក្នុងឧបសម្ព័ន្ធនីមួយៗនៃប្រកាសនេះ។

៤.៤ ប.ស.ស អាចបដិសេធការទូទាត់ថ្លៃសេវាទាំងស្រុង ឬមួយផ្នែកនៃថ្លៃសេវាដែលស្នើដោយមូលដ្ឋានសុខាភិបាល នៅក្នុងករណីដូចខាងក្រោម៖

- សេវាសុខាភិបាលដែលផ្តល់ឲ្យ លើសពីតម្រូវការចាំបាច់ នៃបញ្ហាសុខភាព ឬលក្ខខណ្ឌជំងឺ។
- អន្តរាគមន៍ ឬ បែបបទនៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់ការព្យាបាល និងថែទាំមិនស្របតាមពិធីសារ នៃការព្យាបាល ឬ គោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងសុខាភិបាល។
- ប្រើប្រាស់ឱសថមានគុណភាពអន់ ឬ គ្មានប្រភពច្បាស់លាស់ ឬគ្មានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងការចេញវេជ្ជបញ្ជាមិនត្រឹមត្រូវ។
- ក្លែងបន្លំឯកសារ ឬ ផ្តល់ព័ត៌មានមិនពិត ដែលជាយន្តការសម្រាប់ការទូទាត់ថ្លៃសេវា។ និង
- ការទទួលយកនូវការអនុវត្តតាមបទដ្ឋាន និងការព្យាបាលដែលមានគម្លាតខុសគ្នាទាំងស្រុង។

**ប្រការ ៥.-**

៥.១ ប.ស.ស ត្រូវត្រួតពិនិត្យតាមដានគុណភាពសេវាសុខាភិបាល ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាលបានចុះកិច្ចព្រមព្រៀង និង និន្នាការនៃការប្រើប្រាស់សេវាសុខាភិបាលរបស់សមាជិក ប.ស.ស ដោយអនុវត្តយន្តការត្រួតពិនិត្យតាមដានជាកាលិក ព្រមទាំងសហប្រតិបត្តិការផ្តល់ព័ត៌មានទៅវិញទៅមក ដើម្បីលើកកម្ពស់គុណភាពសេវាជាប្រចាំ និងតម្រង់ទិសការប្រើប្រាស់សេវារបស់សមាជិក ប.ស.ស ឲ្យមានប្រសិទ្ធភាព។

៥.២ ការត្រួតពិនិត្យតាមដានគុណភាពសេវាសុខាភិបាល ត្រូវផ្តោតជាចំបងលើរចនាសម្ព័ន្ធគុណភាពសេវា កម្រិតផ្តល់សេវា បែបបទ នៃការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលនិងថែទាំ ព្រមទាំងកម្រិតនៃការពេញចិត្តចំពោះគុណភាពសេវារបស់សមាជិក ប.ស.ស ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃគុណភាពសេវា ដែលកំណត់ដោយក្រសួងសុខាភិបាល។

**ប្រការ ៦.-**

ដើម្បីធានាបាននូវគុណភាពសេវាជូនសមាជិក ប.ស.ស ត្រូវកំណត់ពីវិធីសាស្ត្រ និងនីតិវិធី ក្នុងការវាស់វែងពីប្រសិទ្ធភាពនៃការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង។

**ប្រការ ៧.-**

ប.ស.ស និងមូលដ្ឋានសុខាភិបាល ត្រូវដោះស្រាយវិវាទដែលអាចកើតមានជាយថាហេតុ ដោយសន្តិវិធី ឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី ឬតាមរយៈក្រសួងអាណាព្យាបាល បើសិនចាំបាច់។

**ប្រការ ៨.-**

បេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង អាចធ្វើការពិនិត្យ និងសើរើកិច្ចព្រមព្រៀងជាថ្មី ដោយផ្អែកលើគុណភាពសេវា កម្រិតផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល និងសេចក្តីត្រូវការចាំបាច់របស់សមាជិក។

**ប្រការ ៩.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**__កន្លែងទទួល៖__**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល

# រវាង

# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

# និង

# មណ្ឌលសុខភាព..................

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើង រវាង:

**បេឡាជាតិរបបសន្តិសុខសង្គម** (**ប.ស.ស**) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

មណ្ឌលសុខភាព..................................................មានទីតាំងស្ថិតនៅអាគារលេខ.............. ភូមិ.........................ឃុំ/សង្កាត់............................ស្រុក/ខណ្ឌ/ក្រុង.......................រាជធានី/ខេត្ត ..................................... ដែលតទៅនេះហៅថា **ភាគី "ខ"**។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី "ក"** និង **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោមៈ

**ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស**

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅ៖

- *សមាជិក ប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅ សហគ្រាស គ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាមីជនមានបញ្ហាសុខភាព ឬគ្រោះថ្នាក់។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ "ប័ណ្ណសមាជិក" និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិក ត្រូវមាន "**ការទទួលស្គាល់ពី ប.ស.ស**"។
- *សហគ្រាស គ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាពក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព ដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល ។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្តល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ទំ និងដោយចលនា ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យនិងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

**ប្រការ ២_. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"**

ក. ដើម្បីផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថា៖

ក.១ មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមណ្ឌលសុខភាព ២៤/២៤ម៉ោង និង ០៧(ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។ រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាល មិនត្រូវយឺតយូរ និងគ្មានហេតុផល បន្ទាប់ពីអ្នកជំងឺ ឬជនរងគ្រោះចូលដល់មណ្ឌល សុខភាព។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬ សេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ ដែលបានកំណត់នៅក្នុងបញ្ជីឱសថសារវ័ន្តរបស់ក្រសួងសុខាភិបាល។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុង គោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការ ចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែល លើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៤ នៃឧបសម្ព័ន្ធនេះ។

ក.៦ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះ និងព្យាបាលជម្ងឺទូទៅ និងជម្ងឺឯកទេស
- ពិគ្រោះ និងព្យាបាលជាមួយនឹងការវះកាត់តូច
- ពិគ្រោះ និងការពិនិត្យផ្ទៃពោះមុនសម្រាល(រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្ត ឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការថែទាំ ព្យាបាល ក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមណ្ឌលសុខភាព
- សម្រាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជា ចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣ Active Management of the Third Stage of Labor (AMTSL) ការដេរស្នាមកាត់ ឬដាច់ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និង តាមដានក្រោយ សម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមណ្ឌលសុខភាព។
- សេវារំលូត និងសំអាតក្រោយរំលូត
- សេវាមន្ទីរពិសោធន៍ និងសេវាអមគ្លីនិកផ្សេងៗទៀត

- សេវាបង្ការសុខភាព: ការពន្យារកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កងក្នុងស្បូន និងដៃ...)
- សេវាពិនិត្យជម្ងឺក្រៅ រួមបញ្ចូលទាំងការពិគ្រោះជំងឺ ការផ្ដល់ឱសថសារវន្ត ការផ្ដល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ ។
- សេវាសម្រាកពេទ្យ រួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថសារវន្ត សេវាអមគ្លីនិកផ្សេងទៀត ឧបករណ៍ និងការថែទាំទាំងអស់។

ក.៧ ផ្ដល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១. ការព្យាបាលមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

៣. ការព្យាបាល និងវះកាត់ប្ដូរភេទ

៤. ការផ្សាំ ឬ ប្ដូរសរីរាង្គផ្សេងៗ

៥. សេវាបង្កកំណើតដោយសិប្បនិម្មិត

៦. ការព្យាបាលដោយខ្លួនឯង

៧. ការព្យាបាល ឬវះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩. ការព្យាបាលញៀនសុរា និងផ្ដាច់គ្រឿងញៀន

១០. ការព្យាបាលអសមត្ថភាពផ្ដល់កំណើត

១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង

១៣. ការលាងឈាម

១៤. ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ខែឧសភា ឆ្នាំ ២០១៦ ស្ដីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។ និង

ក.៨ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬព្យាបាលបាន ឬមិនអាចផ្ដល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេង

ទៀតដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាង ដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ខ. ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា **ភាគី "ខ"** ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬ គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅ៖

ខ.១ ពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវា របស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬស្នាមម្រាមដៃ(Finger Print) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បី៖

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង
- ពិនិត្យឯកសារអ្នកជំងឺ ឬ ជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀត ទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលាបន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងក្នុងចំណុច ៣.៤ នៃឧបសម្ព័ន្ធនេះ។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត របស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី "ក"** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។ និង

ខ.៧ ធានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាព បន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី "ខ"** វិញ ល្គឹកណាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី "ខ"** មិនលើសពី ៤៨ម៉ោង នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា **ភាគី "ខ"** ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ទិន្នន័យប្រើប្រាស់សេវា ដោយមានតម្លៃតាមប្រភេទករណី(Case-based) និងតម្លៃតាមប្រភេទសេវា(Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជសាស្ត្រនិងលទ្ធផល និង វេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាពរបស់សមាជិក ប.ស.ស។ និង

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

## **ប្រការ ៣._ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ក"**

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រ.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវ ដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី "ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និង

អនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"** ដូចខាងក្រោម៖

| *សូចនាករណ៍វាយតម្លៃគុណភាពសេវា* | | | |
|---|---|---|---|
| សូចនាករណ៍(Indicator) | ទិសដៅ | មធ្យោបាយផ្ទៀងផ្ទាត់ | ពេលវេលា |
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០ នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| របាយការណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពីបុគ្គលិក ពេទ្យយ៉ាងតិច ២ ដងក្នុង ១ថ្ងៃ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី "ខ"** | |
|---|---|
| ពិន្ទុ | អត្រានៃការបង់ថ្លៃសេវា |
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬ តិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

៣.៥ ផ្តល់ឲ្យ **ភាគី "ខ"** នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាសគ្រឹះស្ថានដែលបានចុះបញ្ជិកានៅ ប.ស.ស ។

៣.៦ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានត្រលប់ទៅឲ្យ **ភាគី "ខ"** ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី "ខ"** ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

## ប្រការ ៤.. យន្តការដោះស្រាយវិវាទ

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

## ប្រការ ៥.. ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវា និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណ-ភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ) ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦.. ប្រសិទ្ធភាពនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី............ខែ...............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**

បានឃើញ និងបញ្ជូនមក
លោកប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត........
ដើម្បីពិនិត្យ និងសម្រេច។
ធ្វើនៅ...........ថ្ងៃទី..........ខែ.........ឆ្នាំ ២០១៦
**ប្រធានការិយាល័យស្រុកប្រតិបត្តិ.............**

បានឃើញ និងឯកភាព
ធ្វើនៅ..................ថ្ងៃទី...........ខែ...........ឆ្នាំ២០១៦
**ប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត.........**

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល

# រវាង

# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

# និង

# មន្ទីរពេទ្យបង្អែក..............

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើងរវាង:

**បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

មន្ទីរពេទ្យបង្អែក...........................................មានទីតាំងស្ថិតនៅអាគារលេខ.................. ភូមិ.....................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត .............................. ដែលតទៅនេះហៅថា **ភាគី "ខ"** ។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី "ក"** និង **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោម៖

## ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅ៖

- *សមាជិកប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅសហគ្រាស គ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាម៉ីជនមានបញ្ហាសុខភាពឬគ្រោះថ្នាក់ ។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ"ប័ណ្ណសមាជិក"និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិកត្រូវមាន"**ការទទួលស្គាល់ពី ប.ស.ស**" ។
- *សហគ្រាស គ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនទាំងឡាយ ដែលបានចុះបញ្ជិកាក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងសេវាស្តារនីតិសម្បទាដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្តល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា ។
- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល ។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។

- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

**ប្រការ ២.. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"**

ក. ដើម្បីផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថា៖

ក.១ មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមន្ទីរពេទ្យបង្អែក ២៤/២៤ម៉ោង និង ០៧(ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាលមិនត្រូវយឺតយូរ និងគ្មានហេតុផលបន្ទាប់ពីអ្នកជំងឺ ឬ ជនរងគ្រោះចូលដល់មន្ទីរពេទ្យបង្អែក។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យ ដែលបានកំណត់នៅក្នុងគោលនយោបាយសុខាភិបាលសារធារណៈ។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុងគោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ ត្រូវធានាផ្តល់ឱសថ និងសេវាអមវេជ្ជសាស្ត្រ ជូនសមាជិក ប.ស.ស ឲ្យបានគ្រប់គ្រាន់ទោះជាក្នុងស្ថានភាពណាក៏ដោយ។

ក.៦ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែលលើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៣ នៃឧបសម្ព័ន្ធនេះ។

ក.៧ សមាជិកប.ស.ស អាចទទួលបាននូវអាហារក្នុងរយៈពេលសម្រាកពេទ្យ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក.៨ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះ និងព្យាបាលជំងឺទូទៅ និងជំងឺឯកទេស
- ពិគ្រោះ និងព្យាបាលជំងឺរោគស្ត្រី
- ពិគ្រោះ និងព្យាបាលជាមួយ និងការវះកាត់
- ពិគ្រោះ និងព្យាបាលជំងឺទូទៅផ្នែកកុមារ
- ពិគ្រោះ និងព្យាបាលមាត់ធ្មេញ
- ពិគ្រោះពិនិត្យតាមដានផ្ទៃពោះមុនសម្រាល ( រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការព្យាបាល និងថែទាំវេជ្ជសាស្ត្រក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យ
- សម្រាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣(AMTSL) ការដេរស្នាមកាត់ ឬដាច់ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និងតាមដានក្រោយសម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមន្ទីរពេទ្យ។
- រំលូត និងសំអាតក្រោយរលូត
- សេវាអមគ្លីនិកផ្សេងៗទៀត
- ការវះកាត់
- សង្គ្រោះបន្ទាន់
- សម្រាកពេទ្យផ្នែកសល្យសាស្ត្រ
- បង្ការសុខភាពៈ ការពន្យាកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កងក្នុងស្បូន និងដៃ)
- សេវាពិនិត្យជំងឺក្រៅ រួមបញ្ចូលទាំង ការពិគ្រោះជំងឺ ការផ្តល់ឱសថ ការផ្តល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ។
- សេវាសម្រាកពេទ្យ រួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថ សេវាអមគ្លីនិកផ្សេងៗទៀត ឧបករណ៍ និងការថែទាំទាំងអស់។

- បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងបញ្ជូនសព។

ក.៩ ផ្ដល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១-ការព្យាបាលមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២-ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

៣-ការព្យាបាល និងវះកាត់ប្ដូរភេទ

៤- ការផ្សាំ ឬ ប្ដូរសរីរាង្គផ្សេងៗ

៥- សេវាបង្កកំណើតដោយសិប្បនិម្មិត

៦- ការព្យាបាលដោយខ្លួនឯង

៧- ការព្យាបាល ឬ វះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩- ការព្យាបាលញៀនសុរា និងផ្ដាច់គ្រឿងញៀន

១០- ការព្យាបាលអសមត្ថភាពផ្ដល់កំណើត

១១- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង

១៣- ការលាងឈាម

១៤- ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តន៍ការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ខែឧសភា ឆ្នាំ ២០១៦ ស្ដីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ក.១០ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬ ព្យាបាលបាន ឬមិនអាចផ្ដល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេងទៀត ដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាង ដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ក.១១ ចំពោះការផ្តល់ឈាម ប.ស.ស អនុវត្តតាមគោលនយោបាយសុខាភិបាលសាធារណៈ។

ខ. ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា **ភាគី "ខ"** ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅ៖

ខ.១ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ខ"** ត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវារបស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬស្នាមម្រាមដៃ(Finger print) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវា លើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បី៖

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង
- ពិនិត្យឯកសារអ្នកជំងឺ ឬជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពី ការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលាបន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការ

វាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់ ០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងនៅក្នុងតារាងទី១។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប /ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី** "**ក**" ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។

ខ.៧ ធានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាព បន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី** "**ខ**" វិញ ល្គឹកណាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី** "**ខ**" មិនលើសពី ៤៨ ម៉ោងនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

ខ.៨ ទទួលយកការដាក់ភ្នាក់ងារ និងមានបន្ទប់ធ្វើការសម្រាប់ភ្នាក់ងារ ប.ស.ស នៅក្នុងមន្ទីរពេទ្យបង្អែកជាការចាំបាច់។

**គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖**

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ ទិន្នន័យប្រើប្រាស់សេវាដោយ មានតម្លៃតាមប្រភេទករណី (Case-based) និងតម្លៃតាមប្រភេទសេវា (Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជសាស្ត្រ និងលទ្ធផល និងវេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាពមន្ទីរពេទ្យបង្អែករបស់សមាជិក ប.ស.ស ។

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

**ប្រការ ៣ _ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ក"**

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគីភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី"ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី"ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី"ខ"** ដូចខាងក្រោម៖

| តារាងទី១. សូចនាករណ៍វាយតម្លៃគុណភាពសេវា | | | |
|---|---|---|---|
| **សូចនាករណ៍(Indicator)** | **ទិសដៅ** | **មធ្យោបាយផ្ទៀងផ្ទាត់** | **ពេលវេលា** |
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| របាយការណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប. ស.ស. | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពីបុគ្គលិក | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ | ០៦ខែម្តង |

| | | | |
|---|---|---|---|
| ពេទ្យយ៉ាងតិច ២ ដងក្នុង១ថ្ងៃ | | ប.ស.ស | |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| តារាងទី២. ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី**"**ខ**" | |
|---|---|
| ពិន្ទុ | អត្រានៃការបង់ថ្លៃសេវា |
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬតិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

ការទូទាត់ និងការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី៖

- **ភាគី** "**ក**" នឹងទូទាត់ ១០០% ទៅតាមប្រភេទករណី ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀង រហូតដល់មានការវាយតម្លៃសូចនាករណ៍គុណភាពសេវា។
- ការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី ត្រូវអនុលោមទៅតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាដូចមានចែងក្នុងតារាងទី២ ដែលធ្វើឡើងដោយ ប.ស.ស។

៣.៥ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី** "**ក**" ត្រូវផ្តល់នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ដល់ **ភាគី** "**ខ**" ។

៣.៦ ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី** "**ខ**" និងផ្តល់ព័ត៌មានត្រលប់ទៅឲ្យ **ភាគី** "**ខ**" ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី** "**ខ**" ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

### ប្រការ ៤ _ យន្តការដោះស្រាយវិវាទ

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

### ប្រការ ៥ _ ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវានិងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ)ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ៦ _ ប្រសិទ្ធភាព នៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី............ខែ...............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**

បានឃើញ និងបញ្ជូនមក
លោកប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត........
ដើម្បីពិនិត្យ និងសម្រេច។
ធ្វើនៅ...........ថ្ងៃទី.....ខែ.........ឆ្នាំ ២០១៦
**ប្រធានការិយាល័យស្រុកប្រតិបត្តិ.............**

បានឃើញ និងឯកភាព
ធ្វើនៅ...........ថ្ងៃទី.....ខែ.........ឆ្នាំ ២០១៦

**ប្រធានមន្ទីរសុខាភិបាលរាជធានី/ខេត្ត.........**

# កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់និងការផ្តល់សេវាសុខាភិបាល

# រវាង

# បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)

# និង

# មន្ទីរពេទ្យ..............

កិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលត្រូវបានធ្វើឡើងរវាង៖

**បេឡាជាតិរបបសន្តិសុខសង្គម** (**ប.ស.ស**) មានទីស្នាក់ការកណ្តាលស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលតទៅនេះហៅថា **ភាគី "ក"** ។

និង

មន្ទីរពេទ្យ.......................................................មានទីតាំងស្ថិតនៅអាគារលេខ..................
ភូមិ......................ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ/ក្រុង...............................រាជធានី/ខេត្ត
.............................. ដែលតទៅនេះហៅថា **ភាគី "ខ"** ។

គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺដើម្បីកំណត់នូវលក្ខខណ្ឌយោងការងារដែលត្រូវអនុវត្ត ដោយ **ភាគី "ក"** និង **ភាគី "ខ"** ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាតាមលក្ខខណ្ឌយោងការងារដូចខាងក្រោម៖

## ប្រការ ១_. វាក្យស័ព្ទបច្ចេកទេស

វាក្យស័ព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងកិច្ចព្រមព្រៀងនេះមានដូចតទៅ៖

- *សមាជិក ប.ស.ស* សំដៅដល់កម្មករនិយោជិតដែលបានបម្រើការងារនៅសហគ្រាសគ្រឹះស្ថានរហូតមកដល់កាលបរិច្ឆេទដែលសាមីជនមានបញ្ហាសុខភាពឬគ្រោះថ្នាក់ ។ លក្ខណៈសំគាល់នៃសមាជិក ប.ស.ស អាចត្រូវកំណត់បានដោយ "ប័ណ្ណសមាជិក" និងក្នុងករណីដែលពុំទាន់មានប័ណ្ណសមាជិកត្រូវមាន **"ការទទួលស្គាល់ពី ប.ស.ស"** ។
- *សហគ្រាសគ្រឹះស្ថាន* សំដៅដល់រោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនទាំងឡាយ ដែលបានចុះបញ្ជិកាក្នុង ប.ស.ស ។
- *សេវាសុខាភិបាល* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបង្ការសុខភាព សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងសេវាស្តារនីតិសម្បទាដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់នានា ដើម្បីបង្ការជំងឺ និងហានិភ័យសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព ការផ្តល់ថ្នាំបង្ការ ។ល។
- *សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជ-សាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ទំ និងដោយចលនា ។
- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល ។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល ហើយបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។
- *សម្រាកមាតុភាព* សំដៅដល់ការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន ។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ។

**ប្រការ ២_. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី "ខ"**

ក. ដើម្បីផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព និងទាន់ពេល ជូនសមាជិក ប.ស.ស **ភាគី "ខ"** ត្រូវធានាថា៖

ក.១. មានបុគ្គលិកបំពេញការងារ និងប្រចាំការនៅមន្ទីរពេទ្យ ២៤/២៤ម៉ោង និង០៧ (ប្រាំពីរ)ថ្ងៃក្នុងមួយសប្តាហ៍។ រយៈពេលរង់ចាំទទួលការពិគ្រោះ និងព្យាបាលមិនត្រូវយឺតយូរ និងគ្មានហេតុផល បន្ទាប់ពីអ្នកជំងឺ ឬជនរងគ្រោះចូលដល់មន្ទីរពេទ្យ។

ក.២ ផ្តល់ការពិគ្រោះ ព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងវេជ្ជបញ្ជា ស្របតាមពិធីសារ ឬសេចក្តីណែនាំប្រតិបត្តិគ្លីនិក របស់ក្រសួងសុខាភិបាល។

ក.៣ ចេញវេជ្ជបញ្ជាត្រឹមត្រូវដោយប្រើប្រាស់ឱសថ សម្ភារ បរិក្ខារ និងឧបករណ៍ពេទ្យដែលបានកំណត់នៅក្នុងគោលនយោបាយសុខាភិបាលសារធារណៈ។

ក.៤ ផ្តល់សេវាសុខាភិបាលដទៃទៀត ដែលលើកលែងការបង់ថ្លៃដូចមានកំណត់ក្នុងគោលនយោបាយសុខាភិបាលសាធារណៈ មានជាអាទិ៍ ការផ្តល់វ៉ាក់សាំងបង្ការជម្ងឺ ការផ្តល់មីក្រូសារជាតិ (គ្រាប់ថ្នាំជីវជាតិអា ជីវជាតិដែក/អាស៊ីតហ្វូលិក) បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ការព្យាបាលជំងឺរបេង ។ល។

ក.៥ ត្រូវធានាផ្តល់ឱសថ និងសេវាអមវេជ្ជសាស្ត្រ ជូនសមាជិក ប.ស.ស ឲ្យបានគ្រប់គ្រាន់ទោះជាក្នុងស្ថានភាពណាក៏ដោយ។

ក.៦ គ្មានការបង់ថ្លៃសេវា ដោយរាប់បញ្ចូលទាំងការបង់ថ្លៃក្រៅផ្លូវការ ដោយសមាជិក ប.ស.ស នៅពេលប្រើប្រាស់ ឬទទួលសេវាសុខាភិបាល និងសេវាដទៃទៀតដែលលើកលែងការបង់ថ្លៃដូចមានចែងក្នុងចំណុច ក.៣ នៃឧបសម្ព័ន្ធនេះ។

ក.៧ សមាជិកប.ស.ស អាចទទួលបាននូវអាហារក្នុងរយៈពេលសម្រាកពេទ្យ តាមការកំណត់របស់ក្រសួងសុខាភិបាល។

ក.៨ ផ្តល់សេវាដូចខាងក្រោម៖

- ពិគ្រោះនិងព្យាបាលជំងឺទូទៅ និងជំងឺឯកទេស
- ពិគ្រោះ និងព្យាបាលជំងឺរោគស្ត្រី
- ពិគ្រោះនិងព្យាបាលជាមួយ និងការវះកាត់
- ពិគ្រោះ និងព្យាបាលជំងឺទូទៅផ្នែកកុមារ
- ពិគ្រោះនិងព្យាបាលមាត់ធ្មេញ

- ពិគ្រោះពិនិត្យតាមដានផ្ទៃពោះមុនសម្រាល (រួមទាំងសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត) ការពិគ្រោះក្រោយសម្រាល ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្រោយរលូត និងការចាក់ថ្នាំបង្ការនៅមន្ទីរពេទ្យ
- សំរាលកូន និងសេវាចាំបាច់ដទៃទៀតរួមមានៈ ការចាក់ថ្នាំ Oxytocin ជាចំណែកមួយ នៃការគ្រប់គ្រងការសម្រាលសកម្មដំណាក់កាលទី៣(AMTSL) ការដេរស្នាមកាត់ ឬដាច់ ទ្វារមាស ការថែទាំ និងសង្គ្រោះទារកនៅពេលកើតភ្លាម ការថែទាំ និងតាមដានក្រោយសម្រាលសម្រាប់ករណីសម្រាលកូនធម្មតានៅមន្ទីរពេទ្យ។
- រំលូត និងសំអាតក្រោយរលូត
- មន្ទីរពិសោធន៍ និងសេវាអមគ្លីនីកផ្សេងៗទៀត
- ការវះកាត់
- សង្គ្រោះបន្ទាន់
- សម្រាកពេទ្យផ្នែកសល្យសាស្ត្រ
- បង្ការសុខភាពរួមមាន ការពន្យាកំណើតករណីថ្មី និងករណីបន្តបន្ទាប់(រួមទាំងការប្រឹក្សា និងវិធីសាស្ត្រពន្យារកំណើតទំនើប ស្រោមអនាម័យ ថ្នាំគ្រាប់ ឬថ្នាំចាក់ពន្យាកំណើត ការដាក់កង ក្នុងស្បូន និងដៃ)
- សេវាពិនិត្យជំងឺក្រៅ រួមបញ្ចូលទាំង ការពិគ្រោះជំងឺ ការផ្តល់ឱសថ ការផ្តល់សេវាអមគ្លីនិកផ្សេងៗទៀត សេវាព្យាបាលដោយចលនា និងការតាមដានជំងឺ។
- សេវាសម្រាកពេទ្យរួមបញ្ចូលទាំងការពិនិត្យព្យាបាលជំងឺ ការពិនិត្យតាមដានជំងឺ ថ្លៃបន្ទប់ ឱសថ សេវាអមគ្លីនិកផ្សេងៗទៀត ឧបករណ៍ និងការថែទាំទាំង-អស់។
- បញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងបញ្ជូនសព។

ក.៩ ផ្តល់ព័ត៌មានពីសេវាដែលមិនត្រូវបានធានារ៉ាប់រងដល់សមាជិក ប.ស.ស ដូចខាងក្រោម ៖

១. ការព្យាបាលមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
២. ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
៣. ការព្យាបាល និងវះកាត់ប្តូរភេទ
៤. ការផ្សាំ ឬ ប្តូរសរីរាង្គផ្សេងៗ
៥. សេវាបង្កកំណើតដោយសិប្បនិម្មិត
៦. ការព្យាបាលដោយខ្លួនឯង
៧. ការព្យាបាល ឬវះកាត់ដើម្បីប្រយោជន៍ នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨. ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
៩. ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
១០. ការព្យាបាលអសមត្ថភាពផ្តល់កំណើត
១១. ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
១២. ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
១៣. ការលាងឈាម
១៤. ការព្យាបាលជំងឺមហារីកដោយសារធាតុគីមី

ក្នុងករណីសង្គ្រោះបន្ទាន់ សេវាដូចមានចែងខាងលើត្រូវបានធានាដោយ **ភាគី "ក"** ហើយអនុវត្តការទូទាត់ថ្លៃសេវា ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ខែឧសភា ឆ្នាំ ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

ក.១០ បញ្ជូនអ្នកជំងឺ ឬជនរងគ្រោះដែល **ភាគី "ខ"** មិនអាចធ្វើរោគវិនិច្ឆ័យ និង/ឬព្យាបាលបាន ឬមិនអាចផ្តល់សេវាអមគ្លីនិកបាន ទៅកាន់មូលដ្ឋានសុខាភិបាលផ្សេងទៀតដែលបានចុះកិច្ចព្រមព្រៀងជាមួយ **ភាគី "ក"** ហើយមានសមត្ថភាពបច្ចេកទេសខ្ពស់ជាងដោយភ្ជាប់ទៅជាមួយនូវឯកសារបញ្ជូនគ្រប់គ្រាន់។

ក.១១ ចំពោះការផ្តល់ឈាម ប.ស.ស អនុវត្តន៍តាមគោលនយោបាយសុខាភិបាលសាធារណៈ។

ខ. **ដើម្បីធានាប្រសិទ្ធភាពនៃការលើកកម្ពស់គុណភាពសេវា និងការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវសហប្រតិបត្តិការជាមួយមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ដោយត្រូវអនុវត្តភារកិច្ចដូចតទៅ៖**

ខ.១ ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ខ"** ត្រូវពិនិត្យ ផ្ទៀងផ្ទាត់សុពលភាពប្រើប្រាស់សេវារបស់សមាជិក ប.ស.ស តាមរយៈប័ណ្ណសមាជិក ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬការបញ្ជូនសារ(SMS) ឬ ស្នាមម្រាមដៃ(Fingerprint) ឬតាមរយៈទូរស័ព្ទស្នើសុំការបញ្ជាក់អត្តសញ្ញាណពី ប.ស.ស នៅមុនពេលផ្តល់សេវាលើកលែងតែក្នុងករណីត្រូវការសង្គ្រោះបន្ទាន់។ **ភាគី "ក"** នឹងមិនទូទាត់ថ្លៃសេវាដែល **ភាគី "ខ"** បានផ្តល់ឲ្យសមាជិក ប.ស.ស ណាដែលគ្មានសុពលភាពប្រើប្រាស់សេវានោះឡើយ។

ខ.២ អនុញ្ញាតឲ្យមន្ត្រី បុគ្គលិក ឬគណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ឬគ្រូពេទ្យត្រួតពិនិត្យគុណភាពសេវា ឬមន្ត្រីអធិការកិច្ច ដែលត្រូវបានចាត់តាំងជាផ្លូវការ នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីនាយក ប.ស.ស ដើម្បី៖

- ត្រួតពិនិត្យមើលប្រតិបត្តិការផ្តល់សេវារបស់ **ភាគី "ខ"** និង

- ពិនិត្យឯកសារអ្នកជំងឺឬជនរងគ្រោះ ដែលជាសមាជិក ប.ស.ស ឬឯកសារពាក់ព័ន្ធចាំបាច់ផ្សេងៗទៀតទាក់ទងនឹងការផ្តល់សេវា និងការទូទាត់ថ្លៃសេវា។

ខ.៣ ធានាថាសមាជិក ប.ស.ស ជាស្ត្រីមានផ្ទៃពោះ បានធ្វើការពិនិត្យឈាម ហើយរកឃើញថាមានផ្ទុកមេរោគអេដស៍(HIV) នោះការសម្រាលកូនត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំស្តីពី ការបង្ការការចំលងមេរោគអេដស៍(HIV) ពីម្តាយទៅទារក "Prevention of Mother-to-Child Transmission (PMTCT)" ។

ខ.៤ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែលម្អគុណភាពសេវាឲ្យទាន់ពេលវេលាបន្ទាប់ពីទទួលបានអនុសាសន៍ជាផ្លូវការ ពី ប.ស.ស ដោយផ្អែកលើ លទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលធ្វើឡើងរៀងរាល់ ០៦(ប្រាំមួយ)ខែ ដោយ ប.ស.ស ដូចមានចែងនៅក្នុងតារាងទី១។

ខ.៥ កំណត់រោគវិនិច្ឆ័យ និងសេវា ដើម្បីបញ្ចូលទៅក្នុងប្រភេទករណីណាមួយ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព។

ខ.៦ ត្រូវមានកាតព្វកិច្ចកត់ត្រា និងរក្សាទុករាល់ឯកសារវេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់សមាជិក ប.ស.ស ដែលបានប្រើប្រាស់សេវា សម្រាប់ជាទិន្នន័យដល់ **ភាគី "ក"** ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ តាមដាន និងវាយតម្លៃ ។

ខ.៧ ធានាថាសមាជិក ប.ស.ស ដែលបានបង់ប្រាក់មុនការកំណត់សុពលភាពបន្ទាប់មករកឃើញថាមានសិទ្ធិប្រើប្រាស់សេវា សមាជិកនោះអាចទទួលបានប្រាក់ថ្លៃសេវាដែលបានបង់រួចពី **ភាគី "ខ"** វិញ លុះត្រាតែបានផ្តល់ព័ត៌មាននេះទៅ **ភាគី "ខ"** មិនលើសពី ៤៨ម៉ោង នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេវា ។

ខ.៨ ទទួលយកការដាក់ភ្នាក់ងារ និងមានបន្ទប់ធ្វើការសម្រាប់ភ្នាក់ងារ ប.ស.ស នៅក្នុងមន្ទីរពេទ្យបង្អែកជាការចាំបាច់។

**គ. ដើម្បីទទួលបានការទូទាត់ថ្លៃសេវា ភាគី "ខ" ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ ប.ស.ស ដោយអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖**

គ.១ រាល់ការស្នើសុំទូទាត់ថ្លៃសេវាត្រូវធ្វើឡើងនៅរៀងរាល់ដំណាច់ខែនីមួយៗ ដោយមានភ្ជាប់មកជាមួយនូវលិខិតស្នើសុំទូទាត់ ទិន្នន័យប្រើប្រាស់សេវាដោយ មានតម្លៃតាមប្រភេទករណី(Case-based) និងតម្លៃតាមប្រភេទសេវា(Fee-for-Service) ដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព រួមទាំងវិក្កយបត្រ ប័ណ្ណវិភាគអមវេជ្ជ-

សាស្ត្រនិងលទ្ធផល និងវេជ្ជបញ្ជា ព្រមទាំងលិខិតអនុញ្ញាតចេញពីមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែករបស់សមាជិក ប.ស.ស។ និង

គ.២ ត្រូវបើកគណនីនៅធនាគារដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដើម្បីទទួលបានការទូទាត់ថ្លៃសេវា។

## ប្រការ ៣.. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ភាគី"ក"

៣.១ ត្រូវទូទាត់ថ្លៃសេវាជូន **ភាគី "ខ"** ដោយអនុវត្តយន្តការទូទាត់ថ្លៃសេវា តាមប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព។

៣.២ ការទូទាត់ថ្លៃសេវាជូន **ភាគី"ខ"** ត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្នើទូទាត់ថ្លៃសេវា និងឯកសារពាក់ព័ន្ធត្រឹមត្រូវ ដូចមានចែងក្នុងចំណុច គ.១ នៃឧបសម្ព័ន្ធនេះ។

៣.៣ ការទូទាត់ថ្លៃសេវាត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយបញ្ចូលទៅក្នុងគណនីផ្ទាល់របស់ **ភាគី"ខ"**។

៣.៤ ការទូទាត់ថ្លៃសេវាត្រូវបានពិនិត្យកែសម្រួលឡើងវិញ បន្ទាប់ពីលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវាដែលនឹងត្រូវធ្វើក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែម្តង និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី"ខ"** ដូចខាងក្រោម៖

តារាងទី១. សូចនាករណ៍វាយតម្លៃគុណភាពសេវា

| សូចនាករណ៍(Indicator) | ទិសដៅ | មធ្យោបាយផ្ទៀងផ្ទាត់ | ពេលវេលា |
|---|---|---|---|
| រយៈពេលរង់ចាំរបស់អ្នកជំងឺ ឬជនរងគ្រោះមិនលើស ៣០នាទី | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| បុគ្គលិកសុខាភិបាលមានឯកសណ្ឋានត្រឹមត្រូវ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| មានអនាម័យជាទូទៅ និង តាមបន្ទប់ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការទទួលស្គាល់គុណភាពពីអ្នកជំងឺថាល្អ | ៨០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| | | | |
|---|---|---|---|
| របាយការណ៍អំពីឥរិយាបថល្អរបស់បុគ្គលិកពេទ្យចំពោះអ្នកជំងឺ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| ការចុះសួរសុខទុក្ខអ្នកជំងឺអំពីបុគ្គលិក ពេទ្យយ៉ាងតិច ២ ដងក្នុង១ថ្ងៃ | ៩០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការបង់ប្រាក់ក្រៅផ្លូវការក្នុងគ្រប់ករណី | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |
| គ្មានការទាមទារ ឬតម្រូវឲ្យសមាជិក ប.ស.ស ទិញឱសថ លើកលែងតែមានចែងក្នុងបទប្បញ្ញត្តិ | ១០០ ភាគរយ | របាយការណ៍ពីក្រុមការងារ ប.ស.ស | ០៦ខែម្តង |

| តារាងទី២. ពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវាជូន **ភាគី"ខ"** | |
|---|---|
| ពិន្ទុ | អត្រានៃការបង់ថ្លៃសេវា |
| >៩០% | ១២០% |
| >៨៥% ទៅ ៩០% | ១០០% |
| >៧០% ទៅ ៨៥% | ៨០% |
| >៦០% ទៅ ៧០% | ៧០% |
| >៥០% ទៅ ៦០% | ៦០% |
| ស្មើ ៥០% ឬ តិចជាងនេះ | មិនអាចចុះកិច្ចព្រមព្រៀងបាន |

ការទូទាត់ និងការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី៖

- **ភាគី "ក"** នឹងទូទាត់ ១០០% ទៅតាមប្រភេទករណី ដូចមានចែងនៅក្នុងប្រកាសអន្តរក្រសួងលេខ១៧៣ កប/ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់សេវាផ្នែកថែទាំសុខភាព គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀង រហូតដល់មានការវាយតម្លៃសូចនាករណ៍គុណភាពសេវា។

- ការកែសម្រួលអត្រាទូទាត់តាមប្រភេទករណី ត្រូវអនុលោមទៅតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាដូចមានចែងក្នុងតារាងទី២ ដែលធ្វើឡើងដោយ ប.ស.ស។

៣.៥  ក្នុងករណីដែលពុំមានភ្នាក់ងារ ប.ស.ស **ភាគី "ក"** ត្រូវផ្តល់នូវបញ្ជីឈ្មោះសមាជិកដែលមានសុពលភាព និងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកានៅ ប.ស.ស ដល់ **ភាគី "ខ"** ។

៣.៦  ធ្វើការស្ទង់មតិ ពីភាពពេញចិត្តរបស់សមាជិកចំពោះសេវា **ភាគី "ខ"** និងផ្តល់ព័ត៌មានត្រលប់ទៅឲ្យ **ភាគី "ខ"** ព្រមទាំងក្រសួងអាណាព្យាបាលអំពីលទ្ធផលនៃការស្ទង់មតិនោះ។

៣.៧ រៀបចំកិច្ចប្រជុំជាមួយ **ភាគី "ខ"** ឲ្យបានមួយដងយ៉ាងតិចក្នុងមួយឆ្នាំ ដើម្បីពិភាក្សារកដំណោះស្រាយអំពីបញ្ហាការផ្តល់សេវាសុខាភិបាល និងបញ្ហានានាដែលបានជួបប្រទះ។ ក្នុងករណីចាំបាច់ភាគីនីមួយៗអាចស្នើសុំឲ្យមានកិច្ចប្រជុំបន្ថែម។

**ប្រការ ៤. យន្តការដោះស្រាយវិវាទ**

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវធ្វើការដោះស្រាយដោយសន្តិវិធី ដោយឈរលើផលប្រយោជន៍រួម តាមយន្តការទ្វេភាគី រដ្ឋបាល ឬគណៈកម្មការវេជ្ជសាស្ត្រ ឬអាជ្ញាធរជាអាណាព្យាបាល។

**ប្រការ ៥. ការពិនិត្យ និងកែសម្រួលកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ឬសើរើឡើងវិញ ដោយផ្អែកទៅតាមលទ្ធផលនៃការវាយតម្លៃសូចនាករណ៍គុណភាពសេវា និងអនុលោមតាមពិន្ទុវាយតម្លៃសូចនាករណ៍គុណភាពសេវាសម្រាប់កំណត់អត្រាបង់ថ្លៃសេវា។

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាច្បាប់ដើមចំនួន០២(ពីរ)ច្បាប់ ជាភាសាខ្មែរ ហើយមានតម្លៃស្មើគ្នានៅចំពោះមុខច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦. ប្រសិទ្ធភាព នៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅ....................ថ្ងៃទី............ខែ..............ឆ្នាំ២០១៦

**ភាគី "ខ"** **ភាគី "ក"**

# ឧបសម្ព័ន្ធទី៤
# ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាល ផ្នែកហានិភ័យការខារនិងថែទាំ សុខភាពតាមបណ្ដា រាជធានី ខេត្ត

- **តារាងទី ១. ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារ**

| ល.រ | ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារ | ចំនួនមូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារ |
|---|---|---|
| ១ | មូលដ្ឋានសុខាភិបាលសាធារណៈ: | |
| | - មន្ទីរពេទ្យថ្នាក់ជាតិ | ០៦ |
| | - មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត/ស្រុក | ៧៥ |
| | - មណ្ឌលសុខភាពរាជធានី/ខេត្ត/ស្រុក | ៣៥ |
| ២ | មូលដ្ឋានសុខាភិបាលឯកជន (មន្ទីរ ឬពហុព្យាបាលឯកជន) | ១៥ |
| សរុបមូលដ្ឋានសុខាភិបាល | | ១៣១ |

- **តារាងទី ១.១. មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារតាមបណ្តាលរាជធានី/ខេត្ត**

| ល.រ | មូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារតាមបណ្តាលរាជធានី/ខេត្ត | ចំនួនមូលដ្ឋានសុខាភិបាលផ្នែកហាភ័យការងារ |
|---|---|---|
| ១ | មន្ទីរពេទ្យថ្នាក់ជាតិ | ០៦ |
| ២ | រាជធានីភ្នំពេញ (លើកលែងមន្ទីរពេទ្យថ្នាក់ជាតិ) | ២៦ |
| ៣ | ខេត្តកណ្តាល | ២១ |
| ៤ | ខេត្តកំពង់ស្ពឺ | ០៤ |
| ៥ | ខេត្តស្វាយរៀង | ០៣ |
| ៦ | ខេត្តកំពង់ឆ្នាំង | ០២ |
| ៧ | ខេត្តព្រះសីហនុ | ០៥ |
| ៨ | ខេត្តសៀមរាប | ០២ |
| ៩ | ខេត្តបន្ទាយមានជ័យ | ០៣ |

| | | |
|---|---|---|
| ១០ | ខេត្តកំពង់ចាម | ០៨ |
| ១១ | ខេត្តត្បូងឃ្មុំ | ០៣ |
| ១២ | ខេត្តក្រចេះ | ០៣ |
| ១៣ | ខេត្តព្រៃវែង | ០៨ |
| ១៤ | ខេត្តតាកែវ (លើកលែងមន្ទីរពេទ្យថ្នាក់ជាតិ) | ០៩ |
| ១៥ | ខេត្តកែប | ០១ |
| ១៦ | ខេត្តស្ទឹងត្រែង | ០១ |
| ១៧ | ខេត្តកំពត | ០២ |
| ១៨ | ខេត្តពោធិ៍សាត់ | ០៦ |
| ១៩ | ខេត្តកោះកុង | ០២ |
| ២០ | ខេត្តប៉ៃលិន | ០១ |
| ២១ | ខេត្តបាត់ដំបង | ០៥ |
| ២២ | ខេត្តកំពង់ធំ | ០៣ |
| ២៣ | ខេត្តរតនគីរី | ០២ |
| ២៤ | ខេត្តមណ្ឌលគីរី | ០៣ |
| ២៥ | ខេត្តឧត្តរមានជ័យ | ០៣ |
| ២៦ | ខេត្តព្រះវិហារ | ០៩ |
| សរុបចំនួនមូលដ្ឋានសុខាភិបាលផ្នែកហានិភ័យការងារតាមបណ្តាលរាជធានី/ខេត្ត | | ១៣១ |

- **តារាងទី ២. ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព**

| ល.រ | ចំណាត់ថ្នាក់មូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព | ចំនួនមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព |
|---|---|---|
| ១ | មូលដ្ឋានសុខាភិបាលសាធារណៈ | |
| | - មន្ទីរពេទ្យថ្នាក់ជាតិ | ០៥ |
| | - មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត/ស្រុក | ១០៩ |
| | - មណ្ឌលសុខភាពរាជធានី/ខេត្ត/ស្រុក | ១១៧៤ |
| ២ | មូលដ្ឋានសុខាភិបាលឯកជន (មន្ទីរ ឬពហុព្យាបាលឯកជន) | ៣១ |
| សរុបមូលដ្ឋានសុខាភិបាល | | ១ ៣១៩ |

- **តារាងទី ២.១ មូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាពតាមបណ្ដាលរាជធានី/ខេត្ត**

| ល.រ | មូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាពតាមបណ្ដាលរាជធានី/ខេត្ត | ចំនួនមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាព |
|---|---|---|
| ១ | មន្ទីរពេទ្យថ្នាក់ជាតិ | ០៥ |
| ២ | រាជធានីភ្នំពេញ (លើកលែងមន្ទីរពេទ្យថ្នាក់ជាតិ) | ៦៨ |
| ៣ | ខេត្តកណ្ដាល | ១១២ |
| ៤ | ខេត្តកំពង់ស្ពឺ | ៦១ |
| ៥ | ខេត្តស្វាយរៀង | ៤៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤៤ |
| ៧ | ខេត្តព្រះសីហនុ | ១៧ |
| ៨ | ខេត្តសៀមរាប | ៩៥ |

| | | |
|---|---|---|
| ៩ | ខេត្តបន្ទាយមានជ័យ | ៧២ |
| ១០ | ខេត្តកំពង់ចាម | ៩៥ |
| ១១ | ខេត្តត្បូងឃ្មុំ | ៧២ |
| ១២ | ខេត្តក្រចេះ | ៣៣ |
| ១៣ | ខេត្តព្រៃវែង | ១១៧ |
| ១៤ | ខេត្តតាកែវ (លើកលែងមន្ទីរពេទ្យថ្នាក់ជាតិ) | ៨៦ |
| ១៥ | ខេត្តកែប | ០៦ |
| ១៦ | ខេត្តស្ទឹងត្រែង | ១៣ |
| ១៧ | ខេត្តកំពត | ៦៧ |
| ១៨ | ខេត្តពោធិ៍សាត់ | ៤៤ |
| ១៩ | ខេត្តកោះកុង | ១៥ |
| ២០ | ខេត្តប៉ៃលិន | ០៧ |
| ២១ | ខេត្តបាត់ដំបង | ៨៣ |
| ២២ | ខេត្តកំពង់ធំ | ៥៥ |
| ២៣ | ខេត្តរតនគីរី | ២៧ |
| ២៤ | ខេត្តមណ្ឌលគីរី | ១៣ |
| ២៥ | ខេត្តឧត្តរមានជ័យ | ៣៦ |
| ២៦ | ខេត្តព្រះវិហារ | ២៨ |
| សរុបចំនួនមូលដ្ឋានសុខាភិបាលផ្នែកថែទាំសុខភាពតាមបណ្តាលរាជធានី/ខេត្ត | | ១ ៣១៩ |